**សម្ភាសន៍ជាមួយ ឯម សារិន ភេទប្រុស អាយុ៦៦ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ"កងអនុសេនាធំស្រុកអន្លង់វែង"**

**ស្រុកកំណើត ភូមិសង្គ្រា ឃុំព្រៃសន្ទឹក ស្រុកទ្រាំង ខេត្តតាកែវ ។**

**សព្វថ្ងៃរស់ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ**

**ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឌី ខាំបូលី និង សោម ប៊ុនថន**

**០៣ៈ៣៨ៈ២២**

**៦៧ទំព័រ**

បូលីៈ ចឹងជាថ្មីម្តងទៀត ខ្ញុំសូមជម្រាបអ៊ំ ខ្ញុំឈ្មោះ ឌីខាំ បូលី មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

សារិនៈ បូលី!

បូលីៈ បូលីៗ! "ល" ដាក់ស្រះ "ី" ។ ហើយខ្ញុំមកនេះ គឺខ្ញុំចង់សរសេរសៀវភៅប្រវត្តិសាស្ត្រអំពីតំបន់អន្លង់វែងមួយសម្រាប់ឲ្យអ្នកកើតមិនទាន់សម័យកាលសង្គ្រាម សម័យកាលតស៊ូ ក៏ដូចសម័យកាលចរចារស្វែងរកវិភាគសន្តិភាពឲ្យបានយល់អំពីថាតើឪពុកម្តាយអ៊ុំពូមីងអីចាស់ៗហ្នឹងគាត់បានឆ្លងកាត់អីខ្លះ ហើយគាត់បានធ្វើអ្វីខ្លះ ទើបបានយើងមានសន្តិភាពរហូតដល់ថ្ងៃនេះយើងរស់នៅក្នុងក្រមខ័ណ្ឌរាជរដ្ឋាភិបាលតែមួយអញ្ចឹង មុនហ្នឹងឈានទៅដល់ថ្ងៃហ្នឹងយើងបានអ៊ុំៗចាស់ៗ គាត់បានធ្វើអីខ្លះ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងផង ។ បាទ! ចឹងជាបឋមខ្ញុំសូមស្គាល់ឈ្មោះ អ៊ំ!

សារិនៈ ខ្ញុំឈ្មោះ ឯម សារិន ។

បូលីៈ ឯម សារិន?

សារិនៈ បាទៗ

បូលីៈ អ៊ំសព្វថ្ងៃអ៊ំបម្រើការជា?

សារិនៈ ជាប្រធានក្រុមប្រឹក្សាស្រុក ។

បូលីៈ ត្រពាំងប្រាសាទ ។

សារិនៈ បាទ!

បូលីៈ អ៊ំ មានស្រុកកណើតនៅឯណាដែលអ៊ំ?

សារិនៈ ស្រុកកំណើតខ្ញុំ ភូមិសង្គ្រា ឃុំព្រៃសន្ទឹក ស្រុកទ្រាំង ខេត្តតាកែវ ។

បូលីៈ ចុះបច្ចុប្បន្ននេះ?

សារិនៈ បច្ចុប្បន្ននេះគឺ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។

បូលីៈ អ៊ឹ មានគ្រួសារឈ្មោះអីដែរ?

សារិនៈ គ្រួសារខ្ញុំឈ្មោះ អឹម ហឹន ។

បូលីៈ គាត់មានមុខរបរជាអី?

សារិនៈ មុខរបរ ជាកសិករ ។

បូលីៈ អ៊ឹមានកូនប៉ុន្មាននាក់ហើយ?

សារិនៈ ខ្ញុំមានកូន៦នាក់ ប្រុស៤ ស្រី២ ។

បូលីៈ នៅក្នុងបន្ទុកទាំងអស់ ឬក៏?

សារិនៈ មិននៅទាំងអស់ទេ នៅក្នុងបន្ទុកតែ៤ទេ ព្រោះ២គេមានប្រពន្ធហើយ ។

បូលីៈ គេការហើយគេចេញទៅ ។ ខ្ញុំចង់ឈានទៅរកប្រវត្តិសង្ខេបរបស់អ៊ឹបន្តិច មុនហ្នឹងរាកយើងតក្អាប់មក តស៊ូមកលើភ្នំដងរែកនេះ ។ អ៊ុំចូលបដិវត្តន៍នេះ ពីឆ្នាំណាដែរអ៊ឹ?

សារិនៈ ខ្ញុំចូលតាំងពី បើនិយាយទៅថ្ងៃ២៥ ខែ៤ ឆ្នាំ៧០ ។

បូលីៈ បានន័យថាក្រោយរដ្ឋប្រហារបន្តិច?

សារិនៈ បាទ! ក្រោយរដ្ឋប្រហារ ដុះខ្ញុំរដ្ឋប្រហារ ខ្ញុំកំពុងតែសិក្សាអនុវិទ្យាល័យវត្តតុមខេត្តតាកែវ ធ្វើរដ្ឋប្រហារហ្នឹង សាលាក៏បិទ ខ្ញុំនៅរយៈ៥ថ្ងៃក៏អត់មានការសិក្សាបានខ្ញុំទៅផ្ទះ ។

បូលីៈ បានន័យថានៅតាកែវ គ្រាន់តែក្រោយរដ្ឋប្រហារភ្លាមសាលារៀនហ្នឹង បិទតែម្តង?

សារិនៈ បិទ!

បូលីៈ មូលហេតុអ្វីបានជាបិទសាលា?

សារិនៈ បិទសាលាដោយ ទីមួយគឺថា គ្រូទាំងអស់របៀបថាធ្វើរដ្ឋប្រហារ ចលាចលទាំងអស់ អត់ឃើញមក កូនសិស្សមករៀន ប៉ុនមកអត់គ្រប់ទេ ប៉ុន្តែបាត់គ្រូតែម្តង គ្រប់សាលាទាំងអស់ ។

បូលីៈ ក្រោយមកមានការរៀបចំឡើងវិញឲ្យស្រុកទេសស្រួលបួលការបើសាលាឡើងវិញក្រោយមកបន្តិច?

សារិនៈ ក្រោយពីចឹងមក ក៏កើតមាន គេហៅថា បើតាមខ្ញុំដឹងគឺបាតុកម្ម គឺបាតុកម្មគឺទាមទារសម្តេចនរោត្តមសីហនុ សម្តេចឪ គេថាទាមទារសម្តេចឪកាលហ្នឹងណា ទាមទារឯករាជ្យ គឺទាមទារសម្តេចឪ ទៅជាចលនាបាតុកម្មនៅស្រុកទ្រាំងខ្ញុំ ផ្សារព្រែកសណ្តែកហ្នឹងគឺមានបញ្ហាមួយទៅជាការស្លាប់រង្គាល គឺបាញ់ បាតុកម្ម ស្លាប់រង្គាលនៅហ្នឹងទីផ្សារហ្នឹង ហើយខ្ញុំមកពីការសិក្សាដែលអត់មានសិក្សាមកឆ្លងកាត់ឃើញ ឃើញមកចំថ្ងៃហ្នឹងតែម្តង ។ ចំថ្ងៃហ្នឹងត្រលប់មកផ្ទះ

ដល់ផ្ទះ ក៏ខ្ញុំប្រាប់ស្ទូរបងប្អូនទាំអស់នៅឯភូមិហ្នឹង ខ្លះបានទៅ ទៅចូលរួមប៉ុន្តែអត់ត្រូវទេ ព្រោះនៅកន្ទុយនេះ ក៏បបួលរត់មកផ្ទះវិញមក ប៉ុន្តែទៅភាគតិចកាលហ្នឹងណា ។ អាហ្នឹងមួយ ហើយមួយទៀត ក្រោយពីមានបញ្ហាហ្នឹងហើយប្រជាជនមានបញ្ហា ថាលែងទុកចិត្តជាមួយហ្នឹង អ្នកដែលធ្វើរដ្ឋប្រហារ លន់ នល់ ហើយមួយទៀតគ្រូ ។ គ្រូទាំងអស់ខ្លះត្រូវទៅជាកាន់ប្រដាប់អាវុធបាញ់គ្នា ធ្វើរដ្ឋប្រហារចឹងណា ធ្វើបាតុកម្មប្រឆាំងជាមួយបាតុកម្មបាញ់ ។ ដល់ចឹងហើយ ប្រជាជនទាំងខ្ញុំ ទាំងគេមានការគិត ដែលខ្ញុំសម្រេចចិត្តនឹងតស៊ូនេះ ទី១ដោយក្រោយពីព្រឹត្តិការណ៍បាតុកម្មនេះស្ងប់ ដល់ស្ងប់ហ្នឹងរយៈមិនបានមួយខែទេ គឺត្រូវការបងខ្ញុំនេះ ត្រូវហ្នឹងថ្ងៃការបងខ្ញុំបងបន្ទាប់ខ្ញុំ គាត់មកតាមខ្ញុំក្រោយពីនេះ អីហ្នឹងគឺថាការ ដល់ការទៅធ្វើយុទ្ធនាការរបស់ចលនាខ្លាំងប្រឆាំងជាមួយ លន់ លន់ ហើយទៅមើលសភាពការណ៍កងទ័ពបេះតែបុក ដែលហៅថាចលនា ដល់ចឹងទៅចូលខេត្ត ដល់ចឹងទៅក៏បានជាទាក់ទងជាមួយដែលហៅថាពួកបញ្ញាការពួកអាធៀវគី គេហៅខាងហ្នឹងណា យួនខាងត្បូងហ្នឹងទាក់ទងហ្នឹងនាំចូល ចំថ្ងៃការបងខ្ញុំ ។

បូលី: រត់មកខាងធៀវគី?

សារិន: បាទ! មកដល់ធ្វើបាប ចង់និយាយថា កាលហ្នឹងយើងទៅចឹងទៅ ដល់ត្រលប់មកវិញប្រមូលចានឆ្នាំងដែលនៅផ្ទះទាំងអស់ហ្នឹង ដាក់នៅលើវាលស្រែតម្រៀបនៅលើវាលស្រែ ហើយបរថក្រោះកិន កងវិទ្យុអីសម្ភារអីយកទៅទាំងអស់ ហើយខ្ញុំសម្រេចចិត្តដោយ ទី១ធ្វើបាបខ្ញុំ ទី២ធ្វើបបាបឪពុកខ្ញុំ ធៀវគីនេះគេចាប់ឪពុកខ្ញុំទៅ ហើយអង្វរថាកុំធ្វើបាបគាត់តែអត់ទេ វាទាត់ឪពុកខ្ញុំ បីដើងហើយយកលុយចំណេងដៃការទៅអស់ បានខ្ញុំ កុំតែបានបងថ្លៃខ្ញុំក៏ត្រូវគ្រោះថ្នាក់បានបងថ្លៃចាប់ទេ ដល់ចឹងទៅខ្ញុំក៏ទាញកាំបិតនៅលើគ្រែទៅ ហើយស្សៀកសារុងឪពុកខ្ញុំហ្នឹងយកទៅកាប់ នឹកឃើញទាត់ឪពុកបីដើងហើយដួល ហើយចាប់នាំគាត់ បកមកវិញឡើងលើផ្ទះយកលុយឲ្យវា បានខ្ញុំសម្រេចចិត្តថាខ្ញុំត្រូវតែមកចូលរួមតស៊ូឲ្យមានអាវុធ សម័យ៧០ហើយ ។ បានសាប់អាធៀវគីមួយ សាប់ខ្លួនឯងក៏សាប់ចុះដើម្បីសងគុណឪពុកអីចឹងទៅណា ។ ហើយខ្ញុំអត់ដឹងថាតស៊ូ អីយ៉ាងម៉េចទេកាលនោះ នៅវ័យ១៨ ប៉ុន្តែស្ម័គ្រចិត្តចឹងបងនោះក៏ ប្រាប់ទិសប៉ុនខ្ញុំចេញតាំងពីនោះ ចេញតាំងពី៧០រហូតដល់៧៥ បានខ្ញុំទៅស្រុកវិញ ចោលស្រុកចោលទេស ។

បូលី: ឪពុកអ៊ីយ៉ាងម៉េចទៅត្រូវបានធៀវគីទាត់ធាក់ហ្នឹង គាត់របួសធ្ងន់ធ្ងរទេ?

សារិន: គាត់ឈឺធ្ងន់ធ្ងរប៉ុន្តែបងខ្ញុំគេនៅហ្នឹង គេជួយថែទាំព្យាបាលទៅ ឯខ្ញុំក្រោយពីហ្នឹងបាន២ថ្ងៃទេខ្ញុំសម្រេចចិត្តរត់អត់មានប្រាប់នរណាទេ រត់ហ្នឹងបានមិត្តភក្ត្រមកជាមួយ៨នាក់ បានពិភាក្សា

គ្នាសមាជិក៤នាក់ហ្នឹងវត់ជិតភ្ជីវត់ វត់ឡើងមកពីលើទៅស្រុកអង្គរជ័យ ខេត្តកំពតនេះមក តំបន់ភ្នំនេះ មកក៏ជួបជាមួយគេជាមួយឯងទៅកដល់ណាគេតស៊ូកើតជាទ័ព ខ្ញុំនៅប្រវត្តិហ្នឹងក៏ ខ្ញុំអត់បានចូលជាទ័ពទេគឺខ្ញុំនៅជាមួយអភិបាលស្រុកគេ ពីដើមគេនិយាយថាចៅហ្វាយស្រុកនេះ ណា៎! នៅជាមួយគេឲ្យធ្វើជានិរសា ។

បូលី: បាទ! ឈ្មោះអីគេអឹកណៈស្រុក?

សារិនៈ ឈ្មោះ និន ។

បូលី: ចឹងកាលដែលអ៊ីចូលតស៊ូហ្នឹង គឺអត់មានអ្នកនាំទេចឹង?

សារិនៈ អត់! អត់មានទេ គ្រាន់បង តែបងថ្លៃហ្នឹង គាត់និយាយថាមានទិសដៅមួយដែលគេច្រើនទៅ ហ្នឹងទេបើថាចង់តស៊ូ តែបើបងមិនតស៊ូទេ គឺនៅហ្នឹងផ្ទះទៅ ចឹងណា! តែខ្ញុំនឹកឃើញថាឈឺ ចាប់ខ្លាំងណាស់នៅពេលហ្នឹង មានសមាជិក ហើយសមាជិកហ្នឹងមិនដឹងខុសដឹងត្រូវខ្លួនទេ ដោយកំហឹងជាមួយហ្នឹងពួកធៀវគី យួនខាងត្បូងហ្នឹង មានទាំងរថក្រោះ មានទាំងគ្រាប់កាំភ្លើង សុទ្ធអាវុធតែម្តងធ្វើបាបប្រជាពលរដ្ឋជាពិសេសធ្វើបាបឪពុកខ្លួនឯងហើយហ្នឹងសម្ភារការ ។ ខ្ញុំ ក្រ ឪពុកខ្ញុំម្តាយសងគេ!ដោយសាររឿងសម្ភារការទាំងអស់ហ្នឹង យកទៅកិននៅឯវាលស្រែ ។ យកទាំងឆ្នាំង យកទាំងសម្ល ទៅទាំងអស់ ស៊ីហើយយកទៅដាក់កិនគម្រៀបចោល ហើយនៅ សល់តែកង់មួយទេដែលវាអត់កិន កង់ខ្លួនខ្ញុំ ពេលវាត្រលប់ចេញទៅៗបាត់បានទៅយក ។

បូលី: មានហេតុផលអ្វីបានជាខាងកងទ័ពធៀវគីធ្វើចឹង?

សារិនៈ ព្រោះកាលហ្នឹងគេ បើនិយាយឲ្យចំគេថាគេមកគាំទ្រនៅលន់ នល់ ។ ហើយដល់ប្រជាជនតស៊ូ ដើម្បីនេះ លន់ នល់ ទប់! របៀបថាទប់កំលាំងមិនទាន់បានទប់ៗ រួចពីងពាក់ពាក់ពួកនោះឲ្យ អន្តរាគមន៍មកជាមួយ ។ ក្រៅពីនោះ លន់ នល់ និងកម្ពុជាក្រោមនៅក្នុងចក្រពត្តអាមេរិកគ្រប់ គ្រង ដូចនេះវាត្រូវបញ្ជាឲ្យមកចាប់ដៃជួយ សម្រាលដល់ លន់ លន់ ចឹងណា ។ ចលនាបាន ខ្ញុំវិភាគ គិតក្រោយមកទៀតបានដឹង ។ ពីមុនអត់ដឹងទេស្មានតាអាធៀវគីមកឈ្លានពានទៀត ខ្ញុំអត់ យល់ពីកាលហ្នឹងទេពីចលនាគេមុនដំបូង ។

បូលី: ប៉ុនបើជួយគ្នតែមកក្នុងនាមវាយជាមួយហ្នឹងកងទ័ព ម៉េចក៏មកធ្វើបាបប្រជាជនសាមញ្ញចឹង?

សារិនៈ បាទ! អាហ្នឹង គេនេះខ្ញុំអត់យល់ដែរ ប៉ុនកាលពិតមកក្នុងលេសមួយថាមកជួយ ប៉ុនសភាព ការណ៍មកហើយដូចជាមកប្លន់ មកប្លន់តែម្តង ឲ្យតែជំពូកតែអ្នកមានគឺអាសន្នតែម្តង បើអ្នក មានគ្រាន់ បើគឺអាសន្ន ។ ដូចនេះបានជាគេដាក់មកគឺថាផ្នែកយោធាមកគាំទ្រផងគឺឱកាសគេ ហ្នឹងទៅជាប្លន់ ចាត់ទុកជាតំបន់នៅក្រៅទីប្រជុំជននៅក្រុងហ្នឹង ទៅជាគូរសត្រូវជាមួយ លន់ នល់ ។ បានជាចលនាតស៊ូហ្នឹង វាលឿនមូលហេតុចឹងឯងនៅជនបទ ជាកម្លាំងទាំងអស់វាទៅ

ជាចូលតស៊ូដោយស្ម័យប្រវត្តិដោយសារឿងចឹងណាស់ ។ ដូចជាខ្ញុំសមាជិក ខ្ញុំអត់មានទាក់ជាមួយប្រព័ន្ធនៃកាសិក្សា គឺវានៅការសិក្សាប៉ុន្តែដល់ពេលចឹងបានសម្រេចិត្តទៅតស៊ូ ដោយស្ម័យប្រវត្តិខ្លួនឯងចឹងគេថាចូលរួមតស៊ូដោយស្ម័គ្រចិត្ត អានេះយើងគិតចឹងណាស់ ។

បូលី: បាទ! អ៊ីរៀនដល់ថ្នាក់ទីប៉ុន្មានដល់ពេលចូលតស៊ូ?

សារិនៈ ខ្ញុំរៀនថ្នាក់ទី៣ ពីសង្គមចាស់ ។

បូលី: ចឹងបានន័យថាទី១០ឥឡូវ?

សារិនៈ បាទ!

បូលី: ខ្ពស់!

សារិនៈ អត់ទេ! ទី១២ ។ ស្មើរនឹងទី១២បច្ចុប្បន្ន ។

បូលី: បាទៗ! ទី១២ពីដើមបានន័យថា?

សារិនៈ ទី៣ពីដើមគឺថាប្រលងចូលឌីប្លូមចេះមក ប្រលងចូលធ្វើការងារ ធ្វើគ្រូ បាទៗ! ចឹងប្រវត្តិសាស្រ្តខ្ញុំនឹងគឺដោយសារអាណិតព្រោះឪពុកម្តាយគាត់ស្លាប់ណា ដល់ផុតរឿងហ្នឹង ខ្ញុំមិនតស៊ូបានជាខ្ញុំ ចូលមកនេះគឺទៅជួបហ្នឹងមុខ និន ហ្នឹង ហើយគាត់ក៏ឃើញ ក៏យកធ្វើជានិរសានិរសាក្នុងស្រុកហ្នឹងពីឆ្នាំ៧០និង ៧១ ។ មួយសម្រេចចិត្តថាមកផ្ទះវិញមិនដឹងជាពឹងអី ទី២នៅជាមួយគេនេះ ខបសគ្គប្រចាំថ្ងៃទីបើកភ្នែកឡើង គឺត្រូវតែចលនាអាពួកអាធៀវគីនេះហើយហ្នឹងទាហានលន់ នល់ ហ្នឹងធ្វើបាប រុករើ និយាយពីថារថក្រោះផង ថ្មើរជើងផងហើយកម្លាំងយើងតូច កម្លាំងយើងតិច យើងមានការរត់ពួនគេចវេសរហូត ។

បូលី: គេចម៉េចទៅអ៊ុំ គេចនៅលើភ្នំព្រៃ កំពូតឬក៏?

សារិនៈ បានចូលព្រៃនៅលើភ្នំចឹងទៅ សម្ងំទាល់តែគេដកយុទ្ធនាការឲ្យយើងចុះមកវិញជួបហ្នឹងប្រជាជនទៅប៉ុណ្ណឹងទេ ។ ដល់តែពេលក្នុងនោះក៏មានទៀត គេហៅថាមានចលនាកងទ័ព គេហៅពួកយៀកកុង យុទ្ធភូមិនេះណាស់ ប៉ុន្តែឡើងមកហ្នឹងជាអន្តភាព ប៉ុនខ្ញុំមិនស្គាល់ទេ ចាត់ទុកថាយួនមិនយួន អាណាក៏យួនដែរកាលហ្នឹង ដល់ចឹងទៅកាលហ្នឹង ប៉ុនដល់ហើយទៅគេយួនក៏ប្រឆាំងធៀវគី ដូចនេះគេបាននៅនោះផ្សេង ឯយើងនៅនេះផ្សេង ប៉ុនពេលដែលធៀវគីពេលឡើងមក ប៉ះគ្នា វាយគ្នាចឹងទៅណាស់ ។ ឯពួកខ្ញុំនេះគ្មាននកម្លាំងវាយទេ កម្លាំងប្រដាប់វុធកាលហ្នឹងមាន អាវុធអី មានដូនកាលកាំភ្លើង CKC មួយដើម ពីរដើមចឹងទេ ហើយធ្វើជានិរសាចលនា ប៉ុន្តែក្រោយមកពួកខ្ញុំទទួលនិរសារឆ្លងកាត់ទៅដល់តំបន់កំពត បើគេនិយាយគឺថាជាអ្នកដឹកនាំតំបន់ នៅខេត្តណា ។

បូលី: តំបន់៣៣?

សារិនៈ បាទ! តំបន់៣៣ ប៉ុន្តែខ្ញុំលំបាកគ្នាបីនាក់ហ្នឹង ជួនកាលដើររយៈ៥ថ្ងៃទៅ១អាទិត្យបានដល់ ។

បូលីៈ ពីណាទៅណា?

សារិនៈ ពីស្រុកអន្លង់វែងទៅដល់ជិតរោងចក្រ ចក្រីទីង រោងចក្រស៊ីម៉ង់ ខេត្តកំពតណា ព្រោះតំបន់គេនៅកន្លែងហ្នឹង ប៉ុន្តែខ្ញុំអត់ដឹងភូមិសាស្រ្តស្អីៗ ប៉ុន្តែក្រោយមកបានដឹងថាមុំជាប់នៅភ្នំវល្លិ៍ ភ្នំអីហ្នឹងណា ។

បូលីៈ អូ៎! បានន័យថាមូលដ្ឋានធំនៅក្នុងតំបន់៣៣ហ្នឹង គឺនៅក្នុងរោងចក្រហ្នឹង?

សារិនៈ ឯខ្ញុំគឺនៅក្នុងភ្នំសែនហា ភ្នំស្រមោចនេះ ខាងនេះភ្នំដំរីរមៀល បានថានារាយណ៍ នៅភ្នំក្រោមនេះទៀត ។ ដូចនេះហើយដើរឆ្លងកាត់នេះ នាំសារនាំសំបុត្រទុក រាយការណ៍គេនៅហ្នឹងទៅ ។

បូលីៈ បាន័យថាអឹជានិរសាតំបន់ ឬ?

សារិនៈ និរសាស្រុក ។

បូលីៈ ស្រុកអន្លង់វែង?

សារិនៈ បាទ! ស្រុកអន្លង់វែង ។ ចូលទៅក្បែរហ្នឹងហើយដល់ក្រុងកែបចឹងណា! នាំសារខបសគ្គជាពិសេសខ្លាំងជាងគេមុំភ្នំអន្ទង់ ឥឡូវគេហៅថាតំបន់គេយកអាចម៍ក្រចៀវនោះ បាននៅក្រោយភ្នំអន្ទង់ គឺសត្រូវច្រើនតែស្ទាក់នៅកន្លែងហ្នឹងដែលខ្ញុំជួបខបសគ្គខ្លាំងជាងគេ នៅកន្លែងហ្នឹងគឺថាគ្រប់ជើង សឹងថានេះ ប៉ុន្តែពួកខ្ញុំចេះតែគេចរួចប្រយុទ្ធ ។ ជួនកាលកុនមែនទែនចូលទៅក្នុងសំបុកវាណា ។ បាញ់មកៗ ងាប់ក៏ងាប់ទៅ បាញ់ៗទៅចេះតែខបសគ្គទៅ យើងបាញ់ងាប់ចឹងទៅយើងរត់ចឹងទៅគេចេះតែដេញធ្លាក់ទឹកធ្លាក់ភក់ឆ្លងស៊ីងរួចទៅ ក៏រួចទៅ នេះបញ្ហាប្រវត្តិដើម ។ ដល់ក្រោយមកទៀតបានអភិបាលស្រុកឈ្មោះ និន ហ្នឹង គេឲ្យទទួលខុសត្រូវឈ្លប ។ ឈ្លបឃុំសំណាយ ស្រុកអន្លង់វែងហ្នឹង កម្លាំង២០នាក់ ប៉ុន្តែខ្ញុំហ្នឹងដឹកនាំប្រយុទ្ធ រៀបចំធ្វើការនៅក្នុងឃុំនឹងផង ដឹកនាំប្រយុទ្ធជាមួយហ្នឹងទាហាន លន់ នល់ ហ្នឹងផ្សារតានីហ្នឹងចុះមករាតត្បាតម្តងៗហ្នឹងណា ហើយទៅវាយ ទៅបោកគ្នានៅគ្រប់ឃុំជាមួយគ្រប់កង ស្រុកហ្នឹងទៅវាយ ។ ថៃដន្យថ្ងៃមួយខ្ញុំដឹកនាំកម្លាំងទៅវាយ ហើយខ្ញុំវគ្គផ្លូវជាតិ កម្លាំងទាំងតែ៩នាក់ទេ ស្លាប់កម្លាំងខ្ញុំអស់៥នាក់នៅសល់តែ៤នាក់ ។ ២នាក់របួសហើយខ្ញុំហើយម្នាក់ទៀតនៅល្អ ហើយយកអ្នករបួស ប៉ុនអ្នកស្លាប់៥បាត់ ។ អាហ្នឹងបូកលន់ នល់ ផង បូកធៀវគីផង ហើយយុទ្ធនាការទឹកធំឡើង ហើយកម្លាំងពួកនោះវានៅ បានវាឡើងមកបូកដល់ចឹងទៅមកត្រឹកក្រាក់ គេអត់ស្គាល់ផ្លូវ១០៥ ហើយថា(ស្តាប់ពុំបាន)វាអត់ត្រូវទេ វាចេញមកម្តងៗលេង១០ដើម ធ្លាក់ម្តងៗ ៣០ឬ ៤០គ្រាប់នោះអត់ដឹងទេ ។ ស្លាប់ពួកខ្ញុំ៥នាក់រហូតដល់នេះខ្ញុំគ្រាន់តែជម្រាបថាត្រូវរបួសដែរ ប៉ុនគ្រាន់តែថារបៀបប៉ះទង្គិចចឹងណាក្បាល

ធ្វើឲ្យខ្ញុំចេញផុតពីសមរភូមិ ហូរឈាមតាមត្រចៀក តាមមាត់អស់ហើយខ្ញុំសន្លប់ៗ សន្លប់ទី១ដោយសារស្ទុតដោយសារមិត្តភក្ត្រស្លាប់ផង ទី២ដោយខ្លួនឯងហ្នឹងការឈឺចាប់ចឹងផងៗ ដល់ចឹងផង គេយកទៅពេទ្យរហូតដល់ ខ្ញុំជាព្យាបាលតំបន់១៣ហ្នឹង ហៅថាតំបន់តាកែវហ្នឹងៗ តំបន់១៣ ហ្នឹងមានតាសោម ឈ្មោះតាសោម ប៉ុនជីតាខ្ញុំអត់ដឹងទេ! តាមុត គាត់គណៈតំបន់ហ្នឹង ហើយតាផែនខ្ញុំដឹង ដល់ចឹងគាត់ ចុះមកលេងមកអី យកថ្នាំយកអីជួយ ព្យាបាលដល់ខ្ញុំជាបានរៀបចំខ្ញុំឡើងជាគ្រប់គ្រងអនុសេនាធំកងស្រុកអង្គជ័យ ។

បូលី: ប៉ុន្មាននាក់អ៊ឺ?

សារិន: ខ្ញុំបួនអនុសេនាតូច មួយអនុសេនាធំៗ គេមានតែ៣ទេ ដល់រៀបទៅ៤អនុសេនាតូចខ្ញុំគ្រប់គ្រងៗ ដល់ចឹងគេចាត់តាំងខ្ញុំទទួលខុសត្រូវវាយខាងភ្នំនៅសន្ទុង ទីតាំងទាហានលន់ នល់ នៅភ្នំសន្ទុង ហើយកងតំបន់ កងអីគេវាយខាងនោះ គេស្ទាក់ផ្លូវជាតិលេខ២ វាយអមហើយខ្ញុំស្ទាក់អាផ្លូវហ្នឹងហើយឲ្យនវាយអានោះតាឯង មួយកងស្រុក វាយតែឯងៗ ខែ៨វាទឹកធំឡើងចូលទៅមុនដំបូងទឹកចេញទេ ដល់ពេល២ ទៅ៣យប់ស្រាប់តែទឹកតាមនេះៗ ចូលក្តាប់បញ្ហាដល់ ចូលដល់ទឹកតាមនេះ កន្លែងខ្លះហែល ដល់ចឹងបន្ទុំចិត្តថាត្រូវតែវាយខ្មាំងក៏ចេញពុំរួចទាល់តែយើងទៅវាយ ទៅវាយហើយ ខ្ញុំវាយបានថាស្ទុងស្ទាប វាយហើយដក ដល់លើកទី២បាន ខ្ញុំចូលដឹកនាំកម្លាំងវាយផ្ទាល់ៗតែម្តងៗ ទៅវាយហ្នឹងគឺចាប់ពីវត្តហ្នឹងវាយស្ទាក់ផ្លូវ បិទផ្លូវវាយ ផ្តាច់ទាក់ផ្លូវតែម្តង វាយបិទមួយយប់តែម្តង ស្រាប់តែយប់ព្រលឹមឡើង គឺសត្រូវបាក់ៗ បាក់គឺ រត់ជាន់ពួកខ្ញុំហ្នឹងពាំងផ្លូវហ្នឹង គឺបាញ់គ្នារត់កាត់ចឹងទៅ យើងរំដោះបាន រំដោះបានទីតាំងហ្នឹង កាលហ្នឹង អាវុធកងស្រុកមានអីទំនើប កាលហ្នឹងបានអស់ខ្ពស់ហើយត្រឹមCKC ហើយហ្នឹងច្រើនតែការ៉ង់អង(quarante-et-un) និងត្រង់ស៊ីស(trentesix) ក្នុងស្រុកណាជំនាន់ហ្នឹងអាវុធ នៅក្រ វាយពុំទាន់បានទេ បានរំដោះទេដែលបានអាវុធដូរៗ អាវុធមាន៨០ មាន៦០ ហើយរហូតដែលថា មេទីយ៉ែរត្រង់(Moitié trente) មេទីយ៉ែរ៣០ហ្នឹងណា៎ ហើយបាន(ស្តាប់ពុំបាន) គឺមកទាំងអស់ៗ យកមករៀបកងខ្លួនឯង អាវុធចាស់ប្រគល់ឲ្យទៅស្រុកវិញ បានបំពាក់ខ្លួនឯងហើយបានអាវុធបីរទេះក្របីទៀត បាទ! យើងដេញទៅនិយាយ ពីចាប់នៅឯនោះ យើងស្ទាក់ដល់កំពង់ជ្រៃ ដល់ចឹងទៅស្ទាក់បាននៅអាវុធបីរទេះក្របីហ្នឹង បានដឹកមកមានកងថា កងតំបន់ហ្នឹង ស្ទាក់វាយដណ្តើមគ្នាវាយអស់មួយរទេះដណ្តើមគ្នាឯងៗ ប៉ុន្តែពួកខ្ញុំអត់តទេ ប៉ុនគ្រាន់តែគេចថាយកក៏យកទៅចុះយើងតែ២រទេះក៏មករៀបចំដកអាវុធណាដែលល្អទៀតដែលយើងបានទៅហ្នឹងដូរបានថ្មីទាំងអស់ហើយ បានសល់ប៉ុន្មានដាក់រទេះជូនទៅស្រុកស្រុកគេ បញ្ជូនទៅតំបន់ទៅ អាវុធគេរាយការតាមហ្នឹង ហើយសភាពការណ៍ហ្នឹងខ្ញុំរស់បានតែ

មក សមរភូមិហ្នឹងទេ ចប់បិទសមរភូមិបូកហ្នឹងដេញគ្នាដល់ធ្លាក់ព្រំដែនយួន អូនឯងស្គាល់ទេ ភ្នំដិន គេហៅថាយុថ្កាហ្នឹងហើយ ខាងកើតទន្លេបហ្នឹង ទៅយុថ្កា ក្រពុំឈូក ទៅដល់ហ្នឹង ពួកខ្ញុំដេញដល់ហ្នឹង ។

បូលី៖ ដេញពីណាអ៊ី?

សារិន៖ ដេញពីតាំងពីស្រឡុងនោះមកកំពង់ត្រឹ ចឹងធ្លាក់ទៅអន្ទក់ ចឹងទៅធ្លាក់ទៅដូង ទៅបេះទៅក្រពុំឈូក ធ្លាក់ទៅកំណប់ ដល់អានោះដេញទៅធ្លាក់យុថ្កា ។ ដល់កន្លែងហ្នឹងប្រគល់ភារកិច្ចឲ្យកងស្រុកកោះអណ្តែកគេហ្នឹងទៅ ក៏ពួកខ្ញុំត្រលប់មកវិញដកកម្លាំងមកជួបជុំគ្នានៅទីផ្សារកំពង់ជ្រៃនេះ ។ ផ្សារកំពង់ជ្រៃរៀបរយកម្លាំងហ្នឹងហើយ បានខាងស្រុកខាងអីគេចុះមក ទៅដឹកសម្ភារចំណីចំណុកជាការឧបត្ថម្ភប្រជាជនប្រគល់ឲ្យទ័ពហូបចុកជប់លៀងណា ខាងជ័យជំនះអាវុធអីចឹងទៅបេះទុកដាក់ខ្លួនឯងហើយណាស់ ដល់ចឹងទៅអង្គភាពខ្លួនឯងដូចថា ឧទាហរណ៍ថាមាន ១៥ នាក់នៅជាមួយយើងហ្នឹង មានអាវុធ១៥ដើមទុកទៀតការពារ ហើយគេអង្គភាពនោះក៏គេទុកដែរ ហើយខូចខាតអីដោះដូរភ្លាមៗ ចឹងណាអាណាខូចបញ្ជូនមក ដល់គេបេះតែមានគំនិតចឹងអត់មានបាន១អាទិត្យទេ ស្រាប់តែខាងតំបន់គេរៀបរយទៅជាកង ខ្ញុំឡើងទៅជាកងតំបន់បានសារ៉េទាំងបួនអានុសេនាតូច មករៀបទាំងបីអានុសេនាតូចទេ ហើយឡើងទៅកងតំបន់រួចកងតំបន់ខ្ញុំដាច់(ស្តាប់ពុំបាន)ពីតំបន់ ។

បូលី៖ តំបន់១៣ ។

សារិន៖ បាទតំបន់១៣ហ្នឹង ។

បូលី៖ អនុសេនាធំលេខប៉ុន្មានអ៊ី?

សារិន៖ អនុសេនាធំខ្ញុំកាលហ្នឹង២៤ ។

បូលី៖ ២៤?

សារិន៖ បាទ!

បូលី៖ ពេលហ្នឹងមានរៀបកងពលនៅអ៊ី?

សារិន៖ អត់មានទេ! ពេលហ្នឹងខាងគេតំបន់គេគ្រប់គ្រងមានតែថាមេបញ្ជាការកងតំបន់ ហើយអត់ទាន់វរសេនាតូចវរសេនាធំទេ ជាអនុសេនាធំប៉ុនមានមន្ទីរបញ្ជាការរួមមួយ ដែលបញ្ជាការតំបន់ណាស់ កាលនោះអត់ទាន់មាន ខ្ញុំអត់ស្គាល់ទេ អត់ដឹងវរសេនាតូចទេ ដឹងតែអនុវរសេនាធំទេហ្នឹងទេ ។ ដល់ចឹងអានេះខ្ញុំនិយាយដាក់ស្តែងណាស់! ដល់ពេលប្រយុទ្ធចូលទៅ ចូលបានមួយថ្ងៃ ចូលទៅសមរភូមិ គេឲ្យទៅដាច់ស្រយាលទៀតទៅ ចាប់ពីគេថាអាជ្ញវត្តអីគេហ្នឹង វត្តអំពិល វត្តអំពិលហ្នឹងធ្លាក់ទៅដល់ក្បាលប៉ូលឲ្យសុទ្ធតែពួកដើងទឹកទាំងអស់ ហើយពួកខ្ញុំសុទ្ធតែ

ក្មេង ហើយការពិតនិយាយឲ្យត្រង់ទៅស្ពាយកាំភ្លើងនៅអូសស្មៅ ក្មេងៗ! ហើយពេលឡើងទៅ ដល់ពេលព្រលឹមចូលដើររៀបមើលភូមិសាស្ត្រចឹងរៀបត្រង់សេដីក យប់ឡើងដីកត្រង់សេទៅ ដីកត្រង់សេ ព្រលឹមឡើងខ្ទាំងចុះដាន់ៗ

បូលីៈ ខាងណា ខាងលន់ នល់ ឬធៀវគី?

សារិនៈ ខាង លន់ នល់ហ្នឹងចុះមក ចុះមកដាន់ព្រឹប គិតទៅទាហាន លន់ នល់ប្រហែលទ្រង់ជា២០០ ដាងដែលចុះហ្នឹង ចុះហ្នឹង៣មុខសញ្ញា ប៉ុនប៉ះពួកគេអីដើមដៃនោះតែខ្ញុំចុងនេះ វាមកទាំងដុំមកបណ្តោយ គេហៅថាបើទិសដៅបើវាយបាក់ចុងនេះទៅវាទៅព័ទ្ធពួកយើងអីនោះ ប៉ុនមកប៉ះពួកខ្ញុំក្មេងនេះ វាទើបតែឈ្នះដេញផងក្លាហាននោះ ប៉ុនដល់ប៉ះឈុល បាញ់ឈុលគឺវារត់ចូលតែម្តងរត់សម្រុក ។

បូលីៈ ក្មេងៗ ហ្នឹង!

សារិនៈ បាទ! អត់បញ្ហាទេ! ខ្ញុំអត់បានបញ្ហាទេ គ្រាន់តែប៉ះឈុលវាឡើងបុកទាហានបាក់រត់ ដេញៗបាក់ដល់ក្បាលប៉ូល អីទាំងអស់រត់ ភ័យរត់ក៏ឈ្នះពេលហ្នឹង យកអីទុកអីទេ ។ ដល់ក្បាលប៉ូលបើស្រាវិញ អាស្រាក្បាលប៉ូល ស្រាបិតអង្គរក្រហមមិនសូវគ្រួសនោះ អាងហែល សុទ្ធតែស្រា ហើយអាស្រាវាមិនទាន់កាច់នោះ និយាយពីអាងមិនដឹងជាយកទៅណានោះទេ ហើយអាស្រែះៗនោះទម្រាបពេញៗទាំងអស់មិនដឹងជាយកទៅណា ហើយមួយទៀតបើនិយាយពីរឿងប្រជាជននៅហ្នឹងសុំទៅ ចេញចឹងទៅមានរទេះគោរទេះក្របីមានអីយកដឹងទៅ ហើយពួកខ្ញុំអត់មានអីទេទៅមុខ ប៉ុនត្រលប់មកវិញនៅឃើញប្រយ័ត្នយន្តហោះ ហើយកាំភ្លើងធំអីគេផ្ទោងត្រូវងាប់ណា គាត់ចេះចេញមកក្រោយទៅ ហើយត្រលប់ដល់នោះហើយស្អីមិនអស់មកវិញទៅចឹងណា ។ ដល់ព្រៃរុនបានថាប្រវត្តិសាស្ត្រក្នុងខេត្តតាកែវ ខ្ញុំដល់ទៅឃើញនៅភូមិព្រៃរុនដែលជាប់នៅខេត្តតាកែវ បានដឹងថាភូមិហ្នឹង ទីក្រុងតាកែវអត់ដល់ទេ គឺកំពូលអ្នកមាននៅព្រៃរុនហ្នឹងព្រោះអីគេនេសាទក៏នេសាទ ស្រូវប្រាំងក៏ស្រូវប្រាំង ស្រូវវស្សាក៏ស្រូវវស្សា ហើយជង្រុកគេចឹង ៦ម៉ែត្របណ្តោយ៨ម៉ែត្រ ផ្ទះមួយៗខ្លះមានដល់២០ម៉ែត្រនោះបណ្តោយជង្រុកដាក់ពេញៗសុទ្ធតែស្រូវ ហើយគមិនដឹងជាយកទៅណា ប៉ុន្តែគិតទៅខ្ញុំចប់ទៅខ្ញុំវាយចូលចឹងទៅបានវាយបាននេះទៅ ទៅវត្តមិនដឹងទេខ្ញុំភ្លេចអាវត្តនៅហ្នឹង ដល់ចឹងទៅបានចូលទៅក្នុងក្រុងដល់វាយក្នុងក្រុងបានខ្ញុំត្រូវរបួស ។

បូលីៈ ក្រុងភ្នំពេញ?

សារិនៈ អត់ទេ! នៅក្រុងតាកែវណា ។ ចូលក្រុងតាកែវដល់ផ្ទះថ្ម ផ្ទះផ្លូវនៅក្បាលប៉ូលហ្នឹង ហើយចូលទៅក្នុងទៀតចូលទៅដល់ក្នុង គេហៅបន្ទាយស៊ុប បន្ទាយស៊ុបខេត្តគេនោះ ដល់ចឹងទៅខ្ញុំ

ត្រូវរបួស វាបោកគ្រាប់បែកពីលើផ្ទះមក ឯខ្ញុំហ្នឹងកំពុង! ប្រវត្តិសាស្ត្របានកាំភ្លើងអាកាមួយដើម និងដាវនៅព្រៃរុនហ្នឹង បានដាវបុរាណមួយ ដាវទាំងស្រោមស្ពាយទៀតណា៎ នៅផ្ទះតាហ្នឹង ហើយគាត់ចេញគាត់អីទៅ គាត់ប្រគល់ដាវឲ្យ ដាវហ្នឹងដកកាត់ល្ហួសបន្លាយើងវាធ្វើនេះហ្នឹង ហើយដាក់ភ្លើង កាប់មួយប្រាវចឹងដាច់ពីរខ្សែ ដាវហ្នឹងហើយអត់មានឆែបមានអីទៀតដាវ ហើយកាប់ដីក ហើយតំបន់រស់នៅនេះយើងចូល ដល់ចូលទៅវាបោះគ្រាប់បែកពីលើត្រូវរបួស ត្រូវរបួសធ្ងន់ណាស់កាលហ្នឹង ហើយដល់ចឹងទៅបាននិរសាខ្ញុំ ពាក្យថានិរសាពីដើមណា ហើយនិរសាខ្ញុំហ្នឹងនៅមាត់ទឹកហ្នឹង កន្លែងការពារបិទកន្ទុយហើយកម្លាំងចូលវាយនេះ ដល់នេះ ពួកនេះបាត់បោកគ្រាប់បែក ក៏ត្រូវរបួសម្នាក់ ឯខ្ញុំត្រូវរបួសធ្ងន់ បានខ្ញុំបេះវាលូនមកហើយ ហែកយកអាក្រម៉ាជូតក្បាលប៉ាវ៉ាហ្នឹង រុំ រុំហើយបេះតែលូនៗដៃ ហើយជើងងាប់ទាំងអស់ ហើយត្រូវដល់ចឹងទៅលូនដៃចាប់ផង ហើយកាំភ្លើងផងបេះតែលូនៗដល់ជួបទៅ គេនាំដាន នាំទៅដល់ឯនោះបានអង្គុយចាំនៅកន្លែងហ្នឹង បានតិចឃើញបាត់បានឲ្យពួកអានេះទៅតាមមកយកខ្ញុំចេញ ។ ខ្ញុំស្មានតែស្លាប់នៅហ្នឹងហើយមូលហេតុគ្រាប់កាំភ្លើងងើបអត់បានដូចគ្នា ហើយ បានមកដល់វត្តហ្នឹង ហែកខោអាវកាត់ចោលទាំងអស់ហែកស្បង់ជីពហ្នឹងរុំ ខ្ញុំនិយាយពីទាំងអស់ រុំស្បង់ជីពហែកមករុំរបួសបណ្តោះអាសន្ន ហើយគេចាក់ថ្នាំចាក់អីគេសែងចេញបាត់ មកបានដី ប្រហែលជា១គីឡូសន្ទប់ រហូតមកដល់ពេទ្យមូលដ្ឋាននេះ បានខ្ញុំដឹងខ្លួន ។

បូលី: ពេទ្យតំបន់១៣?

សារិន: បាទ! ពេទ្យតំបន់១៣នៅមន្ទីរពេទ្យក- ណា ។

បូលី: ប្រធានមន្ទីរពេទ្យ ពីណាគេ?

សារិន: កាលហ្នឹង ឈ្មោះ ស៊ីៗ ។ គាត់គ្រប់គ្រងកាលហ្នឹងតាស៊ីណា ប៉ុន្តែគាត់ព្យាបាលខ្ញុំជាទៅបានខ្ញុំជួបជាមួយហ្នឹងប្អូន បានកូនតានិន ហ្នឹងទៅហៅប្អូនៗសេរី គេមកធ្វើពេទ្យនៅហ្នឹងជួប! ជួបទៅក៏គេទៅហ្នឹង មើលថែតាមវេនគេហ្នឹង ប៉ុនពេលណាគេអត់វេនគ្នាទៅ ក៏ទៅតាមទៅ តាមគេចាត់តាំងគេកាលហ្នឹង ប៉ុន្តែយប់ឡើងមកចឹងទៅ ទៅភូមិទៅតាមអីចឹងបានខ្ចប់យកមកឲ្យបងហូបអីចឹងទៅ ។ ដល់ខ្ញុំជាខ្ញុំត្រូវ ត្រូវមុនដំបូងខ្ញុំគិតថាខ្ញុំត្រូវរបួសសុទ្ធតែសាច់មែន ប៉ុនត្រូវធ្ងន់ជាងគេ ជើងខ្ញុំនេះត្រូវកាលជំនាន់ហ្នឹង ត្រូវដាច់សរសៃ អ៊ំអត់ដាច់ទេឈាមខ្មៅ ឈាមក្រហមហ្នឹង គឺវាត្រឹមពាក់កណ្តាល វាដាច់ទាំងសងខាងវាចូល ដល់ចឹងវាឆ្លងគ្នា ។ រីតៗទៅចឹងទៅហើយដល់ចឹងជើងខ្ញុំប៉ះ ក្រោយពីជារបួសហ្នឹងហើយ អានេះអត់ទាន់ជាទេ មានអាពេទ្យហ្នឹងវាលាងដាប់សំលី ដល់ហើយវារបូតសំលីនៅហ្នឹង អត់ជា! បេះអត់ជាបេះតែខ្ទុះចេញ ដល់

ចេញមកៗចាប់ចេញបានលាងទៅជាដាច់ ប៉ុនជាដាច់ជើងខ្ញុំដើរអត់កើតគឺជំពប់ ស្អិតចហ្នឹង ដួលព្រោសតែម្តង ជើងហ្នឹងឆ្វងវាទៅជាស្ពុត ។

បូលីៈ ប៉ុន្តែ អត់ទាន់ដាច់ទេ?

សារិនៈ នេះទាន់ដាច់ទេ!

បូលីៈ ខាងក្រោយមកនេះទេ! អានេះនោះ?

សារិនៈ នេះ! ពិការលើកទី៣បានដាច់ ដល់លើកទី២ពិការទៀត ត្រូវជើងហ្នឹងដែរវាត្រូវនេះស៊ិតជើងហ្នឹងម្តងទៀត ម្លោះហើយធ្វើចលនានេះ ប្រវត្តិសាស្ត្រដល់ពេល៧៥នេះ ថ្ងៃ១៧! ថ្ងៃ១៥ គឺខ្ញុំត្រូវរបួស មុនហ្នឹងរំដោះ ។

បូលីៈ ១៥មេសា?

សារិនៈ បាទ!

បូលីៈ ២ថ្ងៃ?

សារិនៈ មុនហ្នឹងរំដោះ២ថ្ងៃ ខ្ញុំទៅដល់ពេទ្យ២ថ្ងៃ នៅអង្គស្នួលបែកចាននេះ វាយចូលភ្នំពេញ ។

បូលីៈ ខ្ញុំសូមបកក្រោយតិចអ៊ុំ ពេលដែលអ៊ុំថានៅតំបន់១៣ហ្នឹងមានក្រុមគណៈមេបញ្ជាកាធំមួយដែលគ្រប់គ្រងយោធាទាំងអស់ អ្នកណាប្រធានកាលនោះអ៊ុំ?

សារិនៈ កាលហ្នឹងឈ្មោះ សុច! ឈ្មោះ កប! កបហ្នឹង នយោបាយ សុចគឺ(ស្តាប់ពុំបាន) ប៉ុនជីតាខ្ញុំដឹង ដឹងតែឈ្មោះណា ដល់មានសឿនមួយទៀត សឿនហើយនិង កប ហ្នឹង សិទ្ធស្មើគ្នា គ្រាន់តែសឿនហើយហ្នឹងសុច គឺបញ្ជាកាដូចគ្នា ប៉ុនបែកទិសផ្នែកនេះមួយៗ ប៉ុន កប គេអ្នកនយោបាយ តែអ្នកគ្រប់គ្រងលើហ្នឹងមានតំបន់១៣ហ្នឹង មានតាមុត តាសោម តាផែន ចឹងទៅ នេះខ្ញុំដឹង ប៉ុន្តែការរៀបចំក្រោយពីហ្នឹង ខ្ញុំវាយនៅហ្នឹងបានក្លាយខ្លួនមកវាយកងតំបន់ហ្នឹងគឺរៀបទៅជាមានវរសេនាតូចហើយ រៀបជាកងតំបន់មានជាវរសេនាតូច ទី១៣វរសេនាតូច ១២, ១៤នែក! ដល់ពេលចឹងខ្ញុំនេះវរសេនាតូច៤០៦ ។ ៤០៦ វរសេនាតូចខ្ញុំហ្នឹងតំបន់១៣ហ្នឹង ហើយជាអនុសេនាធំ ខ្ញុំធ្វើបានតែឡើងតែតំបន់បានតែមួយខែទេ គេរៀបតំបន់ទៅជាបញ្ជាការងណ៌ គេថាមានអ្នកបញ្ជា ហើយអនុបញ្ជាហ្នឹង មួយផលនោះជានយោបាយឈាងនេះជាបញ្ជាកា ខ្ញុំជាបញ្ជាការងចឹង! ប៉ុន្តែខ្ញុំគ្រប់គ្រងមួយអង្គភាពខ្ញុំ២៤ហ្នឹងរហូត ខ្ញុំអត់ចេញទេ ឯណាបែកគ្នាក៏បែកទៅតែខ្ញុំប្រាប់តែអង្គភាពរុញវាយហ្នឹង វាយនៅវាយបានតាំងពីឫស្សីជ្រុំ វាយរំដោះមកដល់ចំបក់ អូរចំបក់ដែលហៅថាបន្ទាយទាហានអូរចំបក់ពីដើមនោះអាផ្លូវបំបែកពីរហ្នឹង អាផ្លូវបំបែក ផ្លូវជាតិលេខ២ហ្នឹង ខ្ញុំវាយដល់ហ្នឹង រំដោះ អ៊ីចឹងហើយទៅ

បានដក់សមរភូមិដកយុទ្ធនាការសមរភូមិនៅភ្នំពេញ ។ នៅភ្នំពេញ គេដកកងខ្ញុំហ្នឹង មកចូលកង ពលទី២ ។

បូលី៖ របស់ភូមិភាគនិរតី?

សារិន៖ របស់ភូមិភាគនិរតី ។ កាលហ្នឹងក្រោមអ្នកដឹកនាំឈ្មោះតា ប៊ិត ។

បូលី៖ សំ ប៊ិត?

សារិន៖ សំ ប៊ិត! គាត់!

បូលី៖ និរតី កាលហ្នឹង គាត់មានប៉ុន្មានកងពលអឺកាលហ្នឹង?

សារិន៖ និរតី ការពិតមានតែកងពលទី២ ហ្នឹងតែមួយទេ ។

បូលី៖ មានតែមួយកងពលទេអី?

សារិន៖ មានតែមួយកងពលនេះទេ ក្រៅពីនេះសុទ្ធតែកងពលភូមិភាគពិសេសនេះទេ ប៉ុន្តែមួយកងពលហ្នឹង គឺថាគេជាភូមិភាគ ប៉ុន្តែកងតំបន់ គ្រប់តំបន់ទាំងអស់មួយបូក ជួនកាលមួយវរសេនាធំៗ កម្លាំងច្រើនណា ប៉ុន្តែចប់ភារកិច្ចគេទៅតំបន់គេវិញ ប៉ុន្តែកងពលនោះ៤វរសេនាតូច អ៎៤វរសេនាធំហ្នឹងវរសេនាធំ១១,១២,១៣,១៤ ។

បូលី៖ ហ្នឹងកងពលទី២?

សារិន៖ កងពលទី២ ប៉ុនមួយវរសេនាធំ ហ្នឹងគឺកម្លាំងពេញៗណា ។

បូលី៖ មានវរសេធំ?

សារិន៖ ១១,១២,១៣ និង១៤ ។ ឯ១៣នេះខ្ញុំភ្លាប់អត់បានអ្នកដឹកនាំ ព្រោះអន្តភាពមួយហ្នឹងច្រើនតែចល័តទៅខាងកោះកុង ដល់ចឹងគាត់១១នេះ នែក តាវ៉ែន ។

បូលី៖ អុង វ៉ែន ហ្នឹងមែន?

សារិន៖ មិនមែនទេ! មិនមែន អុង វ៉ែនទេ ។ វ៉ែន កូនប្រសារតាម៉ុក ។ តាវ៉ែនហ្នឹង បើ១២នេះ ខាងតាវិន ។

បូលី៖ កូនប្រសារតាម៉ុកដែរ?

សារិន៖ ហ្នឹងហើយ! កូនប្រសារតាម៉ុកដែរ ។ ដល់១៤នេះ តាសឿន ហៅតាសឿនរថក្រោះអន្លង់វែងនោះ ។

បូលី៖ តាសឿន រថក្រោះ?

សារិន៖ ហ្នឹងហើយ! តាសឿន រថក្រោះហ្នឹងចេញពីតំបន់តាកែវមក១៣ទាំងអស់ ។

បូលី៖ ចុះ១៣?

សារិនៈ ១៣នេះ ខ្ញុំអត់ក្តាប់បាន មិនដឹងអ្នកណាអ្នកទទួល កាលហ្នឹងវាមិនសូវទំនាក់ទំនងអីជាមួយនេះ ដាប់ប៉ុន្តែ!

បូលីៈ យ៉ាងម៉េច គេខាងកោះកុង?

សារិនៈ បាទ! នៅបូកគ្នា ប៉ុន្តែអង្គភាពហ្នឹងគេអត់សូវមកចូលរួមប្រយុទ្ធសមរភូមិអី បីអង្គភាពនេះ ច្រើនតែមូលគ្នាវាយ១៣ហ្នឹងមួយដូចជា ឡាត សម្បិត្ត ដើរទៅជួយខេត្តនេះ ខេត្តនោះចឹងទៅ ណា ។

បូលីៈ ចុះមេកងពល២ពីណាគេ?

សារិនៈ សំ ប៊ិត!

បូលីៈ សំ ប៊ិត ហ្នឹងធំណាស់ពីដើម?

សារិនៈ បាទ! ធំ ។ ប៉ុន្តែគាត់ជាអ្នកនយោបាយ គ្រាន់តែរៀបចំសមរភូមិ ម្ល៉ោះហើយក្នុងកងវរសេនាធំ មានវាយខ្លាំង វរសេនាធំ១១ហ្នឹងទេ ដែលវាយខ្លាំងជាងគេ ។

បូលីៈ អ៊ឹអត់មាននៅក្នុងនេះទេ?

សារិនៈ ខ្ញុំអត់ទេ! ក្នុងវរសេនាធំនោះ ប៉ុន្តែខ្ញុំនៅក្នុងវរសេនាតូច១១ដែរ ប៉ុន្តែខ្ញុំវរសេនាតូច ក្នុងវរសេនាធំ១១ហ្នឹង ក-៣១០, ៣៩០,៤០៦ និង៣៣០ ។ ៣១០, ៣៩០,៣៨០ និង ៤០៦ ។

បូលីៈ ៣១០, ៣៩០, ៣៨០ និង ៤០៦ ។

សារិនៈ បាទ! អាហ្នឹងមួយវរសេនាធំ ។

ប៊ុនថនៈ អ៊ឺនៅ៤០៦?

សារិនៈ បាទៗ!

បូលីៈ ៤០៦ ហ្នឹង អ៊ឹមេ?

សារិនៈ អត់ទេ! ខ្ញុំនៅតែដដែលទេ! ព្រោះអីផល, ឈាងអីអត់ទាន់ស្លាប់ នៅមូលគ្នាទាំងបីហ្នឹង ។

បូលីៈ ផល, ឈាង!

សារិនៈ អិត ឈាង! គេហៅអា អិត ឈាង! ហ្នឹង ឈ្មោះវាប្រឆាំងហ្នឹង អា អិត សួង ។ អា អិត សួង របស់ លន់ នល់ ។ វាជួបគ្នា វាហៅអា អិត សួង ចុះហែងស្អីអា អិត សួង! ចុះហែងស្អី អញ អាអិត ឈាង ។ គាត់ឈ្មោះ អា អិត ឈាងរហូត ។

បូលីៈ អ៊ូ ចឹងមិនមែនឈ្មោះ គាត់ពិតប្រាកដទេចឹង?

សារិនៈ ពិត! គាត់គឺ ឈាងហ្នឹង ប៉ុន្តែ អា អិតហ្នឹងជីតាខុស គេដាក់ជីតា ដាក់នេះអិតរូប ប្រឆាំងហ្នឹងជាមួយ អា អិត សួង ។

បូលីៈ ហើយអ៊ីទី៣ហេ៎?

សារិនៈ បាទ!

បូលីៈ ចុះ៣១០ ពីណាគេអ៊ី?

សារិនៈ ៣១០ ហ្នឹង ឈ្មោះ ភា ។

បូលីៈ ភាមេ?

សារិនៈ បាទ! ភាមេ នយោបាយ ហើយ ហ្នឹងភីមបញ្ញាកា ហើយមកហ្នឹង អានុ ។

បូលីៈ ៣៩០អ៊ី?

សារិនៈ ៣៩០ស៊ី ។

បូលីៈ ស៊ី?

សារិនៈ ស៊ី!

បូលីៈ ស៊ី ។

សារិនៈ ហើយមួយនោះ ឆាវ ។

បូលីៈ ឆាវ ។

សារិនៈ ហើយហ្នឹង យ៉ាន ។

បូលីៈ យ៉ាន ។ ៣៨០?

សារិនៈ ៣៨០ ឈ្មោះ មឿន ។ មឿន អ្នកនយោបាយ នេះតា សឿន!

បូលីៈ សឿនមួយទៀត មិនមែនតាសឿន រថក្រោះទេ?

សារិនៈ សឿន មិនមែនសឿនរថក្រោះទេ! ហើយមួយទៀតខ្ញុំភ្លេចហើយមិនដឹង ។ ខ្ញុំនិយាយប្រវត្តិនឹងទៅហើយចាំនិយាយអង្គភាពណា៎! គឺខ្ញុំនៅជាប់រហូតដល់រំដោះភ្នំពេញហើយ ។ ភារកិច្ចខ្ញុំគឺបោះនៅទីតាំងចោមចៅបែកចាន កន្លែងទួលគីណា៎ ។

បូលីៈ ទួលគី?

សារិនៈ អង្គភាពខ្ញុំ នៅទួលគី នៅធ្វើការមួយអង្គភាពទាំងអស់ ប៉ុនអង្គភាពវរសេនាតូចខ្ញុំហ្នឹងគឺនៅទួលគីនៅធ្វើស្រូវធ្វើអំពែនៅហ្នឹងផង ហើយហ្នឹងចុះទៅតាមជួយប្រវត្តិផ្លូវទៅដល់ខេត្តកំពត ខេត្តអីហ្នឹងនោះ ជួយធ្វើផ្លូវខាងថ្នល់ជាតិ ជួយកែលម្អហ្នឹងមួយអនុសេនាធំទៅ នៅចល័តធ្វើហ្នឹងដល់ក្រោយមកដក បានគេរៀបរយទៅការពារព្រំដែនខាងត្បូងហ្នឹងចាប់ពីអីទៅនោះ ទៅដល់ព្រំដែនចាប់ពីបាក់ដៃទៅរហូត ទៅដល់មុខភ្នំដិន ហៅថ្នល់ដាច់យើងហ្នឹង ភ្នំដិន ធ្លាក់មកដល់ទន្លេបាសាក់ អាហ្នឹងគេរៀបឲ្យខ្ញុំទៅទទួលគ្រប់វរសេនាតូចទាំងអស់គេឲ្យមកអនុសេនាធំៗ ហើយគេឲ្យខ្ញុំទទួលតំណាងហ្នឹងទៅការពារ ។

បូលី៖ ទៅការពារព្រំដែន?

សារិន៖ ការពារព្រំដែនខាងត្បូង ។

បូលី៖ នៅឆ្នាំណាដែលអ៊ីទៅការពារព្រំដែន?

សារិន៖ ៧៧ហ្នឹង!

បូលី៖ ៧៧?

សារិន៖ អត់ទេ៧៦! ឲ្យទៅប៉ុនក្នុងហ្នឹង គ្រាន់តែក្តាប់សមរភូមិទេ ទៅកម្លាំងតិចទេ! ទៅក្តាប់ ប៉ុន្តែអា ៧៧ទៅពេញតែម្តង អាហ្នឹងទៅ៤អនុសេនាធំ គឺទៅពេញតែម្តង ។

បូលី៖ ចុះ៧៥ អ៊ីមានវាយចូលទៅភ្នំពេញទេ?

សារិន៖ ៧៥ ខ្ញុំវាយចូល ខ្ញុំត្រូវរបួសនៅអង្គស្នួលបែកបាន ថ្ងៃទី១៥ ខ្ញុំទៅពេទ្យគេរំដោះហ្នឹង រំដោះភ្នំពេញថ្ងៃ១៧ ។

បូលី៖ ចូលពេទ្យអីគេ?

សារិន៖ ចូលពេទ្យក-២ គេថាពេទ្យជួយសង្គ្រោះបន្ទាន់ នៅពាក់កណ្តាលសមរភូមិបានគេយើងបានធូរស្រាលហើយបានគេបញ្ជូនទៅមន្ទីរពេទ្យបង្អែកនោះ នៅអីជិតក្បាលដីររមៀលហ្នឹង! អាកន្លែងពេទ្យដែលខ្ញុំដេកមុននោះ ។

បូលី៖ ចឹងបកមកក្រោយវិញអីអឹ?

សារិន៖ បកមកក្រោយវិញ ។

បូលី៖ មិនមែនបញ្ជូនចូលទៅភ្នំពេញ?

សារិន៖ អត់ទេ! បញ្ជូនទៅភ្នំពេញម៉េច បើភ្នំពេញច្របូកច្របល់ មានតែពេទ្យយើងក្រោយទេឃើញទេ ។

បូលី៖ ចឹងអ៊ីអត់បានចូលទៅភ្នំពេញហ្នឹងគេទេ?

សារិន៖ អត់ទេ! ថ្ងៃ ១៧ គេរំដោះខ្ញុំនៅមន្ទីរពេទ្យនោះ មានទៅដើររួចអី ។

បូលី៖ សម្រានពេទ្យប៉ុន្មានថ្ងៃ?

សារិន៖ ខ្ញុំសម្រាកពេទ្យ១ខែ បានខ្ញុំចេញ ខ្ញុំចេញមកដល់ទួលកីបានគេប៉ុន្មានបី បួនខែទៀត បានគេឲ្យខ្ញុំទៅព្រំដែន ។

បូលី៖ ទៅព្រំដែនភ្នំដិន?

សារិន៖ បាទ! អង្គបុរីនៅភ្នំអង្គបុរី ហើយរៀបចំប្រវត្តិហ្នឹងរហូតការពារព្រំដែនហ្នឹងរហូតដល់ អាដូចថាថ្ងៃ៣០ ថ្ងៃ៣០ ខែមេសាហ្នឹង ដូចថានៅ៧៧ណាស់! ថ្ងៃ៣០ ខែ៤ គឺបើក យុទ្ធនាការតាមព្រំដែននេះទាំងអស់ រំដោះយកដីវិញ គឺចង់និយាយថាភូមិសាស្ត្រព្រៃវិញទេ្ន គឺព្រៃ

ប្រវត្តិសាស្ត្រព្រំដែនហ្នឹង គេអត់នៅហ្នឹងទេ គេឆ្លងព្រែកមកនៅយើងហ្នឹង ធ្វើបន្ទាយធ្វើអី ណា ។

បូលី: វៀតណាមឆ្លងព្រែកមកនៅទឹកដីខ្មែរ?

សារិន: នៅទឹកដីខ្មែរ នៅមុខសញ្ញាខ្ញុំទទួល គឺនៅព្រែក គេហៅបុស្សស្បូវ ក៏ឆ្លងមកនៅនេះ ឯទៅចេះទៅ គេហៅភូមិក្រសាំង ហើយមុខសញ្ញាខ្ញុំទទួលគឺនៅឯបុស្សស្បូវកមកឆ្លងនៅនេះឯទៅចេះទៅ គឺថាភូមិក្រសាំង ហ្នឹងមិនទឹកដីយើង ប្រវត្តិសាស្ត្រពីដើមយើងហ្នឹង ក៏គេមកនៅឯឡើងមកលើ នេះមកជិតបន្ទាយទឹកដោះ ទឹកដីយើងនៅជិតហ្នឹង គេហៅថាក្បាលជ្រោយ ដល់ចឹងខ្ញុំទទួលមុខ សញ្ញាហ្នឹង ហើយធ្វើការចេះតែធ្វើៗឡើង ចេះតែឡើងរហូតទាល់តែឡើង ខាងលើអ្នកដឹកនាំ គ្រាន់ពុថាអ្នកនយោបាយចាស់ទុំដោះស្រាយតាមព្រំដែនទៅតាមការងារទូតនយោបាយចឹងណា ដល់ចេះទេ! ប៉ុន្តែថ្ងៃចរចារដោះស្រាយការងារទូតហ្នឹងពេលណាអត់បានបីថ្ងៃហ្នឹង គេវាយ យើង យួនណា ។ ខ្ញុំនិយាយអាររឿងយួនណ៎ វៀតណាមហ្នឹងគេរំដោះហើយ ប៉ុន្តែដល់ពេល ចឹងតែឆ្លល់ ហើយរាយការណ៍វាយម្តង វាវាយពីខ្សែមកពីក្រោយយើងមក មកដល់វាយ ងាប់មួយគ្រង់សេ ពីរគ្រង់សេ គេហ្នឹង ត្រូវរបួសផង ងាប់មួយងាប់ពីរ ចេះតែចាស់ទុំគេ ឯង ។ ឯងចរចារព្រំប្រទល់សភាពការណ៍ចឹង ចរចារភ្លាម ខ្ញុំនោះក៏ទៅចរចារនិយាយអត់ទាន់ ចប់ទេ ។

បូលី: អឺចរចារដែលចឹង?

សារិន: បាទ! ចរចារជាមួយគ្នាហ្នឹងដើម្បីឲ្យសុខសុវត្ថិភាពតាមដីណ៎!

បូលី: យើងចរចារទៅលើអ្វីខ្លះ សុំគេយ៉ាងម៉េចខ្លះពេលហ្នឹង?

សារិន: ចរចារទី១ពីបញ្ហារក្សាបូរណភាពទឹកដី ទី២ កម្លាំងទ័ពដែលនៅទឹកដីនេះពីសម័យធៀវគឺបន្ទាយ មៀន ប៉ុនតឡូវហ្នឹងគឺសុំអត់ឲ្យនៅទេ គឺនៅទឹកដីខ្លួន អត់ឲ្យនៅទេ ។ បើការមកនៅវានាំឲ្យប៉ះ ពាល់ ដូចនេះនាំឲ្យប៉ះទង្គិចគ្នា រកសុខសន្តិភាពអត់ឃើញទេ ធ្វើឲ្យប្រទេសយើងទាំងពីរកើត កលយុគ ម្ល៉ោះហើយកុំឲ្យប្រជាជនរងកម្មយូរអង្វែងហើយទាំងអស់គ្នា ចេះតែស្វែងរក ។ ប៉ុន្តែ គំនិតគេអត់ស្មោះត្រង់ ចង់និយាយចរចារចប់ អត់ទាន់ចប់ចេញបែកគ្នាផង វាវាយហើយ អានេះប្រវត្តិដើមពិតប្រាកដ ខ្ញុំនិយាយចេះតែដដែរ ព្រោះកម្លាំងខ្ញុំគ្រោះថ្នាក់ ដល់ចឹងលើក ទី៣ សរុបទៅអស់គ្នា៧នាក់ ទាំងរបួសទាំងស្លាប់អស់៧នាក់ ដល់ចឹងខ្ញុំសម្រេចចិត្តចាស់ទុំម៉េច ទៀតទេ រៀបចំទាំងហើយស្រេចតែម្តង រៀបមកពិភាក្សាគ្នាគ្រប់មុខសញ្ញា ហើយរៀបចំអត់ ឲ្យនរណាដឹង ចុះមករៀបចំចឹងថាបើសិនជាមានការវាយគឺយើងត្រូវផ្ទុះ ហើយមួយទៀត កំទេចសត្រូវឲ្យបាននៅហ្នឹងកន្លែងចាប់រស់ឲ្យបានដើម្បីជាឯកសារ ព្រោះទីតាំងនៅហ្នឹងទឹកដី

របស់យើង ហើយយ៉ាងម៉េចបានជាចូលទៅចាប់យួនអីណា បានៗយួនវាមកវាយយើង បាន យើងចាប់បានគេថាចឹង ហើយដាក់ស្នែងមែន ថ្ងៃក្រោយចរចារនោះតាំងវរសេនាធំផង កង ពលផងដើម្បីនៅសុទ្ធតែមេធំៗនៅខាងនោះទាំងសងខាងមក ។

បូលីៈ ខាងយើងនរណាខ្លះធំៗទៅ?

សារិនៈ បងរ៉ែនគាត់ឲ្យ អីនែ៎គេហៅថា អ៉ំជិន្ទួសភាណា៎! ដូចថា យីហ្នឹង គាត់ទៅជំនួស ដល់វរសេនាធំ ក្រោមមកនេះគេថាបន្ទាប់ចុះមក មានទាំងអស់គ្រប់អ្នកធំប៉ុនមនុស្សស្លាប់អស់ហើយ មន ហ្នឹង ក៏ទៅដែរ ដល់បេលគេនិយាយអត់ទាន់បានចុះពីនេះ គ្រាន់តែឡើងមកដល់ទឹកដីខ្លួនហ្នឹង ប្រហែលខ្ទង់ចម្ងាយប្រហែលជា២០០ម៉ែត្រពីកន្លែងចរចារវាវាយ ។ គ្រាន់តែវាយព្រឹប ខ្ញុំនិយាយថាចូលត្រង់សេ គ្រាន់តែចូលត្រង់សេផ្ទុះដឹងត្រង់ហ្នឹង! វាយៗផ្ទុះបិទ អត់ឲ្យចេញរួច តែបន្ទាយទឹកដីយើងហ្នឹង ក៏អត់ឲ្យចេញចូល ឲ្យពួកនោះឡើងទាក់ វាយងាប់យួននោះនៅកន្លែង ៨នាក់ ហើយចាប់បាន១ ។ ១ហ្នឹង ចងទាំងដៃ ចងទាំងជើងទៀតចាប់ដៃចងទៅក្រោយចង ជើងទៀត ហើយដកស្អីៗទាំងអស់ទុកនៅហ្នឹង ឡើងវាយ វាយទាល់តែចប់បានមកយកហែង ងាប់ៗទៅ ។ យកហើយដាក់ចូលមកនៅ រាយការណ៍មកកងពល យើងអញ្ជើញគេទៅ ដើម្បី ឲ្យដាក់ស្នែង មកហ្នឹងមក គឺសុំឲ្យពួកនេះមកថតដាក់ស្នែងយកទៅ ហើយដល់នេះវាសុំចរចារ គឺបញ្ហាមួយយកខ្មោច ដល់មកយកខ្មោចគឺសុំឲ្យទាំងសងហ្នឹង អ្នកដឹកនាំមកមើលថាខ្មោចងាប់ នៅឯណា ។ ត្រង់ហ្នឹងដែលកើតចលាចលខ្លាំងមែនទែន ហើយអារស់យកទៅសួរយួន ឬក៏ខ្មែរ? ថាយួន ហើយចាប់នៅណា?កន្លែងទីតាំង ទីតាំងហ្នឹខ្លាំង ដល់ចឹងទៅបានខ្ញុំថាបើ យើងមិនធ្វើ ខ្លាំងពិតជាគេខ្លាំងដដែរ បើចឹងទាល់តែខ្លាំងដូចគ្នាបានទប់បាន បានសភាពការណ៍ ហ្នឹងនេះប៉ុន្តែក្នុងករណីដល់ពេលចឹងទៅថាចប់ ចប់បុណ្ណឹង ខ្ញុំវាយពិសេសរំដោះ រំដោះបន្ទាយ ហ្នឹង ខ្ញុំត្រូវរបួសប្រវត្តិសាស្ត្រជើងខ្ញុំ ។ ទី៣ គ្រាន់តែវាយជាមួយលន់ នល់ ២ដង តែគ្រាន់ តែវាយជា មួយព្រំដែនជាមួយវៀតណាមហ្នឹងនេះ ។ អានេះវាយពិសេសគឺកម្លាំងពេលហ្នឹង មួយបន្ទាយហ្នឹង ប្រហែលជាខ្ទង់២០០ជាង ឯកម្លាំងដែលចូលវាយហ្នឹងមានតែ១៨ទេ! ចូលវាយក្នុងបន្ទាយតែម្ដង វាយក្នុងរបងហ៊ុំព័ទ្ធដោយបន្លាលួសតាមមាត់ទ្វាបណ្ដោយ ចូលតាម ទ្វានិយាយ ពីបន្ទាយគេចេញពីមាត់ព្រែក ឡើងមកចូលតែម្ដងទៅចឹងទៅ ព្រោះពេលខ្ញុំកំពុង ទៅព្រំប្រទល់ ឯងថាចឹងផ្លូវគេតាមនេះ ប៉ុនថាគេចូលបន្ទាយ ។

បូលីៈ ពីមាត់ព្រែកមកបន្ទាយហ្នឹង ប្រហែលជាប៉ុន្មានគីឡូអ៊ឺ?

សារិនៈ ប្រហែលជា អត់ទេ! គីឡូអី ប្រហែលជាខ្ទង់៤០ម៉ែត្រហ្នឹងពីបន្ទាយមកព្រែក នៅក្នុងទឹកដី យើង ព្រោះព្រំប្រទល់ត្រឹមតែពាក់កណ្ដាលព្រែកវិញទេ្ហ ពាក់កណ្ដាលទឹកមកនេះទឹកដីខ្មែរ

ឯពាក់កណ្តាលទឹកទៅនោះវៀតណាម ប៉ុនចូលវាចូលឆ្លងមកទៀត ទីហ្នឹងណា! ប៉ុន្តែយើងហេតុផលថាបើយល់ពីស្ថានភាពនេះមិនគួណាមកនៅ ប៉ុន្តែបើអាធៀវគី យើងចាត់ទុកថាអាមេរិកកាំង វាមកនៅណាក៏បាន វាមានអំណាច វាអាចបេះតែធ្វើទៅណា អំពើឈ្លានពានយ៉ាងម៉េចបេះតែធ្វើទៅណា ប៉ុននេះដល់ពេលកម្មុយនីសហើយ នៅតែមកនៅហើយទៅវាកាត់ដីព្រំប្រទល់ព្រៃកវិញទ្បេប្រវត្តិសាស្រ្ត ខ្មែរតែអុងហ្នឹងពីដើមគ្រប់ផ្នែកប៉ុន្តែខ្ញុំវាយហ្នឹងហើយ ខ្ញុំវាយឈ្នះហើយខ្ញុំគ្រោះថ្នាក់ដោយសារពួកយួនរបួស ខ្ញុំវាយរំដោះហើយយកកម្លាំងឡើងជាត្រងសេការពារដល់មាត់ទឹកទាំងអស់ ។

បូលីៈ ស្រុកអីអឺ កាលហ្នឹងស្រុកកោះអណ្តែតយើង?

សារិនៈ អត់ទេ! មិនមែនស្រុកកោះអណ្តែត ស្រុកកោះធំ ព្រំប្រទល់ស្រុកកោះធំខេត្តកណ្តាល ។

បូលីៈ អ៎ូ ស្រុកកោះធំខេត្តកណ្តាលនេះទេ?

សារិនៈ បាទ!

បូលីៈ ប៉ុន្តែនៅក្នុងភូមិភាគនិរតីគ្នានេះ?

សារិនៈ បាទ! និរតី ។

បូលីៈ តំបន់ប៉ុន្មាន តំបន់កោះធំតំបន់ប៉ុន្មាន ៣៥អី?

សារិនៈ ទេ! ខេត្តកណ្តាលហ្នឹង មិនដឹងតំបន់ប៉ុន្មាន ខ្ញុំ!

បូលីៈ ១៥?

សារិនៈ បាទ! ហ្នឹងហើយ១៥ ប៉ុន្តែស្រុកដឹងថាស្រុកស្អាង កោះធំវាជាប់ស្អាងហើយបានកោះធំជាប់ព្រំប្រទល់តែម្តង តែខ្ញុំអត់សូវសិក្សាភូមិសាស្រ្តកន្លែងហ្នឹង ។

បូលីៈ ហើយអឺទៅវាយហ្នឹងទៅវាយព្រំប្រទល់កោះធំទេ?

សារិនៈ ខ្ញុំទទួលមុខសញ្ញាទន្លេបាក់សាក់ហ្នឹង ។ ដូចនេះគេចែកព្រំប្រទល់ការពារគេអត់គិតតំបន់នេះគេចែកភូមិសាស្រ្តគ្នា ខាងមុខចឹងទៅតំបន់ខេត្តកណ្តាល គេទទួលរហូតដល់ក្អមសំណាចឹងណាបូកជាមួយខាងណា ខ្ញុំមិនដឹងទេ ។ ប៉ុនពីនេះទៅដល់ភ្នំដិនហ្នឹងគឺពួកខ្ញុំ ។

បូលីៈ បាទ! ពីកោះធំទៅដល់កោះ?

សារិនៈ អត់ទេ! ពីទន្លេបាសាក់ទៅក្បាលជ្រោយហ្នឹងណ៎ា ។

បូលីៈ វែងដែរ?

សារិនៈ វែង! ដើរព្រឹក ថ្ងៃត្រង់ដាច់បាយ ដាច់ទឹក ដល់កន្លែងមួយៗ ។ ដល់ពេលចឹងខ្ញុំចូលមកវិញរៀបហើយកម្លាំងកងពិសេសខ្ញុំអាខិលៗហ្នឹង កងពិសេសវរសេនាធំ១១ហ្នឹង វាចូលបន្ទាយវាចូលបន្ទាយទៅបានកាំភ្លើងយួនហ្នឹងបានសែកន្លះ ធ្លាប់តែមេ៤០ អាហ្នឹងវា៤១បានស្ទាប់ដៃ

២នោះ យករបស់យួនហ្នឹង បានអាហ្នឹងវាយកអីយ៉ា អាហ្នឹង អញទើបតែរកមុខជួប ហើយវា កាន់សែកខ្ទះ ដល់បានអាហ្នឹងវាលីទាំងពីរដើម វាដើរអីយូយ៉ា ខ្ញុំត្រូវស្រាស់ នរណាគេចូល ទៅបន្ទាយ ក៏រៀបកម្លាំងក៏ចូលទៅ២នាក់ក្មេងជាមួយខ្ញុំម្នាក់ហ្នឹងដើរពីក្រោយហ្នឹង ដល់ពេល គ្រាន់តែទៅដល់ហ្នឹងឲ្យចុះគ្រែ នៅក្នុងបន្ទាយហ្នឹងផ្ញើគ្រែចឹងទៅ ហើយហាលខោអាវពេញលើ ប៉ុនត្រង់សេបន្តប់ហើយ វាត្រូវរបួសអីចឹងទៅបាក់ជើងមួយហើយអារបួសអាភ្នែក ហើយ ដៃមួយអត់បាក់ទេ ប៉ុនអាមួយអ៊ូវាពេទ្យរបួសនោះហ្នឹង ដល់ចឹងទៅខ្ញុំដើរ ដើរបត់ថ្នល់កែង វាបាញ់អត់ត្រូវ បានខ្ញុំដើរលើអាងឈ្នះ៤ម៉ែត្រ កាំភ្លើងវាលើកវាលើកអត់កើត បើលើក កើតវាបាញ់ងាប់បាត់ហើយ ។ បាញ់អាគង់នៅក្រោមដើមនោះ ព្រែតបីគ្រាប់ជើងខ្ញុំបាក់ជើង ដូងបណ្ដោយដូងតែម្ដង ដឹងតែបាក់ជើងខ្ញុំរមៀលចូលកិញ ចូលកិញអូរអាសន្ន ដល់ចឹង ដោះ គ្រាប់បែកពីចង្កេះមកទាំ ទាំងកថាជីវិតនៅនេះស្មារតីយើងណា! ដល់ទាំបោះ បោះទៅវា មិនចូល វាទៅរនាបគ្រែ ភីង! ចឹងទៅបើកគ្រែហ្នឹង ដល់មើលទៅម៉ែរបើកគ្រែ ត្រង់សេនៅ ដដែរ ។ ហើយចុះបើឃើញវាឃើញវាងើប ចង់ឲ្យយើងងើបក្បាលចេញ អាពាក់អាមួក ត្រប៉ែតងើបចេញ! នៅដប់មួយទៀត ដប់បោះមមៀលចូលឈរមក ឈរជើងម្ខាងដាក់កិញ វានោះ កិញខាងនេះឈរចេះកិញចូលក្រលុកបណ្ដោយងាប់អស់រលីង បានខ្ញុំលូនចេញលូន ចេញមកបានខ្ញុំមកជួប មកបន្ទាយហ្នឹងបណ្ដោយមក ខ្ញុំចេញក្នុកុម្ពចេក ខ្ញុំចេញមកពេទ្យ ជើង ខ្ញុំបាក់ ។ ខ្ញុំពិការតាំងពីនោះមករហូត ទល់តែខ្ញុំទៅពេទ្យនៅភ្នំពេញ កាលហ្នឹងខ្ញុំរំដោះ ហើយ មិនរៀបចំពេទ្យនៅភ្នំពេញ ពេទ្យរូស៊ីហ្នឹង ដល់ចឹងទៅវាកើតរៀងតា ជួត ជឿន គាត់ផ្ញើ ផ្ញើអីទៅអបទៅដល់ចុងជើង ។

បូលី៖ កាត់នៅ?

សារិន៖ នៅទេ! បាទ! ផ្ញើអបហ្នឹងទៅ ហើយខ្ញុំបាក់ចើងទាំងពីរ ដល់ហើយជាប់ឆ្អឹងតូចវិញ ឆ្អឹងធំអត់ ជាប់វាបាក់ឃ្លាតពេកវាត្រូវគ្រាប់ត្រង់អាឆ្អឹងធំ វាបាក់ឃ្លាតគ្នាឆ្ងាយចឹង ដល់អាតូចចឹងវាបាក់ មែន វាបាក់ហើយវាទល់គ្នាវិញ ។ ដល់ចឹងវាដុះស្របជាប់អាតូច ហើយខ្ញុំទៅនេះនៅតែចឹង រហូតទាល់ដល់ពេទ្យគេពិនិត្យអីដល់ថ្ងៃដល់ខែចឹងហើយទៅកាត់ កាត់ជើងយើងអត់ទាន់ជាប់ឆ្អឹងធំ គេរុំឡើងវិញ រុំឡើងវិញ ខ្ញុំទៅអន្តភាពត្រលប់ទៅវិញទៅ ខ្ញុំនៅភ្នំដា ដល់ចឹងទៅគេបង្កើត កងពលថ្មី កងពល២៧០ ដឹកនាំដោយលោក ម៉ន ដែលចេញ៣១០នេះ ។ អនុនេះ!

បូលី៖ កងពលរបស់និរតីលោកអី?

សារិន៖ បាទ! និរតី គេរៀបកងពល២៧០ថ្មីណា!

បូលី៖ យកចេញពីណាខ្លះ២៧០ហ្នឹង?

សារិនៈ មិនដឹងជាយកពីណាៗខ្លះទេ ប៉ុន្តែមានមននេះដែរ ម៉ន៣១០ទៅធ្វើកងពល ប្រធានកងពល ។

បូលីៈ ទៅធ្វើមេកងពលតែម្តង?

សារិនៈ ២៧០ហ្នឹង ។ ហើយបានគេដកខ្ញុំពី(ស្តាប់ពុំបាន)ឲ្យមកធ្វើសមាជិកកងពលដើម្បីគ្រប់គ្រងកម្លាំងខាងក្រោយហើយចាត់ចែង ហើយទាញមកមុខ ។

បូលីៈ ២៧០ហ្នឹង?

សារិនៈ បាទ! ២៧០ ។

បូលីៈ ២៧០ហ្នឹង កងពលរបស់ភូមិភាគ ឬក៏របស់?

សារិនៈ របស់ភូមិភាគនិរតី ។

បូលីៈ មិនមែនកងពលរបស់មជ្ឈិមទេ?

សារិនៈ អត់ទេ!

បូលីៈ ភូមិភាគនិរតី ក្រោយ៧៥មកមានប៉ុន្មានកងពលអ៊ី?

សារិនៈ ក្រោយមកពី៧៥ ដូចជាមានបី ។

បូលីៈ ២៧០ មួយ?

សារិនៈ ២៧០មួយ ហើយកងពល២ កងពលធំហ្នឹងណា ។ វាឡើងកងពលធំ កងពល២ហ្នឹង ដូចនេះមានកងពល ទេ! ខ្ញុំដឹងតែ២៧០ពេលខ្ញុំចូល ប៉ុន្តែគេបង្កើតដូចជាមានបីកងពល ។

បូលីៈ អា២ទៀតលេខអីគេអ៊ីចាំទេ?

សារិនៈ ទេ! មិនដឹងទេ ។

បូលីៈ មនប្រធាន! នរណាគេអនុ?

សារិនៈ អនុមានតែខ្ញុំ២នាក់ហ្នឹង! គេទើបតែរៀបថ្មីនោះ ។

បូលីៈ មន ឈ្មោះពេញ ឈ្មោះអីគេអ៊ី?

សារិនៈ ស្អីទេមនទេ! ព្រោះហៅតាអាម៉នៗ ហើយដល់បែកគ្នាវាខ្វាត់ខ្វាយ ។

បូលីៈ វានៅរស់ទេម៉នហ្នឹង?

សារិនៈ អត់ទេ! ស្លាប់ ។

បូលីៈ មានវរសេនាធំ កងពល២៧០?

សារិនៈ មានបីវរសេនាធំ ។

បូលីៈ មានអីខ្លះអ៊ី?

សារិនៈ មើល អា សៀក, អាសួយ អត់ទេ! កងនេះគេកើតហ្នឹង គេរៀប តូចនោះខ្ញុំគ្រាន់តែចូលទៅគ្រប់គ្រងបានតែកន្លះខែទេ ខ្ញុំចេញ ចេញពីហ្នឹងទៀត ដូចថាមួយគ្រាន់បានស្គាល់តែមនុស្ស

ប៉ុន្តែវរសេនាធំ ខ្ញុំស្គាល់គេថ្ងៃខ្ញុំការ គ្រួសារខ្ញុំ! ខ្ញុំការទាំង(ស្តាប់ពុំបាន) ខាងលើ សម្រេចចិត្តការឲ្យ យកពីណែពីណា ខ្ញុំអត់ដឹងទេ ខ្ញុំមកដល់ឲ្យការ ។

បូលីៈ អ៊ឹពុំមែនអ្នករើសខ្លួនឯងចឹង?

សារិនៈ អត់ទេ! ដល់និយាយចឹងរើសនោះ ប៉ុនគេសម្រេចឲ្យនរណាទៅ ដល់ចឹងវាខ្វែងគ្នា ដល់ចឹងទៅសមាជិកខ្ជិលណាស់ ដល់យើងពិការផង ដល់ពេលគេថាត្រូវតែខ្ញុំប្រយុទ្ធខ្លាំងណាស់ដើម្បី ដល់ពេលចឹងទៅបានគេសម្រេចការ ដល់ពេលថ្ងៃការបានគេហៅទៅបានប្រាប់ ។ ប៉ុនដល់ថ្ងៃចូលរណ្តៅ បើយើងសម្រេចចិត្តខុស ពេលហ្នឹងក៏ងាប់ ដល់ចឹងធ្វើម៉េចធ្វើទៅ ទៅទាំងខោអាវប្រលាក់ភក់ហ្នឹងទៅមើលកងចល័តគេធ្វើស្រែនោះផង ។ ដល់ត្រលប់មកវិញ បានការ បានជួបគ្រួសារខ្ញុំ ។

បូលីៈ នៅរាល់ថ្ងៃ?

សារិនៈ រក្សាការពាគ្នាបានល្អ អត់បែកបាក់ទេ ។

បូលីៈ ខុសពីគេលូវការលែង១ ។ កានោះការមិនដែលស្គាល់គ្នាផង ការនៅបានយូរ ។

ប៊ុនថនៈ អត់ដែលស្គាល់គ្នាពីមុនមកទេ គ្រួសារអ៊ឹ?

សារិនៈ អត់! ចង់និយាយថាគាត់ចេញតាំងពីតស៊ូ តាំងពីតូច ។

បូលីៈ គាត់ធ្វើអីអ៊ឹ?

សារិនៈ ពីមុននោះ គាត់កូនប្រជាជន ប៉ុន្តែចូលទៅក្មេងណា ដល់ពេលចឹងគេឲ្យទៅ មន្ទីរមើលតែកូនមន្ទីរពេទ្យគេឧបត្ថម្ភមិនទាន់មើលតែកូនគេហ្នឹង ។ ដល់ពេលគេធំទៅ គាត់បានក្លាយជាពេទ្យជាពេទ្យគ្រុនចាញ់ កំចាត់គ្រុនចាញ់ ពិនិត្យឈាមផង ហើយដើរបាញ់សម្លាប់មូសអីហ្នឹងគាត់មិនមែនជាពេទ្យជាស្អីទេ ។

បូលីៈ ការហ្នឹងឆ្នាំប៉ុន្មានអ៊ឹ ៧៧?

សារិនៈ ៧៧!

បូលីៈ ខែ ប៉ុន្មានអ៊ឹ?

សារិនៈ ការខែ៨ ហ្នឹង ទឹកធំឡើងពេញផង ។

បូលីៈ ប៉ុន្មានគូអ៊ឹ កាលការអ៊ឹ?

សារិនៈ អត់មានទេ ការតែខ្ញុំមួយទេ! មួយគូទេ ។

បូលីៈ ការយ៉ាងម៉េចអ៊ុំ មានពីធី មានអី?

សារិនៈ បាទ! មានពីធីមានអីចឹងទៅ មកហ្នឹងប្រធានវរសេនាធំអីទាំងអស់គេមក អីចឹងទៅណា ហៅគេមកជួយជាមតិចឹងទៅ ក្នុងនាមយើងជាវរសេនាធំទាំងអស់ កើតពីអនុសេនាធំវាប្អូនយើង

ដល់ចឹងគេសុំ សំនូមពរដល់បងចឹងទៅគេថារក្សាធ្វើម៉េចតម្លៃទោះបីជាពុំបានរៀបចំប្រពៃណីគគ្រឹក ប៉ុន្តែធ្វើម៉េចច្បាប់ យើងការស្របច្បាប់អ្នកដឹកនាំទទួលខុសត្រូវ ដើម្បីរក្សាចំណងមិត្តភាពប្តីប្រពន្ធឲ្យបាន ហើយមើលទៅខំបំពេញការងាររបស់យើងដែលមាននាទី ខំធ្វើឲ្យរីកចំរើនចឹងណា ហើយផ្តាំផ្ញើរគ្នាចឹងទៅ ហើយដល់យើងទទួល យើងគ្រាន់តែទទួល យើងប្តេជ្ញាចិត្តថាទោះបីករណីយ៉ាងម៉េចក៏ដោយ ក៏យើងត្រូវតែរក្សា ព្រោះចំណងទោះបីជាពុំបានរៀបចំប្រពៃណីទំនៀមទម្លាប់ចាស់បុរាណ មានម៉ែមានឪមេបាចាស់ទុំប៉ុន្តែមានមិត្តភក្តិទាំងអស់គេទទួលខុសត្រូវ នេះទទួលស្គាល់ ។ ដល់ចឹងនេះ ខ្ញុំប្តេជ្ញាចិត្តរក្សា ប៉ុន្តែក្នុងករណីដែលយើងទទួលខុសត្រូវបាន តែបើទទួលខុសត្រូវមិនបាន ខ្ញុំសូមវេរជូនអ្នកទាំងអស់គ្នាវិញ មូលហេតុអីព្រោះសកម្មភាពមនុស្សខុសគ្នា ។ យើងចង់ធ្វើល្អ ប៉ុន្តែគេធ្វើមិនល្អឲ្យយើងទទួលយ៉ាងម៉េច ។ ប៉ុន្តែអ្នកឯងយកមកខ្ញុំ អ្នកឯងទាំងអស់ចូលរួមត្រូវទទួលខុសត្រូវ ខ្ញុំនិយាយចឹង ។ ប៉ុនដល់ចឹងយើងបានប្រកបដោយធម៌ ។ ទីមួយគ្រួសារយើង ដោយទីមួយគ្រួសារយើងចរិតល្អ ប្តុកពារល្អ សកម្មភាពល្អ ហើយមួយទៀតការនិយាយស្តី ការធ្វើអី គឺអត់អីចំពោះអ៊ីដែលធ្វើឲ្យប៉ះពាល់អ្នកដ៏ទៃ ។ យើងនិយាយគាត់ទទួល គាត់យកទៅពិចារណា បើត្រឹមត្រូវគាត់ថា និយាយធ្វើចឹងដូចល្អ ។ បើយើងនិយាយទៅវាមិនល្អ ធ្វើចេះមិនកើត ឥលូវពិភាក្សាគ្នាម្តងទៀតចឹងទៅណា ។ ប៉ុន្តែតាំងពីខ្ញុំយកគាត់ហ្នឹង បានតែ១ខែទេៗ បានតែ១ខែទេ គាម៉ុកហៅខ្ញុំទៅជួបនៅតាកែវនេះ ហើយរៀបរយថាឯងទៅជួប អា មឿន នៅខេត្តក្រចេះ ។

បូលី៖ រឿងអីអ៊ីបានទៅជួមឿននៅខេត្តក្រចេះ?

សារិន៖ រឿង តំបន់ស៊ុយត ដល់ពេលចឹងទៅវាមានឧបសគ្គចឹងទៅ មឿនហ្នឹងវានៅកងពលទី២ពីមុនវរសេនាធំ ចឹងអី! ដកមឿនចេញពីហ្នឹង បានខ្ញុំមកគ្រប់គ្រងតំបន់ស៊ុយតខេត្តក្រចេះ ពីនិរតីខាងលើមកពីភាក្សាគ្នាគេសម្រេច ដកបុគ្គលហ្នឹងដែលមានសមត្ថភាពបានទៅគ្រប់គ្រងបាន ។

បូលី៖ យកពីណាគេទៅគ្រប់គ្រងនៅក្រចេះ យកមឿនហ្នឹង?

សារិន៖ យកមឿនហ្នឹង ។

បូលី៖ មឿនហ្នឹងទៅតាំងពីអង្កាល់?

សារិន៖ តាំងពីដើម៩៧ ។

បូលី៖ ៧៧ហេ៎?

សារិន៖ បាទ! ៧៧ ។

បូលី៖ ៧៧ យី គួន នៅ នៅឡើយតាអ៊ុំ?

សារិនៈ អត់ទេ! ដក យី គួន ហ្នឹងតាបានមឿនទៅ។

បូលីៈ ចឹងចាប់ យី គួន ហ្នឹងបាត់ហើយ?

សារិនៈ បាទ!

បូលីៈ មឿន ពីដើមគាត់ធ្វើអី?

សារិនៈ មឿនគាត់វរសេនាតូច៣៨០នេះ។

បូលីៈ ៣៨០ហ្នឹង?

សារិនៈ បាទ! ក្រោយមកគាត់ទៅជាវរសេនាធំ រៀបក្រោយមកដកអីហ្នឹងទៅមកហ្នឹងទៀត។ ប៉ុន គាត់ស្លាប់ហើយ ចាំខ្ញុំនិយាយគាត់ស្លាប់។

បូលីៈ ហើយអ៊ំធ្វើអីនៅក្រចេះហ្នឹង ធ្វើអនុរបស់?

សារិនៈ ដល់គេដកខ្ញុំហ្នឹងទឹកធំកំពុងពេញឡើង ឡើងខែ៨ ឡើងមែនទែនឡើងលិចក្រចេះស្អីនៅក្រោម ក៏លិចសុទ្ធតែទឹកទាំងអស់ណាស់។

បូលីៈ អាហ្នឹង៧/៨អ៊ំ ទឹកធំ?

សារិនៈ បាទ! ឆ្នាំរោងគេណានោះ ដល់ចឹងខ្ញុំឲ្យមក តាម៉ុកហៅឲ្យទៅជួប ដល់ទៅជួបចឹងទៅគាត់ សម្រេចថាហែងទៅនោះទៅ ទៅជួយមើលនោះទៅ មឿន ព្រោះមឿនអត់មានគ្នាហើយមួយ ទៀតសកម្មភាពទាំងអស់ មុខផងក្រោយផងតែចឹងណា៎! ហើយខ្ញុំថាអើយតា! ឲ្យខ្ញុំទៅយ៉ាង ម៉េចបើខ្ញុំអ្នកពិការ ដូចនេះប្រើខ្ញុំទៅធ្វើអីកើត តថ្លៃជាមួយតាម៉ុក! ហ៎កើតមិនអង្គុយថាទៅ ចាត់ចែងគេទៅ គេអ្នកធ្វើតា ចឹងថាហ៎ទៅច្រើនតែងាប់មាននរណាក្តាប់ខ្ញុំបានទេនៅនេះទៅ អ្នកនេះក្តាប់ បានក្តាប់បានខ្ញុំយ៉ាងម៉េច។ ខ្ញុំទៅនោះប្រយ័ត្នងាប់ខ្ញុំតា។ អញមិនឲ្យងាប់ទេ ចឹងណាខ្ញុំក៏គេចមិនរួចហើយក៏សម្រេចចិត្តទៅដឹកប្រពន្ធកាត់ទឹកធំលិចនៅក្នុងព្រៃ លិចដល់កំពង់ អំពិល កំពង់យោលទាំងអស់ យកកាត់ទឹកហ្នឹងមក ឡើងឡានមកដល់ភ្នំខ្នែងទៅលើភ្នំខ្នែង ដឹកមកដល់ភ្នំពេញ មកដល់ភ្នំពេញបានធ្វើគេហៅថាលិខិតខទ្ទេសនាម។

បូលីៈ ពីណាមក?

សារិនៈ ពី៨៧! ៨៧ ហ្នឹងគេហៅកន្លែងតាប៉ុលពត កន្លែងគណៈដឹកនាំគេហ្នឹងណា។ ខទ្ទេសនាមហ្នឹង លិខិត ហ្នឹងតាមទូរស្ព័ ធ្វើហើយគេយកឲ្យដល់កន្លែងពាណិជ្ជក្រចេះហ្នឹងឲ្យខ្ញុំ ឲ្យជិះកប៉ាល់។ កប៉ាល់ ក្រចេះហ្នឹង វាមានបី អា១ហ្នឹង៣៥០តោន អាមួយ១៨០តោន២ ហើយជិះអា ១៨០តោន។ ជិះកប៉ាល់ហ្នឹងទៅទាំងទឹកភ្នែកទឹកសំបោ តាមទឹក ទៅដល់កំពង់ចាមហូបបាយ ហូបទឹកនែ៎។ ហូបហើយ ក៏ចេញទៅទៀតទៅដល់មិនដឹងអីណាអីណែទេ អត់ដឹងភូមិសាស្ត្រ នោះ។ ហើយទៅដល់ក្រកេចះ បានគេឈប់ហ្នឹងកំពង់ដែទឹកធំឡើងពៀបនៅផ្លូវ។ ឥលូវហ្នឹង

គេឈប់ ដែរហ្នឹងគេដាប់ហ្នឹងក្រុងហ្នឹង ពុំមែនអានៅដើមពោធិ៍ទេ ។ ឈប់នៅហ្នឹងក៏ឡើងនាំគេក៏នាំទៅ មឿនរៀបរយកម្លាំងក៏មកទទួលចូលកន្លែងគេទៅណា ។ ខ្ញុំក៏ពិភាក្សាគ្នា អើឯងបានមកហើយ ឯគ្នាទៅមុខ ឯងទៅក្រោយគ្នា ទេ! ឯងទៅចោលអញម៉េច ។ កាលហ្នឹងនៅហៅគ្នាអាដែរតា គេធំមែនតែនៅតែហៅអា ។

បូលីៈ ពីណានៅមុខ ពីណានៅឯក្រោយ ។

សារិនៈ មឿនហ្នឹង! ដល់ចឹងទៅវាថា ខ្ញុំមេការឲ្យនៅក្រោយ ឲ្យគ្រប់គ្រងចាត់ចែងខេត្តទៅ នៅតាមស្រុក តាមមូលដ្ឋាន គ្នានៅមុខដាប់ហ្នឹងកម្លាំងទ័ព ការពារជាមួយសត្រូវយួនកាលហ្នឹងនោះ ។

បូលីៈ សុំនេះតិចអ៊ី លិខិតខុទ្ទេសនាមហ្នឹង អត្ថន័យយ៉ាងម៉េចខ្លះនៅក្នុងហ្នឹង?

សារិនៈ អត្ថន័យគេចង់និយាយថា គេខុទ្ទេសនាមណា ។

បូលីៈ គេដាក់ថាម៉េច?

សារិនៈ អាហ្នឹងគេថា គេបញ្ជាក់ពីលើ លិខិតខុទ្ទេសនាម គេដាក់បុណ្ណឹងទេណាស់! បាវចនាខ្ញុំអត់បានមើលកាលហ្នឹង បាវចនាបក្សគេ ។

ប៊ុនថនៈ អាហ្នឹងអត់ដាក់ចេញពី សុន សេន សេនាធិការអីទេពូ?

សារិនៈ អត់ទេ! ពី៨៥ហ្នឹងមកបណ្ដោយ ។

បូលីៈ ៨៧!

សារិនៈ អ៊ំ!៨៧ហ្នឹងមកបណ្ដោយ គឺថាគេខុទ្ទេសនាមនោះ វាថាមកឲ្យខ្ញុំទៅទទួលធ្វើម៉េចឲ្យទៅដល់ហ្នឹងទៅចូលរួមដឹកនាំក្នុងគណៈតំបន់ហ្នឹងណា ។

បូលីៈ អត់មានតែងតាំងឲ្យជាអនុគណៈតំបន់អីទេណ៎?

សារិនៈ អត់ទេ! តែងតាំងអីគេអត់និយាយទេ គេថាឲ្យមកចូលរួមដឹកនាំក្នុងគណៈតំបន់ ហើយយើងគេឲ្យតួនាទីធ្វើអាណាចេះតែធ្វើទៅណា ។

បូលីៈ មានប៉ុន្មានអ្នកគណៈតំបន់?

សារិនៈ មានបីនាក់ ។

បូលីៈ មឿន១!

សារិនៈ មឿន, តាខុន គេអនុប៉ុនគេទទួលខាងផ្នែកទ័ព ខុនណា!

បូលីៈ មឿន នយោបាយ?

សារិនៈ បាទ ! មឿន នយោបាយ!

បូលីៈ ខុន ទទួលទ័ព?

សារិនៈ ខុនទទួលទ័ព ឯខ្ញុំទទួលនូវគ្រប់គ្រងមូលដ្ឋានក្រោយទាំងអស់ មន្ទីរស្អី ស្រុកអីទាំងអស់ គឺខ្ញុំនៅការងារមន្ទីរជុំវិញស្រុកខេត្តហ្នឹងណា ដូចនេះគ្រប់! គេថាបានទាំងពេទ្យ ទាំងដេរ ទាំងត្បាញភ្លើង ពួកដឹកជញ្ជូនខាងដើងទឹកហ្នឹង ពួកខាងសិប្បកម្ម ពួកខាងជាក្រឡឹងអីលើខ្ញុំ ខាងសាំងខាងប្រេង ។

បូលីៈ ពេលហ្នឹង យី គួន អីចាប់អស់ហើយ ។

សារិនៈ ចាប់អស់ហើយ ខ្ញុំអត់ស្គាល់ អត់ឃើញទេ ។ ឃើញតាមឿនហ្នឹង ហើយខុន ហើយហ្នឹងអឿនប៉ុន្តែអឿនហ្នឹងគាត់អនុខាងសមរភូមិទេ ។ គាត់ពុំមែនតំបន់ទេណា ។

បូលីៈ នៅបញ្ញាការគេថាមន្ទីរតំបន់នៅម្តុំណាអ៊ី?

សារិនៈ បើនិយាយឲ្យចំគេនិយាយថា អាផ្លូវមាត់ទឹកតែម្តង ។

បូលីៈ មាត់ទន្លេ?

សារិនៈ បាទ! មាត់ទន្លេ ។

បូលីៈ អ៊ឹ! អានេះទន្លេណា ពេលអ៊ុំទៅដល់កំពង់ដែ អ៊ឹមិនឡើងប្រាំង ទៅឡើងប្រាំងបទស្តាំ ឬក៏បទឆ្វេង?

សារិនៈ ឡើងប្រាំងគឺមកត្រង់កន្លែងនេះ កន្លែងមឿននៅហ្នឹង ដល់អាបត់ក្រោយនេះ កន្លែងពួកឃ្លាំងទីនេះ បើអាពួកខាងនេះគេហៅថាអាពួកកាលពួកប្រធានមន្ទីរខេត្តហ្នឹងណាស់ ទទួលខុសត្រូវ ។

បូលីៈ អាចនៅសាលាខេត្តរាល់ថ្ងៃទៅមើលទៅ?

សារិនៈ សាលាខេត្តអត់នៅ ។

បូលីៈ ឬក៏សណ្ឋាគារសន្តិភាព?

សារិនៈ ផ្ទះ! ផ្ទះតែម្តង ផ្ទះប្រជាជន ធម្មតាពីមុនដែលនៅ ។

បូលីៈ នៅមាត់ទន្លេ?

សារិនៈ នៅមាត់ទន្លេតែម្តង!

បូលីៈ អ៊ឹមើលបីលើមកឃើញទន្លេទេ?

សារិនៈ ឃើញ! ដើរទៅហ្នឹងមាត់ទឹក នៅហ្នឹងហើយ ។

បូលីៈ ផ្ទះហ្នឹងជាប់ហ្នុងផ្លូវ?

សារិនៈ បាទ! ដូចក្លៅហ្នឹង មាត់ទន្លេចឹងមិនផ្លូវ ហើយដល់បត់ចូលមកនេះ ឥលូវខ្ញុំគូបង្ហាញឲ្យមើល ។ គេថាអាបេះវិញពីសាលាខេត្ត ហើយចេញមកដល់នេះមក មិនមានកន្លែងបេនឡានផ្សារនេះចេញពីបេនឡានផ្សារ មកអាផ្លូវនេះ មកដល់នេះចេញមកកុងបេះមកបេះ អានេះទៅនេះផុតទៅដើមពោធិ៍មាត់ទឹកនោះ ប៉ុនអានេះចូលនេះទៅផ្ទះដួល ហើយអានេះផ្លូវមាត់ទឹកទន្លេ ដល់ចឹង

អាផ្ទះហ្នឹងផ្លូវហ្នឹង ហើយអាផ្លូវនេះមួយទៀត ផ្ទះនេះក៏ពួកកម្ចាំងនៅក៏ពួកចាត់ចែងសម្ភារដឹកនាំដល់អានេះផ្លូវនេះគឺ ពួកដែលខបត្តម្ពដល់ស្រុក សម្ភារមានស្អីៗទៀតចឹងទៅជាថ្នាំជុសធ្មេញប្រាសហើយពេទ្យ មន្ទីរពេទ្យអីថ្នាំអីចាត់ចែងផ្តល់ទៅពេទ្យទាំងមុខ និងក្រោយ ។ ហើយកន្លែងនេះពួកគេនៅ មឿននៅ ឯនេះពួកខ្ញុំ ។

បូលី៖ ចុះពូវត្តក្រចេះនៅម្តុំណាវិញ?

សារិន៖ វត្ត?

បូលី៖ បាទ!

សារិន៖ វត្តក្រចេះនៅនេះ ហើយវត្តនៅជិតដែលមកនៅឯនេះមួយទៀត គេថាវត្តនៅជិតមន្ទីរពេទ្យនៅជិតភូមិផ្សារកណ្តាល វត្តហ្នឹងមួយទៀតណ៎!

បូលី៖ មានវត្តផ្សារកណ្តាលមួយផ្សេងទៀត?

សារិន៖ ហ្នឹងហើយ! ផុតពីក្រុងទៅ ទៅតិចទៅបត់ចេះវត្តនៅហ្នឹងបណ្តោយ បែបកន្លែងញហ្នឹងគេថាឡាន ។ កន្លែងឡានពីដើម ព្រោះថាធ្វើឡានតំបន់នោះដួសជុលឃ្លាំងឡាននៅហ្នឹងបណ្តោយចឹងទេ! ខ្ញុំដឹង! បន្ទាប់មកហ្នឹងមកគឺ មន្ទីរពេទ្យ!

បូលី៖ បាទ! មន្ទីរពេទ្យ មន្ទីរពេទ្យហើយគុក ។

សារិន៖ គុកហ្នឹងវាជាប់នៅខេត្ត ប៉ុន្តែខ្ញុំអត់ដឹងថាគុកទេ កាលហ្នឹងខ្ញុំទៅកន្លែង ។

បូលី៖ មន្ទីរតំបន់នោះឆ្ងាយពីមន្ទីរពេទ្យទេអី?

សារិន៖ យ៉េ! ប្រហែលជាដីបើយើងគិតទៅ ខ្ពស់ណាស់៧០០ម៉ែត្រពីកន្លែងសាលាខេត្តណា ។ ពីសាលាខេត្តចាស់ហ្នឹងទៅ ។

បូលី៖ នៅខាងលិចសាលាខេត្ត?

សារិន៖ ខាងលិចសាលាខេត្ត អាឆ្វេងទន្លេទៅលិច ។

បូលី៖ ម្តុំបឹងគីឡូចឹង?

សារិន៖ បាទ! ខ្ញុំអត់ដឹង គ្រាន់តែនិយាយឲ្យចាំភូមិសាស្ត្រ ។

បូលី៖ បានន័យថាយើងឡើងពីដៃណូតមកបត់ស្តាំ?

សារិន៖ ឡើងពីដៃកាណូតបត់ស្តាំពីដៃកាណូតចាស់នេះ កាំជណ្តើរណា ឡើងមកដល់ ចូលអាហ្នឹងផ្ទុកផ្លូវហ្នឹង ផ្ទះគេនៅនេះ ប៉ុនដល់មកតាមផ្លូវនេះចូលផ្លូវនេះ គឺអាកន្លែងផ្ទុកសម្ភារ ពួកតំបន់គេនៅដែរតែគេផ្ទុកសម្ភារ ។ ដល់កន្លែងនេះផ្ទុកសម្ភារសម្រាប់សមរភូមិហើយហ្នឹងស្រុក ចឹងណា ។ ហើយដល់កន្លែងនេះកន្លែងខស្បាហកម្មគេ កន្លែងធ្វើកាណូតធ្វើអី ។ អានេះខាងកាណូតទាំងអស់ ។ ហើយមកកន្លែង កន្លែងសិប្បកម្ម កន្លែងក្រឡឹង ។ កន្លែងក្រឡឹង ជួសជុល

ឡានដឹង អាវុធខូចអីមកធ្វើក្រឡឹងជួលដុលនៅហ្នឹងទាំងអស់ ។ ហើយដល់មកនេះ ហើយដល់អានេះមិនបែកទៅស្នូល ហើយអានេះមិនទៅសម្បូរណ៍ អាខាងនេះគេហៅភ្នំអី ភ្នំសម្បុក និងណា ឃើញទេ! អានេះដំបូងទៅស៊ីងត្រែង អានេះមកស្នួល ស្នួលព្រំដែនយួននោះ ។

បូលីៈ កាលហ្នឹងគណៈគ្រប់គ្រងទាំងអស់នៅក្រចេះទាំងអស់សុទ្ធតែនរតីទាំងអស់ ឬយ៉ាងម៉េច ឬមានអ្នកក្រចេះដែរអី?

សារិនៈ ទេ! ដល់ស្រុកខ្ញុំទៅគឺថាអត់ទេ ។ មានអ្នកមន្ទីរអីនោះទាំងអស់ដែលនៅក្រោមមន្ទីរ សុទ្ធតែអ្នកនៅក្រចេះ អាយើងទៅដឹកនាំបានតែប្រធាន ដូចថាឥលូវហ្នឹងអ្នកទទួលបន្ទុកមូលដ្ឋានហ្នឹងនិរតី ។ ឯអ្នកដឹកនាំកងទ័ពហ្នឹង ក៏គេមកបូកក៏ អឿងហ្នឹង មិនមែនមកពីនិរតីទេ មិនដឹងមកពីណាទេ មិនដឹងមកពីភូមិភាគណាខេត្តណាទេ ដែលមកពីឆ្ងាយដូចគ្នាណ៎ា ។ តែខ្ញុំនេះមានតែ២ទេ ខ្ញុំហើយហ្នឹងមឿននេះ ចេញពីកងពល២ ។

បូលីៈ ហើយចុះខុន?

សារិនៈ ខុននេះក៏មិនដឹងមកពីណា! ព្រោះខ្ញុំក្តាប់ប្រវត្តិគេពុំបាន ព្រោះជួបគ្នា ស្គាល់នៅហ្នឹងបណ្តោយចឹងណាព្រោះអង្គភាពខុសគ្នា ។

បូលីៈ នៅតំបន់ក្រចេះតំបន់ស្វ័យតហ្នឹងយើងរាយការណ៍ផ្ទាល់ដល់មជ្ឈិមតែម្តង?

សារិនៈ បាទ! អត់មានរាយការណ៍ទៅភូមិភាគកណ្តាល ឬក៏ទៅភូមិភាគណាទេ ភូមិភាគឦសាននេះគឺរាយការណ៍មកតែម្តង ។

បូលីៈ ស្វ័យតតាំងពីឆ្នាំណាមកអ៊ីនៅក្រចេះ?

សារិនៈ ស្វ័យតតាំងពី អាចខ្ទង់តាំងពី៧៥,៧៦ខាងលើគេត្រូវមានតំបន់មួយគេគ្រប់គ្រងខ្លួនគេ ។ បើខ្ញុំអត់យល់ទេ ពេលក្រោយមកបានដឹងថាតំបន់ស្វ័យត ។ បើគេហៅតំបន់ស្វ័យតមានខេត្តក្រចេះហ្នឹងតែមួយទេ តាំងពីដំនាន់ហ្នឹង ។

បូលីៈ ម៉េចបានជាគេដាក់ក្រចេះទៅជាស្វ័យត ម៉េចបានជាគេមិនបញ្ចូលទៅក្នុងភូមិភាគមួយណាទៅ ។

សារិនៈ អត់ដឹង! ចង់និយាយថាមានគ្រឹះមូលដ្ឋានមួយសម្រាប់គេដឹកនាំហើយគេប្រៀបធៀបហ្នឹងភូមិភាគទាំងអស់ហើយតើ អ្នកណា! បើនិយាយថាពីស្នាដៃដឹកនាំណា ជាមួយការកសាងដោះស្រាយគ្រប់បញ្ហាទាំងអស់ ។ នេះខ្ញុំយល់ដោយខ្លួនឯងទេ ប៉ុន្តែរឿងរចនាសម្ព័ន្ធគេរៀបហ្នឹងខ្ញុំអត់ដឹងគោលដៅយ៉ាងម៉េច ប៉ុន្តែខ្ញុំទៅក្រោយគេ គេហៅតំបន់ស្វ័យតចឹងទៅ ហើយរាយការណ៍គឺផ្ទាល់ ខ្ញុំធ្វើរបាយការណ៍ គឺរាយការណ៍កាលនោះ៧៨បណ្តោយ អត់មានចូលទៅណាទេ ។ ផ្ញើរមកជូនការយើងចូលមកពាណិជ្ជយើង ពាណិជ្ជយើងទូរស័ព្ទទាក់ទងជាមួយ៨៧/

ផ្ទាល់ទូរស័ព្ទខ្សែណា ។ រោទិ៍ទៅ! ហើយបាដួនការគេថា មកចាំចំណុចណាគេចាំមកយក ឬក៏គេមកយកផ្ទាល់ គេអត់ឲ្យចូលទេកន្លែងនោះ ខុសពីអ្នកហៅអត់ឲ្យចូលទេ ។

បូលី: តំបន់ក្រចេះហ្នឹងយើងហៅថាតំបន់១០៥?

សារិន: បាទ! ប៉ុន្តែខ្ញុំអត់ដឹងទេ ដឹងត្រឹមតែថាភូមិភាគស្វ័យតហ្នឹង ខេត្តក្រចេះ ។ ខ្ញុំនៅទ័ពមិនសូវដឹងថានៅតំបន់ណាៗ ។ ដឹងតែតំបន់ខ្ញុំនៅ ដឹងតែម្តងចឹងណា! មានប៉ុន្មានកងពលនៅតំបន់ខេត្តក្រចេះនោះ គិតទៅមានតែ! អត់ទេ! វរសេនាធំទេ ។ ខេត្តក្រចេះមានតែកងទ័ព ប្រចាំខេត្តក្រចេះហ្នឹង មានវរសេនាធំនែ៎!

បូលី: ប៉ុន្មានវរសេនាធំ?

សារិន: មានតែ១វរសេនាធំទេ! ប៉ុន្តែកងពលស្អីគេ១៧ រ៉ុនោះ!

បូលី: ១១៧?

សារិន: អើ! ១១៧ហ្នឹងណា៎ កងរ៉ុនោះមាន១កងពល ប៉ុន្តែខ្ញុំអត់ដឹងមានប៉ុន្មានវរសេនាធំទេណា៎ ប៉ុនមាន១កងពលបូកជាមួយក្រចេះ ដើម្បីការពារមុខសញ្ញាពីស្ទួលមកព្រំប្រទល់នែ៎មណ្ឌលគិរីណា៎ ។

បូលី: មណ្ឌលគិរី កោះញែក?

សារិន: បាទ! ហ្នឹងហើយ ។

បូលី: ១១៧ហ្នឹងជាកងពលរបស់ភូមិភាគ ឬក៏កងពលតំបន់?

សារិន: ភូមិភាគ ។

បូលី: ភូមិភាគទេនែ៎ក?

សារិន: បាទ!

បូលី: គ្រាន់តែឈរជើងនៅក្នុងខេត្តក្រចេះនេះទេណា៎?

សារិន: បាទ!

បូលី: កងពលរបស់មជ្ឈិមណា៎អ៊ីណា៎?

សារិន: បាទ!

បូលី: ឈរជើងនៅម្តុំណា?

សារិន: ឈរជើងចាប់ពីស្ទួល រហូតឡើងមកលើ ចាប់ដៃខ្ញុំនៅមណ្ឌលគិរី ។

បូលី: នរណាគេមេកងពលហ្នឹង?

សារិន: អានេះឈ្មោះរ៉ុំ ។

បូលី: រ៉ុំ?

សារិនៈ បាទ!

បូលីៈ រុំនៅតាកែវ អ្នកនិរតី ឬក៏ក្រចេះ?

សារិនៈ កំពត ។

បូលីៈ ត្រកូលគាត់អតល់គេអី រុំ?

សារិនៈ មិនបានចាំត្រកូលគេទេ

បូលីៈ អាហ្នឹងតាម៉ុកចាត់តាំងមកដែរ?

សារិនៈ បាទ! អាហ្នឹងអត់ទេ ព្រោះចេញគេកម្លាំងមជ្ឈិមគេតែងតាំងមានតែតាម៉ុកទេកងហ្នឹង ។ តាម៉ុកតែងតាំងតែកងនិរតីមួយទេ ក្រៅពីហ្នឹងរៀបរយទៅជួបគ្នាហ្នឹងបានចាប់ដៃគ្នាធ្វើទៅ ។

បូលីៈ រុំ នៅក្រោមរុំពីណា?

សារិនៈ ខ្ញុំមិនទេ! ព្រោះខ្ញុំទៅទើបតែបាន២ខែ ដែលត្រូវយួនចូល៧មករា ។

បូលីៈ ចឹងអីទៅ៧៨ចឹង?

សារិនៈ បាទ! ៧៨ខែ៩ខ្ញុំទៅដល់ ។

បូលីៈ ខែ៩ ឆ្នាំ ៧៨?

សារិនៈ បាទ!

បូលីៈ បានន័យថាចុង៧៨!

សារិនៈ បាទ! ខែ៩ ខ្ញុំទៅហើយទឹកកំពង់ពេញឡើង ខ្ញុំទៅដល់ហើយឡើងចូលក្រចេះទឹកណា ។

បូលីៈ លិចមន្ទីរទេ?

សារិនៈ បាទ! លិចចូលមកខេត្តចូលដល់ពេញទាំងអស់ឡើង លើកទី២ហើយហ្នឹងបានស្រកទៅបណ្តោយចឹងណា ។

បូលីៈ ពីព្រោះគេថាទឹកដែលធំខ្លាំងមែនទែន គឺ៧៨?

សារិនៈ ហ្នឹងហើយ!

បូលីៈ លិចភ្នំពេញទេកាលហ្នឹង?

សារិនៈ ទេ! ខ្ញុំអត់ដឹងទេ ។ វាលិច ប៉ុន្តែវាលិចដូចស្ថានការណ៍ដីលាងនោះស្អីចឹង នៅភ្នំពេញមានមនុស្សស្អី អត់មានជ្រួលច្របល់ទេណា ។ គ្រាន់តែថានៅសុទ្ធតែពួកនេះ បើនៅតាមខេត្តបានខ្ញុំ ដឹងនៅកំពង់ចាម ហើយក្រចេះហ្នឹងគឺលិច ខ្ញុំទៅដល់ហ្នឹងទឹកឡើងស្រឹតៗ បានប្រហែលហ្នឹង ១អាទិត្យគឺទឹកឡើងចូលទៅក្នុងក្រុង ប៉ុន្តែគឺរាក់ទេនៅផ្លូវ ត្រឹមជង្គង់! ហើយចាប់ស្រកវិញស្រកវិញស្រកទៅរហូតតែម្តង ។

បូលីៈ មន្ទីរដែលនៅក្រោមតំបន់ក្រចេះហ្នឹង មានមន្ទីរអីខ្លះអី?

សារិនៈ មន្ទីរពាណិជ្ជកម្ម មន្ទីរកាត់ដេរ តម្បាញនៃ! មន្ទីរពេទ្យ ។

បូលីៈ ពាណិជ្ជកម្ម, មន្ទីរពេទ្យ, កាត់ដេរ, តម្បាញ!

សារិនៈ ហើយកន្លែងមន្ទីរដឹកជញ្ជូន កន្លែងធ្វើឡានធ្វើអីហ្នឹងផង ។

បូលីៈ ដឹកជញ្ជូន ឬក៏ធ្វើឡានអី?

សារិនៈ ទាំងអស់! ដែលថាពួកដឹកជញ្ជូនវាបង្កើតជាផ្លូវសដុលឡានហ្នឹងបណ្ដោយចឹងណា៎!

បូលីៈ មានអីទៀតទេអ៊ី?

សារិនៈ ឧស្សាហកម្ម! ឧស្សាហកម្មហ្នឹងវាមានការដឹកជញ្ជូនខាង ចឹងទឹកហ្នឹងមកគ្នាពួកកាណូតហ្នឹងតែម្ដង!

បូលីៈ ខាងជើងទឹក?

សារិនៈ បាទ! ខាងជើងទឹក ។

បូលីៈ មានអីទៀតទេអ៊ី?

សារិនៈ ហើយមន្ទីរសិប្បកម្មខាងជាក្រឡឹងនោះ ខ្ញុំភ្លាប់បានប៉ុណ្ណឹងទេ ហើយមន្ទីរកាត់ដេរក៏មានហើយ មន្ទីរតម្បាញក៏មានហើយ!

បូលីៈ មន្ទីរមួយៗសុទ្ធតែមានមេដឹកនាំ?

សារិនៈ មេដឹកនាំ!

បូលីៈ អ៊ីចាំទេពាណិជ្ជកម្មពីណាគេ?

សារិនៈ ពាណិជ្ជកម្មខាងជើងទឹក កាលនោះតាមខ្ញុំចាំឈ្មោះ តាឃុន ។

បូលីៈ តាឃុន?

សារិនៈ បាទ!

បូលីៈ អ្នកក្រចេះ ឬអ្នកណា?

សារិនៈ នៅហ្នឹង! ខ្ញុំទៅជួបនៅហ្នឹងបណ្ដោយ ។

បូលីៈ ចុះបន្ទាប់មកទៀតកាត់ដេរ?

សារិនៈ កាត់ដេរឈ្មោះស្រី, ឈ្មោះរ៉ែម ។

បូលីៈ អ្នកក្រចេះដែរ ឬ?

សារិនៈ មិនដឹងទេ! មិនដឹងមកពីណា ។

បូលីៈ តម្បាញអ៊ី?

សារិនៈ តម្បាញឈ្មោះ វ៉ាន់ ពីមុនហ្នឹងខ្ញុំទៅហ្នឹង ដូចឈ្មោះ វ៉ាន់ ។

បូលីៈ មន្ទីរពេទ្យ?

សារិនៈ មន្ទីរពេទ្យរបស់ហ្នឹង! ខ្ញុំអត់ភ្លេចឈ្មោះគេប៉ុន្តែ បើឡានខ្ញុំដឹង ឈ្មោះ ឆនៗ

បូលីៈ ឆន ខាងដឹកជញ្ជូនណ៎?

សារិនៈ បាទ!

បូលីៈ សិប្បកម្ម?

សារិនៈ សិប្បកម្មវាជាប់ជាមួយដឹកជញ្ជូន វាអត់បានដិតដល់ចង់និយាយទើបទៅហើយការងារវាច្រើន ពេកខាងមុខវារញ៉េរញ៉ៃណ៎ ដល់ចឹងរួមខាងមុខពេក ក៏កន្លែងសាំងនោះ មន្ទីរកន្លែងសាំងនោះ ឈ្មោះញ៉ៗ អាហ្នឹងគ្រប់គ្រងខាងសាំង ខាងប្រេងៗ ដឹកពីកាណូតហ្នឹង មកដាក់នៅសាទែន ធំៗ ។

បូលីៈ ដឹកពីភ្នំពេញមក?

សារិនៈ ពីភ្នំពេញមក ។

បូលីៈ ចឹងអ៊ីៗ សុទ្ធតែផ្គត់ផ្គង់ពីភ្នំពេញ?

សារិនៈ ភ្នំពេញទាំងអស់ ។

បូលីៈ យើងឲ្យអ៊ីទៅមជ្ឈិមវិញ?

សារិនៈ ឲ្យចេញទៅវិញខាងឈើត្រូវការ ជួនការត្រូវការឈើ ចឹងទៅកាត់ដាក់ចងជាក្បូនតូបណា ហើយយកឈើមូលទៅ បណ្តែតកាណូតនាំណ៎ អាហ្នឹងខាងលើកុម្មង់ ប៉ុន្មាន រកបានគ្រប់ បានហើយបាននាំទៅ ទៅដល់កំពង់ចាមគេយក នាំទៅត្រង់នេះទៅតែប៉ុណ្ណឹងៗ

បូលីៈ យកឈើទៅណាមជ្ឈិម?

សារិនៈ គាត់យកទៅអាសម្រាប់សាងសង់ធ្វើទៅតាមតម្រូវការ តែពុំមែនយកទៅលក់ដូរនោះទេ ជំនាន់ ហ្នឹងគេលក់ដូរព្រោះអីទៅធ្វើនៅមូលដ្ឋាន ព្រោះភូមិតាមសហករណ៍មួយៗចេញពីផ្ទះពីសម្បែង មកធ្វើសហករណ៍ រឿងនេះ ហើយកងកន្លែងទីវស័យគ្រប់កងទ័ពទៅធ្វើ ឬមួយមន្ទីរអីចឹងទៅ ណ៎! ហើយគេនាំទៅ ប៉ុន្តែការពិតគឺយកទៅអារៗ

បូលីៈ ចឹងពេលហ្នឹងយើងមានតែបីស្រុកទេអី? មានប៉ុន្មានស្រុក?

សារិនៈ ស្រុកន៏កសម្បូរណ៍ ស្រុកស្នួល ស្រុកក្រចេះ ឆ្លូង ហើយហ្នឹងស៊ីងត្រង់ ៥ណ៎!

បូលីៈ ចុះឆ្លូងក្រែងគាត់ចូលទៅបូព៌?

សារិនៈ អត់ទេ កាលជំនាន់ហ្នឹងនៅ ។

បូលីៈ ព្រែកប្រសប់ក្រែងយើងគាត់ចូលទៅកណ្តាល?

សារិនៈ អត់ទេ! កាលជំនាន់ពួកខ្ញុំនៅ មិនទាន់កាត់ឯណាៗ

បូលីៈ ចឹង?

សារិនៈ បាទ! កាលពីសម័យមុនហ្នឹងនៅទេ! ទើបក្រោយនេះទេដែលកាត់នោះ បើពីមុនក្រចេះគឺ៥ រាប់ពីលើព្រែកប្រសប់ ឆ្លងនេះ ហើយស្រុកក្រចេះ ក្រចេះហើយស្រុកស្នួល ស្នួលហើយ សម្បូរណ៍ ៥!

បូលីៈ នរណាគេគណៈស្រុកក្រចេះអ៊ំ?

សារិនៈ គណៈស្រុកក្រចេះឈ្មោះ យេង ។

បូលីៈ យេង!

សារិនៈ បាទ! ប៉ុន្តែស្លាប់បាត់ហើយ មិនចង់និយាយរឿងអ្នកស្លាប់នោះ ។

បូលីៈ យេង នោះកាន់ពីណាមកណា?

សារិនៈ យេង តែខ្ញុំមិនដឹងទេ! ចេញពីអង្គភាពផ្សេងទេ មានមកពី(ស្តាប់ពុំបាន) ។ ប៉ុន្តែមកពីក្រៅទាំង អស់ ។

បូលីៈ អត់មានអ្នកស្រុកហ្នឹងទេ?

សារិនៈ ហ្នឹងហើយ!

បូលីៈ ចុះគណៈស្រុកសម្បូរណ៍អ៊ុំ?

សារិនៈ គណៈស្រុកសម្បូរណ៍ឈ្មោះរឿន ។

បូលីៈ អ៊ំដែលឮឈ្មោះ តា ចែក?

សារិនៈ ចែក?

បូលីៈ បាទ! ចែក ប្រាក់?

សារិនៈ អត់!

បូលីៈ រឿន អ្នកតាកែវដែរ?

សារិនៈ អត់ទេ! រឿន អ្នកកំពង់ស្ពឺ ។

បូលីៈ អ្នកកំពង់ស្ពឺ?

សារិនៈ បាទ!

បូលីៈ គណៈស្រុកស្នួល អ៊ំស្គាល់ទេ?

សារិនៈ ស្នួល! ទេ ឥលូវសល់តែអភិបាលរងខ្ញុំស្គាល់ មួយដូចជា ភណ្ឌ ណា! ប៉ុន ស្លាប់ហើយទេ ។ ភណ្ឌស្លាប់ ប៉ុនបន្ទាប់មក ក្រែម ។!

បូលីៈ ហ្នឹងអ្នកមកពីនិរតីដែរ?

សារិនៈ បាទ! ប៉ុន្តែគេមកមុនណាស់ កាលហ្នឹងនៅអង្គភាពខុសគ្នាទេ ប៉ុន្តែមកពីនោះវាមកជួបអង្គភាព ប៉ុនវារៀបរយទៅ ប៉ុន្តែចេញពីអង្គភាពខ្ញុំដំណាលកងពលទី២គឺអត់ទេ គេមកមុនគេចូលអស់ ។

បូលីៈ  គណៈស្រុកសម្បូរណ៍ ពីមុនខាងនិរតីចូលមក គឺតា ចែក? តាចែកគឺល្បីថាខូចសីលធម៌ មានស្រីច្រើនណាស់រាប់រយនាក់ ។

សារិនៈ អាហ្នឹងខ្ញុំអត់ដឹងទេ ខ្ញុំមកអត់ទាន់បើអត់ដឹងចឹងនិយាយអត់កើត បើថាដឹងបាននិយាយ បើថាអត់ដឹងមិនដឹងនិយាយថាម៉េចហើយនិយាយប៉ាតណាប៉ាតណីអស់ ចេះតែខុសជួនកាលអត់មានផងចេះតែថាដូចមនុស្សខូចគ្នាកើតដែរ ចឹងដូចវាយប្រហារ ។ នេះខ្ញុំដាក់ស្អែងហ្នឹងទើបមកចឹងមកបានសភាពការណ៍ចូលព្រៃដែរ ។

បូលីៈ  នរណាវាយចូល?

សារិនៈ អាខាងវៀតណាមវាយចូល មកនេះមកដល់ខេត្តក្រចេះ នឹងប្រពន្ធខ្ញុំបែកគ្នា ។ ខ្ញុំនិយាយតិចមុនហ្នឹងសភាពការណ៍ដល់ ខ្ញុំគឺត្រូវស្លាប់ហើយ ខ្ញុំនិយាយត្រង់ គឺអ្នកដឹកនាំត្រូវយកខ្ញុំ គឺដាក់យន្តហោះម៉ោង៧ ពីរនាក់ផង ។ ផងហ្នឹងវរសេនាធំ ថាយកមកដាក់នៅពោធិ៍ចិនតុង ។ ផងហ្នឹងគឺប្អូនរិន, រិនហ្នឹងកូនប្រសារតាម៉ុក ។ ដល់ចឹងទៅពីរនាក់ហ្នឹងមក អត់ដឹងសាច់រឿងព្រោះមឿនគេយកមកមុន រុំគេយកមកមុនបាត់ យកមកភ្នំពេញណា! យកមកបាត់ ដល់បាត់ចឹងបានគេទឹកចុងក្រោយហ្នឹង គេយកខ្ញុំមកហ្នឹង គឺដោយការរៀបរយក្រោយ គឺមានញ៉ាន់នេះ , ទី, ភាព នឹងទៅ ទៅៗធ្វើការមួយរយៈហ្នឹង ខ្ញុំអត់ដឹងហើយខ្ញុំមនុស្សមិនចេះខ្លាច ខ្ញុំចង់និយាយថាការពិតប្រឹងធ្វើត្រង់ ប៉ុនធ្វើៗម៉េចខ្ញុំមិនដឹងទេ ព្រោះផែនការណា ដល់គេហៅខ្ញុំទៅជួប នៅឯទីរួមស្រុកក្រចេះហ្នឹង អាហ្នឹងសាលាស្រុកចាស់គេនោះ គេសួរ គេសួរខ្ញុំថា គេថាខ្ញុំបងៗ បងអត់ដឹងអីទេ? ទេដឹងអី ដឹងតែខាងលើតែម្តង ចឹងណា! ឥលូវហៅមកខ្ញុំដឹងតែមកដឹងរឿងអី! ថាអត់ខ្លាចទេអី? ទេ! ដល់ដំណាក់កាលនេះហើយសមរភូមិមិនខ្លាចផង ខ្លាចអីអាសភាពការណ៍ចេះ និយាយចឹង ខ្ញុំអត់ខ្លាចទេ ប៉ុន្តែការពិតគេហៅខ្ញុំទៅ ដល់បាន២ថ្ងៃ គេខទ្មេសនាមថាកុហកខ្ញុំ ខទ្មេសនាមថាឲ្យមកក្រចេះដើម្បីរៀបចំពាណិជ្ជកម្ម ។ កន្លែងពាណិជ្ជកម្មនៅក្រចេះនេះឲ្យបានល្អ ព្រោះអ្នកដឹកនាំហ្នឹងចាត់ចែងដូចជាខុសចឹងណា ដល់ចឹងសុំឲ្យខ្ញុំទៅរៀបប៉ុន្តែតាមពិតកុហកខ្ញុំទេ ។ គេដាក់ឲ្យជិះយន្តហោះមក ខ្ញុំនៅពោធិ៍ចិនតុង៥ថ្ងៃ ។

បូលីៈ  នរណាអ្នកបញ្ជូនមក?

សារិនៈ បញ្ជូនមកហ្នឹងអត់ទេ ខាងលើសម្រេច! គេនោះទេគេធ្វើការនៅហ្នឹង គេមិនរាយការណ៍ រាយការណ៍ខាងលើគេមិនសម្រេចឲ្យដកខ្ញុំមក ខ្ញុំអត់ដឹងថាអ្នកណាៗទេ ប៉ុនពីសម័យខាងលើឲ្យឋានៈយើងនៅគ្រប់គ្រងហ្នឹង ម្លោះហើយទាល់តែខាងលើអ្នកសម្រេច ។ គេប៉ុនណាដល់សភាពការណ៍គេឲ្យទៅ គ្រាន់តែគេរាយការណ៍ទៅខាងលើពីសកម្មភាពយើង ។

បូលីៈ  ពីណាអ្នករាយការណ៍?

សារិនៈ ខ្ញុំអត់ដឹង! ប៉ុន្តែខ្ញុំដឹងថាគេរាយការណ៍ ព្រោះគេទៅ ។

បូលីៈ បន្ទាប់ពីចាប់រៀន ហើយហ្នឹងរុំមកពីណាគេអ្នកមកជំនួស?

សារិនៈ មកដូចខ្ញុំនិយាយចឹង! ឈ្មោះ តា ញ៉ាន, តា ទី, ហើយហ្នឹងភាព ។

បូលីៈ ញ៉ាន,ទី,ភាព ។

សារិនៈ ភាព ហ្នឹងគេមកជំនួសផ្នែកកងទ័ព ឯទីហ្នឹងគេមកជំនួសមូលដ្ឋានហ្នឹងណាមើលការងារចាត់ចែងគេធ្វើ ខ្ញុំអត់ដឹងទេ ដល់ចឹងបានគេហៅមកភ្នំពេញខ្ញុំសុំនេះ សៀវភៅគេ បីថ្ងៃខ្ញុំសួរគេអូន ។ ខ្ញុំឆ្ងល់ ថាឲ្យខ្ញុំមករៀបចំទីនេះ ប៉ុនយកមកទុកទីនេះ ខ្ញុំចេញទៅមុខខ្ញុំឃើញគេយាម២នាក់ទៅក្រោយបីនាក់ ហើយខ្ញុំឆ្ងល់ខ្ញុំសួរ ។ ដល់សួរចឹងទៅគេថា ខ្ញុំអត់ដឹងទេ គេឲ្យយាមចេះតែយាមទៅចឹងណា ។ ហើយចឹងខ្ញុំថាទេ! ខ្ញុំដូចជាឆ្ងល់ ប៉ុន្តែដល់ពេលជំនាក់កាល ចុះដើងនៅរួមដើរឈើប្រត់ម្ចាង ។ ដល់ចឹងទៅចេះតែឆ្ងល់ ដល់គេថាចាំខ្ញុំគេសួរខាងលើរាយការណ៍ជូនខាងលើ តើដោះស្រាយខាងម៉េច ដល់ចឹងទៅស្អែកឡើងបាន ឃើញគេមក គេមកនាំយកសៀវភៅអា១០០ទំព័រ ២ច្បាប់ ចុះពីរនាក់ ។ អាផេងវរសេនាធំ១បន្ទប់ ហើយខ្ញុំដេក១បន្ទប់ ។ ប៉ុន្តែគេខបត្តម្តកន្វែងតុអង្គុយហ្នឹង និយាយពីទឹកដោះគោ ស្ករស ទឹកក្រូចអីហ្នឹងបារីជាកញ្ចប់អស់អីថែមហ្នឹង ។ រួចទៅខ្ញុំដោះស្រាយ ចឹងគេដាក់ហ្នឹងខ្ញុំសរសេរបណ្តោយ ។ សរសេរប្រវត្តិដូចអូនឯងមកសម្ភាសន៍ចឹង ។

បូលីៈ អ៊ូ! គេឲ្យសៀវភៅយកមកកសរសេរ?

សារិនៈ បាទ! សរសេរចង់និយាយយើងចង់រាយការណ៍ពីរឿងអីៗ ប៉ុនឲ្យខ្ញុំរាយការណ៍ ខ្ញុំសរសេរប្រវត្តិខ្ញុំរឿងបញ្ហាខ្ញុំធ្វើជាក់ស្តែង ហើយចុងបញ្ចប់ខ្ញុំថាបណ្តោយ ខ្ញុំថាខ្ញុំអើ! ពីមុនគេហៅថាបក្ស ខ្ញុំជាកូនបក្ស ដូចនេះជីវិតខ្ញុំ គឺខ្ញុំប្រគល់ជូនបក្សទាំងអស់តាំងពីខ្ញុំចូលតស៊ូរហូតខ្ញុំអត់យល់អី រហូតដល់ខ្ញុំក្លាយខ្លួនជាសមាជិកបក្សបានតួនាទីដឹកនាំកម្លាំង ហើយខ្ញុំប្រគល់ជូនបក្សហើយគ្រប់សមរភូមិទាំងអស់ គឺខ្ញុំត្រូវគេប្រយុទ្ធ ។ ប្រយុទ្ធមានតែ២ទេ មួយដើម្បីជាតិមួយប្រជាជនហើយហ្នឹងបក្ស តែប៉ុណ្ណឹងឯង ។ ហើយដល់ពេលចុងបញ្ចប់ នែ៎ឪខ្ញុំទៅក្រចេះខ្ញុំអត់ទាន់ដឹងអីលិច អីកើតផងនៅវង្វេង មិនដឹងលិចកើតអីណាផង ។ ដល់ថ្ងៃរះបានដឹងថាអីនោះអីកើតនោះ ប៉ុនថាឯងថាអីលិច ។ ហើយចុងបញ្ចប់ខ្ញុំរីករាយសប្បាយណាស់ ប៉ុនគ្រាន់តែថាខ្ញុំអត់មានគថ្ងៃមួយមាត់ទេស្រាច់តែបក្សវិនិច្ឆ័យ ។ ប៉ុន្តែករណីទាំងអស់ដែលធ្វើនេះ ខ្ញុំគ្រាន់តែបញ្ជាក់ថា បើធ្វើរបៀបនេះគឺចាញ់ ។ ចាញ់ហើយ ចេះតែចាញ់មូលហេតុមកពីអី! មកពីកម្លាំងដែលស្មោះត្រង់បម្រើដឹកនាំទាំងអស់ចុងបញ្ចប់គឺរលាយ ស្លាប់អស់រលីង ហើយមេថ្មីទៅអត់ជាប់នឹងកម្លាំងប្រយុទ្ធគឺអត់បាន គឺបរាជ័យយុទ្ធសាស្ត្រ តែខ្ញុំសុខចិត្តស្លាប់ ស្លាប់ដោយ

ស្មោះត្រង់ ដែលចាត់តាំង គឺគ្មានទេ។ ខ្ញុំឆ្លើយដាក់ គឺគ្មានខុសតាម៉ុកទេឲ្យខ្ញុំទៅ ព្រោះខាងលើចាត់តាំងឲ្យខ្ញុំទៅបានខ្ញុំទៅ តែខ្ញុំទៅឲ្យខ្លួនឯងគ្មានទេ អង្គការចាត់តាំងគឺខ្ញុំអត់ ហើយចាត់តាំងឲ្យខ្ញុំធ្វើអី ខ្ញុំធ្វើហ្នឹងប្រយុទ្ធគ្រប់សមរភូមិរហូតទៅដល់ខ្ញុំពិការ រហូតដល់សព្វថ្ងៃនេះ ខ្ញុំរងកម្មទុកខ្លួនឯងដោយសារខ្ញុំស្មោះត្រង់ បម្រើ តែឥលូវបើថាម៉េចក៏បាន ខ្ញុំអត់តថ្លៃ និយាយតែមួយមាត់មែនទេ។ ហើយស្រាប់តែចុងក្រោយខ្ញុំថា ជីវិតអត់ស្ដាយទេ ខ្ញុំស្ដាយតែសាច់ឈាមបងប្អូនម្នាក់ៗ ដែលគ្នាអត់ដឹងអី ដែលស្មោះត្រង់ហើយស្លាប់។ ស្លាប់ដោយអំពើចិនខ្ញុំនិយាយឲ្យត្រង់ ខ្ញុំសរសេរគិតទៅសៀវភៅ១០០ទំព័រ ខ្ញុំសរសេរអស់ពាក់កណ្ដាលសរសេរប៊ិចណា។ គេដាក់សៀវភៅមួយប៊ិចមួយ រាប់អាដេងអត់សរសេររលីងហើយ ដល់ចិនទៅបានសៀវភៅហ្នឹងចប់ ខ្ញុំសរសេរថា ខ្ញុំបញ្ជាក់ខ្លួនឯងថាខ្ញុំអត់ក្បត់ទេ ខ្ញុំស្មោះត្រង់ ប៉ុនបើស្លាប់ក៏ស្លាប់ដោយភាពយុត្តិធម៌ បើងយុត្តិធម៌គង់តែវិនាស ខ្ញុំនិយាយចឹង។ ហើយគោរពជូនពរទៀតក្រោយ សរសេរដាក់ឈ្មោះ ប៉ុនខ្ញុំដាក់ឯម ដួល អត់មាន ឯម យ៉ែម ទេ។

បូលី: ដាក់អីគេអ៊ុំ?

សារិនៈ គេស្គាល់តែ ឯម ដួល។ ដល់ពេលចឹងខ្ញុំ ព្រលឹមឡើងស្រាប់តែគេយកសៀវភៅហ្នឹងទៅ ថ្ងៃល្ងាចនេះយកទៅមេគេ ឲ្យមេគេចឹងទៅថាព្រលឹមឡើងឃើញក្លឹងគេមក គេធ្វើនយោបាយ ទាំងម្ហូបចំណីអី គេមកដាក់ឲ្យហូប មកប្រាប់ថាថ្ងៃរសៀលបងចេញទៅ កន្លែងពាណិជ្ជក្រចេះ ចឹងណា! ហើយខ្ញុំចេះតែចាំមើលទៅអត់មាន មានតែខោអាវមួយកំប្លេកាលហ្នឹងណា ពីរនាក់ប្ដីប្រពន្ធ។ សួរប្រពន្ធខ្ញុំ?

បូលី: ប្រពន្ធពូទៅដែរ?

សារិនៈ អត់ទេ! ប្រពន្ធខ្ញុំនៅឯក្រចេះ ខ្ញុំយកទៅក្រចេះ។

បូលី: ចាប់តែអឹមកទៅទេ?

សារិនៈ យកទៅដាក់កន្លែងអប់រំ ហើមក្អែកប៉ុនៗកដៃ។ សួរ! ទាំងប្អូនទៀតខ្ញុំយកប្អូនទៅ យំទាំងបងទាំងប្អូន នាំគ្នានិយាយដល់ពេលហើយណាស់! ប៉ុនខ្ញុំដោះស្រាយចប់ ចឹងគេបញ្ជូនខ្ញុំ ហូបបាយទៅកន្លែងគេហ្នឹងគេចេញពីកន្លែងនេះ។ អាដេងនៅហ្នឹង គេយកតែខ្ញុំទៅ ហូបបាយហើយគេនិយាយគ្នា ខ្ញុំនឹកឃើញអាននយោបាយ និយាយទៅមិនជឿទេ ដាក់ស្ដែងដល់នោះបានខ្ញុំជឿ។ បើថាឲ្យខ្ញុំរត់មិនជឿទេ! តែថាអត់ទេ កុំធ្វើនយោបាយអត់ជឿទេ។ ប៉ុននឹងខ្ញុំចិត្តថាគេនិយាយយ៉ាងម៉េចជឿទេ ស៊ីៗទាំងចប់ ចង់និយាយថាខឹងណា! អត់មានក្លាចស្លាប់ទេ ប៉ុនខឹង ដល់ខឹងវាចប់ណាំ។ ចេញទៅកន្លែងកងពលគេចឹងទៅ ចេញកងពល ដល់គេនាំទៅវត្តភ្នំ

ទៅមាត់ទន្លេមុខវាំងបានចូលទៅពាណិជ្ជ ជិតយប់! គ្រាន់តែទៅដល់អូនអើយ! ប៉ុនគេមករាវសួរដល់នៅ ដល់ហើយ គ្រាន់តែដល់ថា ស្អែកសូមមិត្ត និយាយ ផ្ទាល់ហ្នឹងណា!

បូលីៈ ប៉ុល ពត?

សារិនៈ ប៉ុល ពត និយាយផ្ទាល់ហើយហ្នឹង សូមមិត្តទៅក្រចេះវិញ រៀបចំឡើងក្រចេះ សភាពការណ៍អស់ពីមុខគ្រប់គ្រងអត់បានទេរញ៉េរញ៉ៃខ្លាំងណាស់ សូមមិត្តត្រលប់ហើយទៅតាមយន្តហោះ ។ ម៉ោង៧ព្រឹកទាក់ទងសុំសំបុត្រនៅទីចាត់ការហ្នឹងហើយ យន្តហោះបញ្ចេះចាំខ្ញុំរហូត ។ ខ្ញុំទៅសុំសំបុត្របាន យន្តហោះត្រូវឡើងហើយ អត់ឲ្យឡើងទេ ចាំទាល់តែខ្ញុំទៅ ។ ឡើងជូនទៅដល់ឡើងយន្តហោះទៅហើយ នឹកឃើញថា ទៅងាប់នៅក្រចេះល្អជាង ។ ដល់ក្រចេះទៅជួបកាំភ្លើងធំអី គេហ្នឹងគេដាក់ខ្ញុំចេញទៅកន្លែងគេ គេឲ្យហូបនំបញ្ចុក ល្ងាចបានគេដឹកមកកន្លែង ប៉ុនចៃដន្យពួកពេទ្យដែលដឹកអ្នករបួសយន្តហោះទៅមិនដឹកអ្នករបួសមកពេទ្យ ខ្ញុំឃើញ ខ្ញុំមកប្រាប់ពូមកវិញមកក៏ឡើងខ្វុរខ្វារពេញកន្លែងនេះ ខ្ញុំក៏មកវិញមកទៅធម្មតា អាសេអ៊ុមចេះតែនៅហ្នឹងក៏គេយកអស់ យកហ្នឹងមានអាសៀន មានកបគេនៅជំនួសកន្លែងខ្ញុំគេយកអស់ គេមកពីកន្លែងជាមួយថ្មីនោះ ជាមួយពួកទី ជាមួយពួកញ៉ាន់ហ្នឹង អាភាពហ្នឹង គេដកអស់នៅសល់តែកង់កង់អត់ហ្កាច់ហ្កោ កង់តួប្រុសមួយសឹកអាជើងច្រើនធាក់ឲ្យពេញទឹកពេញដីហ្នឹងតែម្តង ដើរអត់បាន៥ថ្ងៃ ៥ថ្ងៃគត់ សភាពកាប្រែប្រួលខ្លាំងណាស់ ។

បូលីៈ ចុង៧៨ ហើយពូ? វៀតណាមកំពុងវាយចូលហើយ?

សារិនៈ បាទ! បុកចូល ចូលស៊ើបការណ៍ដល់ក្រុងក្រចេះក្រុងអីណា ។ អាហ្នឹងបត់បូកមែនទែនណា! ដល់ចឹងខ្ញុំក៏ពិភាក្សា កាលហ្នឹងឈ្មោះ អៀង១ និយាយថាគាត់ប្រធានយុវជននៅកន្លែងពិភាក្សាគ្រប់មន្ទីរទាំងអស់ ពិភាក្សា១រៀបកម្លាំងទ័ព បានមួយវរសេនាធំការពារក្រុមឲ្យអៀងហ្នឹងអ្នកគ្រប់គ្រង ហើយអាវុធនៅឃ្លាំងរំសេវដើរយកទាំងអស់ ហើយរៀបទៅ! ការពារ គិតទៅការពារបានមួយអាទិត្យ ប៉ះគ្នារហូតបន្តិចប៉ះទាំងយប់ណាស់ ចុលវាយគ្នា ប៉ះគ្នាហើយមករាយការណ៍ យប់ចឹងមានកម្លាំងអីចូលចឹង ។ ហើយចូលដឹងយ៉ាងម៉េចទេ ដល់ចឹងខ្ញុំរៀបពីរវស័យហ្នឹងថាផ្លូវទីនេះ ឡានប៉ុណ្ណេះ១ ផ្លូវអន្លក់ក្នុងមួយឡាន៤បាវ ឲ្យរៀបអង្ករណាកិនទុកហូបនោះ ឲ្យរៀប៤បាវ នៅក្នុងនោះប្រេងម៉ាស៊ូតមួយប៊ីយម៉ាស៊ូត បើសាំងគឺប្រេងមួយប៊ីយ ។ ហ៊ូ! ប្រេងម៉ាស៊ីនអីស្រគួរហើយទុកឲ្យហើយនៅហ្នឹងគ្រុប ហូបចុកអីដាក់នៅហ្នឹងបានជិះប៉ុន្មាននាក់ស៊ីឡានហ្នឹង រៀបចំទៅធ្វើដំណើរចេញ ។

បូលីៈ ចេញទៅណាវិញ?

សារិនៈ ចេញទៅខេត្តស្ទឹងត្រែង ។ ចុះឆ្លងនេះម៉េចកើតបើកាណូត អាកាលធ្វើអា៣៥០ហ្នឹង អត់ទាន់កាលហ្នឹងកើលក្តា ឆ្លងជិះឡានតូច ឡានធំរបស់មូលដ្ឋានណា ។

បូលីៈ ឆ្លងពីក្រចេះ ទៅដល់ត្រើយម្ខាងណា?

សារិនៈ ឆ្លងទៅព្រែកាប់ ។

បូលីៈ ទៅធ្វើអីព្រែកាប់?

សារិនៈ ឆ្លងទៅត្រើយកាលហ្នឹង ។

បូលីៈ ដើម្បីឆ្ពោះទៅខាងណាវិញ?

សារិនៈ ឆ្លងចឹងទៅកំពង់ធំ មិនចឹងភ្នំដី! ដើម្បីអីឲ្យវាផុតពី ឲ្យបានទន្លេខាងនោះទៅយើងទៅនោះទៅវាគ្រាន់ណាស់ ឆ្លងពីផ្លូវលិច ទៅខាងទន្លេ ។

បូលីៈ ពីរហ្នឹង មានទិសដៅពីលើបញ្ជាបានទេថា ត្រូវទៅខាងណាៗ?

សារិនៈ អត់ទេ! សភាពការណ៍ប្រជាជនជ្រួលច្របល់ហើយ ដល់ចឹងប្រជាជនគ្រាន់តាដោះស្រាយអត់បាច់នរណាបញ្ជាទេ ព្រោះយើងនៅក្នុងមូលដ្ឋាន ដល់ចឹងមានតែសំនូមពរប្រជាជនថាត្រូវធ្វើម៉េចឲ្យឯករាជ្យក្នុងរយៈប៉ុន្មានថ្ងៃ កាលហូបចុកហើយ បើសិនវាដោះស្រាយធូរវាចូលល្អខាងនេះបើអត់ទេ អាហ្នឹងដោះស្រាយទៅតាមដំណើរហើយ ។ នេះសភាពការណ៍ប៉ុន្តែ កុំឆ្ងល់ឆ្ងាត់នៅកន្លែងណា គោរពមូលដ្ឋានហ្នឹង ចូលទៅមូលដ្ឋានណាឲ្យគេដោះស្រាយរឿងហ្នឹងទៅដោះស្រាយជាបន្ទាន់ ប៉ុន្តែខ្ញុំទៅហ្នឹងក្នុងនាមត្រលប់ទៅវិញ មិនមែនក្នុងនាមជាអ្នកដឹកនាំទេ ព្រោះអីវាអត់ន័យដែលយើងមកបំពេញហើយ ដល់ចឹងខបសគ្គត្រូវតែចាត់ចែង ចាត់ចែងហើយ ពួកនោះត្រូវតែឯកភាព ។ គិតទៅឡាន៨៧គ្រឿងត្រូវដក ឡើងទៅក្រចេះណា ឡានដឹកសម្ភារ ខោអាវកាត់ដេរហើយស្រេចនៅឃ្លាំងប្រមូលដឹកអីទាំងអស់សម្រាប់សមរភូមិមុខទ័ពអី ដឹកទៅអីណាមិនអស់ទុកយកទៅ យកទៅដល់ស្ទឹងត្រែងខបសគ្គហ្នឹង ។ ដល់ស្ទឹងត្រែងហើយឆ្លងស្រឡាង ស្រឡាងដែកគេហ្នឹង ។ ឡើងម្តងបានឡានពីរ ឡានយើងមួយឡានគេមួយ (ស្តាប់ពុំបាន) ហើយចឹង បានតែពីរទេណា ។

បូលីៈ ឆ្លងពីស្ទឹងត្រែងទៅថាលាបរិវ័ត?

សារិនៈ ឆ្លងពីត្រើយម្ខាងទៅថាលាបរិវ័ត ធ្លាក់ទៅខេត្តព្រះវិហារហ្នឹង ។ ដល់ចឹងទៅ ខ្ញុំនឹកឃើញថាគេចេះមកបញ្ជូនយោបល់ ចេះចែងទៀតអីគេមកជួបជាមួយខេងដែលនៅព្រះធាតុ មន្ទីរគ្រប់គ្រងនៅខេត្តស្ទឹងត្រែង ដែលមកពី៦៤មន្ទីរកំពង់សោម កំពង់ធំហ្នឹងជួបគ្នា ដល់ជួបគ្នាពិភាក្សា ។ ពិភាក្សាមើលអាដោះស្រាយមិនចេញទេ បើដណ្តើមគ្នាយ៉ាងនេះហើយ គេទ័ពគេនេះណាហើយ ឥលូវនេះចេះ ពួកក្រចេះវាត្រូវ(ស្តាប់ពុំបាន) ទូកដំបូលទី២ហ្នឹង អាទូកដែលបាក់ក្តោង

១៥តោនៗ ១៥ តោន ហើយហ្នឹង២០តោនហ្នឹងឲ្យតែបាន២មក ហើយធ្វើម៉េចធ្វើយកមក ពួកខ្ញុំធ្វើចឹងឆ្លងមកឲ្យតែបាន២ៗ ដូចគ្នា និយាយចឹង! ក្រោយមកពិភាក្សាគ្នាជាមួយខេងហ្នឹង ខេងហ្នឹង គេសម្រេចគេថាចឹងចុះ តាមអញ ទៅតាមជិះឡានអាស៊ីប គេមួយខ្ញុំមួយណាៗ ទៅដល់អាកន្លែងមាត់ទឹកនោះ លែងយកអា២០តោនៗពីរមកបណ្ដោយ ប្រគល់ទាំងចាស់ទាំងអីមកៗ មកដល់មានណាអារស្មើរទ្រូង អារចោលខ្ទេចទុកតែដំបូលអ្នកបើកនៅម៉ាស៊ីនក្រោយៗ កាត់ទាំងអស់ កាត់ទៅមានណា ទៅដឹកឈើនៅកន្លែងអារោងគេដំឡើងអណ្ដាត យកមកដល់ចោះមើលទៅធ្វើ វាយចប់អស់ដាក់ដែកសសៃគេតែម្ដង ឡើងម្ដងពីរៗរឹង ហើយខ្ញុំបេះបានឡានដូរ អាឡានCMC អាឡានក្រោយ! ឡានអាចឹងនេះមួយ អានេះមួយ ដឹកអានេះទៅមួយ ទៅដល់ដើងទឹកចង់ក្រាបដើមឈើធំៗ(ស្ដាប់ពុំបាន) ក្បាលចុះចឹងមកក្រោម ដល់ចឹងហើយបញ្ចេះអានេះបេះតែបើកមកត្រុយ រួចដល់រុញរួច ឡើងៗទៅបេះទម្លាក់មកក្រោម អានោះបេះតែទៅ គិតទៅបានឡាន១៧ៗ

បូលី: សល់តែ៤៧?

សារិន: បានឡានតែ១៧?

បូលី: ចឹងនៅសល់តែ៣០?

សារិន: នៅសល់តែ៣០ក្រោយមកចម្លងឡើងទៅ បានអាស៊ីបខ្ញុំចុងក្រោយបង្អស់គេវិញៗ អានោះផ្លោងដល់ ក្រុមចូលដុតផ្ទះឆេះអស់ក្រុមស៊ីងត្រែងនេះ យួនចូលដល់ៗ

បូលី: ចឹងយើងរត់នេះប្រភិតមែនទែន?

សារិន: បាទ! ខ្ញុំរត់ពិបៗចឹងណា! យើងផ្សងគ្រោះថ្នាក់ ដល់ចឹងខ្ញុំសម្រេចចិត្តថាឥលូវ ពួកតែកុងឡានទាំងអស់ដៃឡាននោះ ហើយសម្ភារនៅពេញឡាន ចឹងខ្ញុំថាអត់ទេអូន សម្ភារនោះមិនអត់រស់ទេ កាលហ្នឹងអង្ករ អាហ្នឹងបបួលទៀតនៅស្រឡាងយើងមកដាក់ហើយលើកអង្ករដាក់ យើងឡើងទៅនេះទៅ ដាក់ឡាន វាដាក់៣ ទៅ៤ឡានទៅ ទៅដល់នោះស្រាយអង្ករចែកគ្នាទៅ ហើយដាក់ឡាន យើងទៅ បើដឹកមិនទាន់ទេវរៈៗចែកគ្នាមកដឹកទៅ ដើម្បីរស់ វាបេះដោះស្រាយយកទៅអាហ្នឹងស៊ី ដល់ណាក៏ស៊ីបានដែរៗ ក៏ដឹកទៅតាមភូមិ (ស្ដាប់ពុំបាន) សែងអង្ករដាក់តាមផ្ទះ សែងម៉ាស៊ូត សែងសាំងមួយ អូសមកអត់ប្រើទេ! មករត់តាមឡាន ឥលូវទៅភ័យអីឡានណាគេមានតាមឡានហ្នឹង ឥលូវបើអស់ចាំយកបុងពីសាទែនៗ នឹកឃើញចលនា គិតទៅទៅ ដុតឡានចោល មិនជិះតែម្ដង ខ្ញុំថាអត់ឲ្យប្រើទេៗ ដូចនេះលេងទាញភួយមក ហើយឡានម៉ាស៊ូត បើកប្រេងម៉ាស៊ូតបង្ហៀរដាក់តែម្ដង កន្លែងដោតទាំងអស់ លីតែអង្ករហើយគ្រប់ឡានទាំងអស់ ខ្ញុំអាណិតតែកុងឡាន អាខ្លះជិះអត់ទាន់គេនោះដែរ ដុតឡានចោលឡើង

ងងឹតមេឃ ដល់ចឹងបានថាទៅយប់នោះបានមកៗ ស្រង់យកគ្នាទៅ ដុតហើយ ដុតចោល បណ្តាយ ៗ ទៅដេកនៅឯជិតដល់ឆែប ភូមិអីនៅព្រៃ ដឹកកម្លាំងនៅលើឆ្លងអារូបព្រះគោរូប ចម្លាក់ពីថ្ម ថ្មជាព្រះគោព្រះកែវ ទៅដាក់អីវ៉ាន់មកហ្នឹង ខោអាវទម្លាក់អីនៅហ្នឹង ក៏បកមក ដឹកមនុស្សនេះទៀត ៗ ដឹកចល័តចោល២សារឡាន១០គ្រឿង២សារ ដឹកធ្លាក់ទៅដល់ពុទ្រា ហើយហ្នឹងឆែប ហួសឆែបទៅទៀត ព្រោះឆែបពុទ្រាស្ទឹងសែន ដាក់ហ្នឹងបានសម្រេចចិត្តចែក កងទ័ពក្រែងរត់មកប៉ះគ្នាអត់ធ្វើការអត់ខោអាវ ម្នាក់ក៏ឲ្យម្តុំ ១០កំប៉ុ ចែកគ្នាទៅប្រជាជនឲ្យ ក្លួយឲ្យខោអាវ ៗ ឲ្យអាវអស់នេះ ទុកតែ២ឡានទេបានខ្ញុំបែកបាក់ប្រពន្ធកូន ៗ

បូលី: ហើយប្រពន្ធកូនឆ្លងមកដែរ?

សារិនៈ អត់ទេ! ទៅស្ទឹងត្រង់ហើយដល់ចឹង គាត់នៅព្រៃប្រសប់ ខ្ញុំចេញពីនោះមកតំបន់កំពង់ធំ ៗ ខ្ញុំអត់ ដឹងភូមិសាស្ត្រហើយសមរភូមិនេះដែរ តាមផ្លូវជាតិចេះតែសួរគេ ៗ មកដល់ពេលយប់ ចេះតែស្រាប់ចេញឡានកំពង់ចាមទៅ យើងក៏ចូលដល់កំពង់ចាម ហើយក៏មកហ៊ុ! ហើយក៏ ប៉ុន្តែខ្ញុំអត់ ដឹង! ចេះតែជៀសគ្នាខ្ញុំគេថាចេះតែឆ្ងល់ ចេះតែស៊ីញ៉ូភ្លើងភ្លើបភ្លែតៗគេដឹងថា គេរត់មក អាឡានទៅណាចឹងណា! ហើយបើគេច្រលំបាញ់ខ្ញុំងាប់បាត់ហើយកាលហ្នឹង ខ្ញុំរត់ ទៅស្អីណា នោះ បានរត់ទៅដល់ផ្លូវបំបែក(ស្តាប់ពុំបាន) កំពង់ថ្មហ្នឹងណា ហើយសួរគេៗតាម ផ្លូវ ណាទៅស្ទឹងត្រង់ ៗ គេប្រាប់ទៅតាមផ្លូវនោះ ធ្លាក់ដល់ស្ទឹងត្រង់ ៗ ទៅដល់ស្ទឹងត្រង់ស្ងាត់ ជ្រៀបធ្លាក់ទៅមាត់ទឹក ដល់មាត់ទឹកហ្នឹងមើលឡានចង់អស់ប្រេង ប៉ុន្តែឡាន(ស្តាប់ពុំបាន) កណ្តាល កានដែកពីរៗជាប់គ្នាពីក្រោយ ដាក់ទៅចឹង ៗ ដល់ពេលចឹងខ្ញុំ ឡើងមកប្រេង គេកចឹងគេរកចោលដាក់ពេញៗឡានពេញអី ដាក់កានពេញអស់ ដាក់កាន៣០លីត្រមួយ ទៀត ឡើងមកជួបប្រពន្ធខ្ញុំនៅលលើ ចុះពីចម្ការកៅស៊ូមក ៗ

បូលី: មកជួបគ្នា?

សារិនៈ ជួបគ្នាញ៉ាំច់ ១៦នាក់!

បូលី: សំណាងនែស៎?

សារិនៈ បាទ! គិតទៅ១ឡាន ១៦នាក់ ឡានឡើងទួលអត់រួចទេ ៗ ឡានអាស៊ីប!

បូលី: បាទ!

សារិនៈ ចុះដើរផុតថ្មទៅបានជិះ ៗ ចតឡាននៅចម្ការកៅស៊ូ ហួសចម្ការកៅស៊ូ ចូលព្រៃអញ្ចាញ ចត ឡានហ្នឹងហើយដើរ ៗ

បូលី: បឹងកេតមែនអ៊ុំ?

សារិនៈ ទៅលើ!

បូលីៈ លើបឹងកេតទៀតអ៊ុ?

សារិនៈ ត្រូវទៅដល់ អាខ្ញុំនិយាយទៅ ដូចថាខ្លួយវាទិច ណែ៎! ពីលើចូលឲ្យគេចាក់ ផុតចម្ការកៅស៊ូទៅណា៎! ដល់ចម្ការគេកាប់ហើយ ប៉ុន្តែអត់ទាន់បានធ្វើវាតវង់ ម៉ោងវាអស់(ស្ដាប់ពុំបាន) ស្វាវនេះ ដល់ចឹងចោលឡានហ្នឹងតែម្ដងទៅ ប៉ុន្មាននាក់ដើរកាត់ព្រៃទៅជួបនៅយាកនៅក្រោអានៅត្បែងណា!

បូលីៈ ត្បែងមានជ័យ?

សារិនៈ បាទ! ទៅជួបត្រង់ទ័ពប៉ុណ្ណឹងឯង ។

បូលីៈ ចាក់ពីកំពង់ធំទៅ?

សារិនៈ បាទ! ចាក់រហូត អត់មានគាមរក កាត់ព្រៃរហូត ដល់ចេញអីផ្លូវហ្នឹងជួបវាក់អើ! ទ័ពមកបណ្ដោយពីក្រចេះមក ចុះដកពីនោះមកហើយទៅ ។

បូលីៈ ទ័ពរបស់វៀតណាម?

សារិនៈ អត់ទេ! ទ័ពយើងៗ ជួបគ្នាហ្នឹងក៏ ប្អូនៗអត់នេះក៏ពិនិត្យមើល ដល់ពិនិត្យមើលគេថាកម្លាំងដូចកម្លាំងបងឯងទៅមើល ដល់ទៅមើលស្គាល់ ស្គាល់ក៏ចេញភ្លេត ជួបគ្នាគេសែងខ្ញុំរហូតទៅ ។

បូលីៈ អឺឈឺហេ៎?

សារិនៈ ឈឺដើង! ចុះគេដើរលឿន ហើយយើងដើរយឺត គេមិនសែងៗ សែងរហូតធ្លាក់ទៅដល់អីតាំងក្រសៅ ជិតដល់ភ្នំសន្ទុក បើនិយាយគ្នាទៅគេហៅស្ទី ជិតដល់កំពង់ថ្ម តាំងក្រសាំងចឹង ហើយផ្សារតាំងក្រសាំង ។

បូលីៈ បាទ! តាំងក្រសាំង ។

សារិនៈ បាទ! ហ្នឹងហើយ(ស្ដាប់ពុំបាន) នេះហើយគេហៅតាំងក្រសៅមក ធ្លាក់ភូមិអីក្បាលអូរដូងហ្នឹងណា៎! ចេញទៅចឹងទៅ ទៅខុសនោះ ដល់ចឹងចុះពីហ្នឹងមកដល់កន្លែងហ្នឹងហើមដើង ដួលកង់ជិះកង់ៗ ចាប់ពួកនេះបានកង់មួយទាហានគេចាប់ ពួកកងទ័ពគេចាប់បានគេឲ្យកង់ជិះគ្មាននរណាដើរកន្លែងហ្នឹងអូរៗ អត់ដឹងថាអូរជ្រៅទៅដួលហើមដើង មានណាគេសែងជងទៅ ដល់កន្លែងហ្នឹងទៅលែងរួចនៅហ្នឹង បានខ្ញុំបកឲ្យវិញទៅនៅភ្នំដីប្រវត្តិខ្ញុំ ។

បូលីៈ ទៅនៅភ្នំដីវិញ?

សារិនៈ បាទ! ទៅនៅភ្នំដីវិញៗ អាហ្នឹងបានរទេះគោ ត្រង់គេលែងគោអស់ទៅ ចាប់គោបានហើយប្រជាជនដឹកហ្នឹង គាត់ឲ្យរទេះក្របីហ្នឹងបរ ដល់ចឹងចោលក្របីយកតែរទេះ ចាប់គោបានបួនទឹម១ទឹមៗ ថាលឿននោះ លឿនគោហ្នឹង! ទៅរហូតធ្លាក់ទៅមាត់ទន្លេវិញ ធ្លាក់ទៅ

មាត់ទន្លេស្រុកសម្បូរណ៍ទេណា ។ ដល់ចឹងទៅតាមមាត់ទន្លេ បានចេញមកចំភ្នំជីវិញ ក្រវិលនៅ ហ្នឹង ដល់៨៣ បានខ្ញុំឡើងមកភ្នំ ។

បូលីៈ អ៊ូ! ចឹងចន្លោះដល់ពេលដែលវៀតណាមវាយដល់ចូល៨៣អ៊ី វិលទៅវិលមកហ្នឹង?

សារិនៈ អត់ទេ! ខ្ញុំនៅឯហ្នឹងឯង នៅតែភ្នំជី ។

បូលីៈ វៀតណាមចូលអត់ដល់ទេកន្លែងហ្នឹង?

សារិនៈ ដល់! ប៉ុន្តែព្រៃចាស់ អានេះយើងគេច ។

បូលីៈ លាក់ខ្លួនក្នុងព្រៃ?

សារិនៈ ហ្នឹងៗទៅ! មានកោះជតា កោះអីត្រូវដាំស្រូវខ្លួនឯងមួយឆ្នាំៗខ្ញុំអត់ខ្វះទេ ។ បាទ! ១ឆ្នាំៗ ជួនកាល ជជ្រុកពីរនោះ ។ ចម្ការហ្នឹងទៅ មួយកន្លែងហ្នឹងដាក់ជជ្រុកមួយៗ ។

បូលីៈ វៀតណាមដូចអត់ឃើញនែកអី?

សារិនៈ ឃើញកន្លែងខ្លះក៏ឃើញ កន្លែងខ្លះក៏អត់ឃើញ ។

បូលីៈ យើងចេះតែរត់ទៀត?

សារិនៈ អត់ទេ! សភាពការណ៍ដឹង ។ ឧទាហរណ៍ អ្នកទៅធ្វើការណ៍នៅមុខ គឺគេចលនាកម្លាំងគេនោះ យើងនៅចឹង អ្នកនៅក្រោយៗកម្លាំងទ័ពទៅធ្វើការខាងមុខ ។

បូលីៈ មិនមែនមានន័យថាអឺរត់ទៅមុំពាសិន រួចហើយបានទៅមកវិញទេ?

សារិនៈ អត់ទេ! មុំពា ដល់៨៣ បានខ្ញុំឡើងទៅដល់មុំពា ។ ៨៣ហ្នឹងបានកម្លាំងដឹកជញ្ជូនប្រចាំភូមិភាគ ហ្នឹង តែពួកហ្នឹងរៀបចំឡើងដឹកជញ្ជូនទៅ ។

បូលីៈ កំលាំងអីដែលនៅមុំភ្នំជីហ្នឹង ប៉ុន្មាននាក់ពេលហ្នឹង?

សារិនៈ ខ្ញុំនៅកម្លាំងនៅវាច្រើន ប៉ុន្តែគេមុខសញ្ញាមួយក្រុមៗណា ។ អគ្គភាពខ្លះក៏បាន ២០,៣០ចឹង ទៅ គេអត់នៅមូលដុំទេ ហើយក្រុមយើងហ្នឹងមានតែគ្នា១៥នាក់ទេ ។ ស្រី២ចឹងណាស់ ប្រពន្ធ ខ្ញុំមួយហើយ មិត្តមួយនៅជាមួយ ទេក្មួយមួយនៅជាមួយប្អូនអីស្លាប់អស់ ។

បូលីៈ ចុះកូន?

សារិនៈ អត់មានកូនអីទេ!

បូលីៈ ហេងហើយអត់មានកូន ។

សារិនៈ ងងឹតភ្នែកទៅ នៅជាមួយមិត្តភក្រ្ត ហ្នឹងគេនៅជួយចឹងទៅ ខ្លះគេទៅមុខ ខ្លះគេនៅឯក្រោយ ចេះតែរកនេះរកនោះបានយកមកឲ្យចឹងទៅណាស់ ។ ចឹងទេ! រស់នៅយ៉ាងវេទនា ប៉ុន្តែអត់ទៅ ណាមកណា ។

បូលីៈ ការហូបចុក គឺយើងធ្វើស្រែធ្វើចម្ការខ្លួនឯង?

សារិនៈ កាប់ស្ពក្ការ ។

បូលីៈ កាប់ស្ពក្ការខ្លួនឯង?

សារិនៈ បាទ!

បូលីៈ អំបិលប្រហុកអីបានពីណា?

សារិនៈ អំបិលប្រហុកសំណាងណ៎ះ ២ឆ្នាំដែលថា៧៩,៨០ គេដាច់អង្កែង នៅរយៈខែ១ ខែ២ អស់អំបិលហូបណ៎ះបាទ! ខ្វះគេមានកម្លាំងទ័ពគេទៅមុខទៅ ប្រជាជនគាត់ខ្វះអំបិល បានបន្តិចបន្តួចមកហូបមក តែខ្ញុំនេះឡើងមក មកតាមអូរមកនៅនេះ ជួបការដ្ឋានសម័យគេ និយាយរួមកម្លាំងមកចាំងសរសរ និយាយទៅរាប់ពាន់ដើមសុទ្ធដើមឈើស្រគុំ វាចាំងមួយធ្វើសហករណ៍ ។

បូលីៈ ពីណាគេចាំង?

សារិនៈ សម័យសហករណ៍ខ្មែរក្រហមហ្នឹងណាគេ ដឹកនាំរៀបរយកម្លាំងគេ មកទៅតាមមូលដ្ឋានគេធ្វើនោះ ជាសហករណ៍ ។ មានណាធ្វើរោងប្រក់ដែកប្រក់អីចឹងទៅ ខាងបាយគេអំបិលបីពេលពាងស្ករហ្នឹងមួយពាង១ ។ ពាងស្ករចំហមាត់ធំ ហើយអាពាងស្រែះដាក់ស្រាពីមុននោះ ពីរស្រែះ ប៉ុនចំហចឹងទឹកពេញ ប៉ុនរត់ទៅពាងស្រែះ មួយចង្អុលដៃមួយទឹក គឺដាក់អំបិលមើលទៅអំបិលសក្បុស ហើយដល់ហើយបបួលគ្នាផ្សៀងពីរនាក់ក្មេង ពីរោងចក្រទឹកដាក់ឆ្នាំងគេគេនៅហ្នឹងទាំងអស់លាងឲ្យស្អាតអូរ ហើយយកមកចិត្តដាក់អំបិល ចាក់ទឹក ចាក់ទឹកហ្នឹងហើយយកសង្កសីប្រក់នោះ រួចចាក់អំបិលហ្នឹងហាល ហាលស្ងួតចាក់ចូលពាងស្រែះហ្នឹងវិញ ហើយសែងទម្លាក់ទុកទៅ ។ ហូបតែអំបិលហ្នឹងទៅ ហើយរំងាស់ ទឹកអំបិលគាត់ត្រូវជាម្នាក់ៗមួយគីឡូជាងងារអំបិលម៉្លងដាក់ថាត្រៀមខ្លួនបើបែកគ្នាអំបិលស៊ីទៅ ។ ពួកក្រោយខ្ញុំអត់អំបិលទេ គឺគ្រប់គ្រាន់ដោយសារបានអាហ្នឹង ហើយកាំបិតពូថៅប្រើប្រាស់អី គឺបាននៅហ្នឹង ។ កាប់ចម្ការ កាប់អីកាប់ខ្លួនឯង ។

បូលីៈ ហ៎ូ! ដូចបានជួបកំណប់ចឹងណ៎ះ!

សារិនៈ បាទ! អាយុជីវិតបានធូរប៉ុណ្ណេះ ដែលខ្ញុំកាប់ចម្ការបាន១ឆ្នាំ! ក្រុមខ្ញុំហ្នឹងកាប់បាន១ហាត់ស្រូវល្អផ្លែនោះផ្លែច្រើន ហូបអត់ដែលអស់ទេ ។ ដល់ចឹងកាប់ស្ពក្ការហ្នឹងទៅបាន គេទៅកាប់១ទៀត ។ ទៅកាប់មួយទៀតបែកការអានេះ អាមួយនោះស្លាប់ចឹងណា ។ ដល់ចឹងទៅកាប់ចម្ការកាប់កន្លែងណាដីទំនាបៗទៅកាប់ទៅហើយឈើតូចកាប់ហើយ កាប់ហើយដុតហើយដាំទៅហើយស្រូវ ។ ស្រូវកាលហ្នឹងមានពីរប្រភេទគេហៅស្រូវរាជមាសសម្រាប់ទន់ចឹងទៅ សម្រាប់ធ្វើអំបុកធ្វើអីហូបបើវាទុំថ្មី តែបើមានថ្ងៃភ្លុកហ្នឹង(ស្តាប់មិនបាន)ក៏ហូបបានឆ្ងាញ់ ។ ហើយបន្លែបង្ការអត់ខ្វះទេ ដាំខ្លួនឯង ។

បូលី៖ អ្វីខ្លះអ៊ី បន្លែបន្ការ?

សារិន៖ បន្លែមានត្រប់ មានត្រកួន មានល្ង ត្រលាច ល្ពៅ ត្រសក់ ឪឡឹក ចាប់ដាំមុនហ្នឹងដាំស្រូវ ដាំពោត ។ ដាំពោតបានដុះប្រវែងនេះមកដាំស្រូវ ដាំពោត ដាំបន្លែបន្ការនេះ ។ ដល់ធ្លាក់ភ្លៀងទៅលាស់ដាំស្រូវនៅហ្នឹង ។ បេះអស់បោចចោលអស់ស្រូវឡើង ។ នេះប្រវត្តិជួរចត់ណាស់ខ្ញុំពីដើម ។ ដល់ពេលសម័យ៧០ គេឡើងវគ្គទី១, ទី២ឡើងអស់ហើយហ្នឹង នៅតែវគ្គទី៣ហ្នឹងមក ៨៣ហ្នឹង មានកម្លាំងដឹកជញ្ជូនហ្នឹងវា៨០នាក់ ដឹកជញ្ជូនទៅសមរភូមិ ប៉ុន្តែគេអំណាចឲ្យខ្ញុំហ្នឹងគេរាប់ កម្លាំងមួយក្រុមហ្នឹងគេរាប់ឲ្យជួយខ្ញុំ កន្លែងណាពិបាកគេសែង ឬមួយក៏គ្រាគេចវេស គេចជួបខបសគ្គជាមួយយួនស្ទាក់ផ្លូវអីចឹងទៅណា ។ ដើរជាមួយគេទៅ ទៅអូសទៅកាប់ មកដល់គេហៅ ខាងនេះភ្នំដឹមកខាង កន្លែងដែលដឹកមាសដែរហ្នឹង ជួបគ្នាហ្នឹង ។ ប៉ុន្តែជួបហ្នឹងវារបៀបពួកយួនវាយ យួនតែ២ទៅ៣នាក់ទេ ប៉ុន្តែពួកកម្ពុជាហ្នឹងនៅកំពង់ធំឡើង ពួកសណ្ដាន់ សន្ទុកហ្នឹង គេចូលទៅប៉ះ ប៉ះហ្នឹងពួកដើរមកហ្នឹងគ្នាគេមួយក្រុមហ្នឹង ដើរមកយើងរាប់៤០០ ម៉ែត្រ ១គីឡូមុននោះ គេដើរទៅបានទៅខាងក្រោម ។ ប៉ះពួកហ្នឹង វាយគ្នាប្រាវ ទូងតាំង១ អាអ្នកមុខមកម្នាក់ ឬក៏២នាក់ចឹងមកប្រាប់ថាទៅចេះ អាអ្នកនាំគេចេះទៅ អ្នកនៅនោះ នាំគ្នាកាប់គ្នាទៅជួបគ្នានោះ ជួបចំណុចនោះអត់មានគេអូប្រើទេ គេប្រាប់តែចំណុចមក ។ ទៅដល់អានេះគេកាត់ទៅៗ យ៉ាងហោចទៅដល់មុនឈប់ចាំនៅនោះទៅ បើអានោះដល់មុនតិចចាំទៅ ទៅដល់ជួបគ្នាហើយ ។ ទៅដល់ដាំបាយដាំទឹកហូបទៅអីហ៎ ទៅចល័តមួយកន្លែងទៀត ចល័តទៅ ។

បូលី៖ យើងម៉េចដឹង ជាចំណុចណាជាចំណុចណា?

សារិន៖ ហ៎! ទៅតាមដែនទី ។ ត្រីវិស័យគេច្បាស់ណាស់ ហើយមួយទៀតការធ្វើដំណើរហ្នឹង គឺដឹងដល់កន្លែងគេប្រាប់ទិសដៅដែនទីគេ គេចុចមកគេដាក់ឈ្មោះ ដល់ពេលប្រាប់ចំណុចហ្នឹង ទៅចំណុចហ្នឹងហើយ ។

បូលី៖ មានធ្វើសញ្ញាដើមឈើអីទេ?

សារិន៖ អត់ទេ! សញ្ញាគឺអត់មានប្រើ គ្រាន់តែកាប់ធ្វើតំរុយ ចង់និយាយដើរកាប់ធ្វើតំរុយ មិនមែនដូចអ្នកដើរព្រៃគេកាប់ខ្លាចវង្វេងទេ តែពួកនេះគេអត់ទេ! តែកាប់គេតាមទាន់ នេះគឺអត់ទេចង់ដានតែម្ដង ។ ដូចនេះហើយពួកខ្ញុំឡើងទៅរហូត ដល់កន្លែងត្នោតអន្ទង់ប៉ាន់នេះទៅ ចូលដេកទៅព្រៃឡង់ បានយប់ហ្នឹងខ្ញុំយល់សប្តិដេកយល់សប្តិ ដេកមិនចេះចប់ ដើមកកោះប៉ុននេះហ្នឹង ហើយដើមនេះខ្ញុំនិយាយប្រវត្តិ ដើមព្រាលគុម្ពព្រាលប៉ុនៗនេះ អាដើមព្រាលធំ ដេកហើយយល់សប្តិថាអានេះដេកមិនដឹងអី ។ ព្រលឹមឡើងកាប់ស្ពាយទៅយកទៅធ្វើថ្នាំហូប គេថាថ្នាំអីថ្នាំ

បន្ទាបអីគេទេ ។ ពេលភ្ញាក់ឡើងកកោក ប៉ុនៗនេះផ្ញើរ គេហៅអាទុំដើមឈើ! បញ្ញើរក្អែក ប៉ុនៗនេះនៅដើមព្រាល ។ ខ្ញុំប្រាប់គេខ្ញុំកាប់បានតែមួយមែក ពួកនោះកាប់យកអស់រលីង កេប្រាប់ដើមកកោះហ្នឹង ។ ខ្ញុំកាប់បានដើមកកោះ វាទុំហ្នឹងអាមែកៗ គេកាប់យកអស់ បាន តែគល់វា កាប់ទៅបាន២ហ្នឹង ដើរមករហូតពីនោះ ហើយបេះប្រពន្ធនេះដាំទឹកឆ្នាំង មាន កំសៀវមានអី មានឆ្នាំងដាំទឹក កាត់យកអាផ្ញើរដើមអាព្រាលហ្នឹង ហើយស្ងោះហ្នឹងដាំ ដើរ ប្រមូល ។ ដុលឡើងភ្នំ ឡើងភ្នំស្រីៗ គេចុះកាន់មកសែងខ្ញុំអត់បានសែងទេ ខ្ញុំអត់ឲ្យសែងទេ ដើរទៅលើភ្នំដងរែកមុំបីៗ! នេះប្រវត្តិដល់មុំ៣នេះហើយដែលរដ្ឋាភិបាលវាយខាងខ្ញុំ ដែល ចាប់បានប្រពន្ធខ្ញុំជាប់គុកជាមួយកូនខ្ញុំ ។ ខ្ញុំមានកូនមួយ!

បូលី៖ ពូមានកូនហើយ?

សារិន៖ កូនខ្ញុំអាបង អាចិន ។

បូលី៖ បងគេ?

សារិន៖ បាទ!

បូលី៖ រូបនេះ?

សារិន៖ អាវៀន បរិញ្ញា ។ អានោះកូនបងបាន ១ខួប ៨ខែ វាយខ្ញុំបាញ់៨៥នោះ ។ វាយនោះ ហើយដល់ថាទៅ គេស្មុកពីក្រោយហើយថាពេលហ្នឹងចាប់ប្រពន្ធចាប់ ហើយវាបាញ់មកបុស្សិ គុម្ពបុស្សិ ដួលហ្នឹង គាត់យកតែអាប៉ុណ្ណឹងទេ គេចាប់បាន ។ ខ្ញុំមុជក្រោមទៅរួចតែឯង ចាប់ បានយកទៅកោះកន្ទុយគោ១ឆ្នាំជាង ។

បូលី៖ យកទៅដាក់នៅត្រង់ណា?

សារិន៖ ស៊ីងត្រែងនោះ កោះកន្ទុយគោ!

បូលី៖ ហ៊ូ! កោះកន្ទុយគោយើងហ្នឹង!

សារិន៖ បាទ! សួរគាត់ទៅបានដឹង ។

បូលី៖ ជាប់ប៉ុន្មានឆ្នាំ?

សារិន៖ ជាប់១ឆ្នាំ ។

បូលី៖ ទាំងកូនទាំងអី?

សារិន៖ បាទ! ដល់ពេលចឹងទៅបាន គេឲ្យរួចមានប្រជាជននៅស្គាល់ កាលខ្ញុំនៅក្រោយព្រែកប្រសប់ ហ្នឹង គាត់ទៅភូមិ២ដង គាត់ទៅស៊ីងត្រែង ប្រជាជនស្គាល់ គាត់ស្រលាញ់ ដល់ចឹងគាត់បាន ទៅជាមួយគេទៅដល់ហ្នឹង ទៅហួសទាល់តែឃើញ ។ គាត់ដោះស្រាយអាហ្នឹង បានហើយ មកៗ ។

បូលី៖ បាន មកមុំពាវិញ?

សារិន៖ អត់ទេ! នាំមកព្រែកស្រសប់នេះ មកចូលព្រែកប្រសប់វិញតា ចូលព្រែកប្រសប់ហើយ ចេញមកនៅស្ទឹងត្រង់នៅជនបទៗ ថាបានកម្លាំងពួកតស៊ូនេះនេះទៅ ៗ ៩២០ទៅជួបឃើញ ចេះតែអ្នកហ្នឹងធ្លាប់ស្គាល់ ចេះតែធ្លាប់ស្គាល់មិនដឹងពីណា អត់ដឹងថាគ្រួសារខ្ញុំនោះៗ គាត់ចេះនិយាយចឹងហើយទៅ កូនខ្ញុំឲ្យហើយប្រពន្ធខ្ញុំហ្នឹង ឲ្យតែទៅហ្នឹង ពួកហ្នឹងចេះឲ្យលុយឲ្យលុយ ទៅកូនខ្ញុំណាស់ៗ ឧទាហរណ៍ថាក្រដាសមួយរយ មួយរៀលយើងហ្នឹង គេហៅមួយរយៗយើងហ្នឹង វាថាអត់យកទេ ម៉ែខ្ញុំមានហើយៗ ក្រដាស៥រយក្រហមនោះហើយអត់យកទៀត ម៉ែខ្ញុំមាន! ក្រដាសមួយពាន់វាយក ហើយបានគេឲ្យទាំងស្បោងគេចូលទៅ ៥០, ៦០នាក់អីទេ ទាំងពាន់ៗ បានលុយហ្នឹងទៅចិញ្ចឹមប្រពន្ធរហូតទៅដល់ យកមកឲ្យប្អូនខ្ញុំអាបងនេះចុះទៅ ទៅឃើញបានយកឡើងមកៗ

បូលី៖ ឡើងទៅភ្នំវិញ?

សារិន៖ បាទ! ឡើងមកភ្នំវិញៗ ទៅលើភ្នំដងរែក ទៅនៅដងទង់ដីថៃនោះៗ

បូលី៖ ទៅនៅខាងណាវិញ?

សារិន៖ នៅដងទង់ គេហៅដងទង់ៗ

បូលី៖ នៅខាងកំពត?

សារិន៖ អត់ទេ! ដងទង់ថៃនេះៗ ក្រោយហួស៤០ ឆ្លងជាំស្រងាំទៅនោះបន្តិចៗ ជិតអូរត្រាវ គេហៅអូរត្រាវនៅឯហ្នឹងៗ ខ្ញុំនៅឯហ្នឹង គេយកឡើងមកគេជួបគ្នានៅហ្នឹង បានជួបគ្នារហូតហ្នឹងៗ

បូលី៖ ពេលដែលអ៊ុំនៅ១០០១ហ្នឹង ការរស់នៅហ្នឹង នរណាគេអ្នកផ្គត់ផ្គង់?

សារិន៖ នៅលើនេះ?

បូលី៖ បាទ!

សារិន៖ ខ្មែរក្រហម! ចឹងឲ្យឧបត្ថម្ភមួយខែ គេបើឲ្យ!

បូលី៖ គេឲ្យយ៉ាងម៉េច ក្នុង១គ្រួសារ ឬក៏ម្នាក់?

សារិន៖ ក្នុងមួយនាក់បើក្មេងតូច គេចង់និយាយថាអត់គិតតូចគិតធំ ចែកតែម្តងម្នាក់មួយកំប៉ុង មួយពេលៗ ម្នាក់គិតទៅវា២កំប៉ុងក្នុងមួយថ្ងៃ ហើយគិតទៅ៣០ថ្ងៃ៦០កំប៉ុងណាស់ៗ ហើយម្នាក់នោះបើរបស់ឯងបីនាក់ វា៩០កំប៉ុង ហ៊ូ! ១៨០កំប៉ុងៗ ចឹងវាល់ដាក់មក វាល់កំប៉ុងឲ្យតែម្តងៗ ដល់ចឹងគ្រប់១ចេញទៅ គឺចេញទៅៗ

បូលី៖ ចុះម្ហូប?

សារិនៈ ម្ហូប! បើម្ហូបគេបើកត្រីខ ត្រីអីបានមក បើទៅប៉ុនដល់ពេលអ្នកនៅនេះ អាណាមិនហូបត្រីខ ដល់ចឹងទៅរក រកខ្លួនឯងណា តាមអូរ តាមស្ទឹងចឹងទៅ អាខ្លះចេះធ្វើលប ធ្វើអីនៅ ទៅដាក់ លបបញ្ឆោតលបបន្តប់អីគេទៅ អាខ្លះក៏គេធ្វើអន្ទប់ធ្វើអីវាយយកសត្វព្រៃចឹង មានសំពោច មានស្មារ ឬមួយកណ្ដុរ កន្ធែន អីផ្សេងទៅអាខ្លះក៏ខាងទាក់មាន់ព្រៃ មាន់អីគេទៀតចឹងទៅ ណ៎ា បានមកហូបចឹងទៅ អានេះប៉ុន្តែវិសេសគឺអូរ ៗ តាមអូរហ្នឹង គឺគេធ្វើត្រី អ្នកខ្លះពេល ព្រឹកមកដល់ថ្ងៃត្រង់ គេស្ទូចហ្នឹងគេស៊ីមួយថ្ងៃ ថ្ងៃសន្ទូចមួយហ្នឹង គេដាក់តាមគន្លៀតថ្មៗរហូត ហ្នឹង ត្រីអណ្ដែង ដូនការប៉ុនៗនេះ ប៉ុនដើង ប៉ុនកដៃនេះទៅស៊ីបានមួយ បានពីរ យកមក ប្រស់ដាក់ទឹកទៅចឹងទេ ៗ ហើយបើអ្នកខាងព្រៃខាងអន្ទុបអី ធ្វើដល់លក់ឲ្យថៃ ៗ

បូលីៈ យើងមានរកស៊ីឲ្យថៃដែរ?

សារិនៈ បាទ! ចុះមកនៅទឹកដីថៃ?

បូលីៈ ១០០១ហ្នឹងនៅក្នុងដីខ្មែរ ឬក៏នៅក្នុងដីថៃ?

សារិនៈ ១០០១កន្លែងមុំពាគឺ ទៅខាងនោះលាវ ទៅខាងនេះថៃ ហើយខាងនេះកម្ពុជា ហើយយើង កាលនោះគឺនៅទឹកដីកម្ពុជាទេ មុនហ្នឹង៨៥ណា! គឺយើងនៅហ្នឹងទេ ដល់មកបានដកកម្លាំង យើងចូលមកដោះស្រាយមករដ្ឋាភិបាលថៃ គេអនុញ្ញាតឲ្យនៅក្នុងទឹកដីគេ ប៉ុនឲ្យនៅក្រៅទេ ក្រៅភូមិអី នៅជនបទធ្លាក់មកដល់ព្រៃណាស់ ដល់ចឹងទេ...

បូលីៈ ចេញពីព្រំដែនខ្មែរប៉ុន្មានគីឡូ?

សារិនៈ ចេញដូនការ៦ ទៅ៧ គីឡូ ៗ កន្លែងខ្លះ៦គីឡូ តាមភូមិសាស្ត្រទេ ៗ

បូលីៈ មុនពេលយើងដកទៅថៃ នៅក្នុងទឹកដីខ្មែរហ្នឹង ផ្ទះមានរូបរាងយ៉ាងម៉េចអី? ជាតង់ ជាខ្ទម ជាយ៉ាងម៉េច?

សារិនៈ ទេ! នៅមុំពានេះផ្ទះ ការពិតទៅផ្ទះគួសមនៅ ប៉ុនផ្ទះពុះ ពីដើមសម្រោង ៗ

បូលីៈ ធ្វើពីឈើ?

សារិនៈ ដើមអាផ្លែសម្រោងគេត្រាំទឹកហូបនោះ បានដើមវាប៉ុនៗនេះ តែបីដើមមកធ្វើផ្ទះណា ៗ ពុះហ្នឹងពូថៅកម្លាំងតែម្ដង ហើយយកមកចាំង ចាំងក្លាយទៅជាគ្រឿង ៗ ដល់ចឹងទៅផ្ទះ ធ្វើផ្ទះ ធំៗ ប៉ុន្តែជញ្ជាំងប្រទាំឫស្សី ឯប្រក់គឺប្រក់ស្បូវ ៗ

បូលីៈ ឆ្អឹងឈើ ជញ្ជាំងឫស្សីប្រក់ស្បូវ ៗ លើកពីដីប៉ុន្មានម៉ែត្រអី?

សារិនៈ ដើរផុតក្បាល ១ម៉ែត្រ៨តឹក អាខ្លះ២ម៉ែត្រ ស្រេចតាមតែទំហំផ្ទះ អាខ្លះ១ម៉ែត្រ៥ ១ម៉ែត្រ៦ ទៅតាមទំហំដែលគេធ្វើទៅ ៗ ផុតពីដីអត់មាននៅផ្ទាល់ដីទេ ៗ

បូលីៈ ប៉ុណ្ណាផ្ទះអី?

សារិនៈ ដុះទទឹង ជួនកាល៥ម៉ែត្រចឹងទៅ បណ្តោយ៦,៧ចឹងទៅ ។

បូលីៈ ធំៗចឹងដែរអីអឹ?

សារិនៈ ធំៗ ដុះដុតពីដី! មួយគូរៗសាងមក ។

បូលីៈ អ្នកណាជាអ្នកទទួលខុសត្រូវសាងមក?

សារិនៈ អត់ទេ! ពាក្យថាកម្លាំងនៅក្រោយអូនៗ ឧទាហរណ៍ថាអង្គភាពមួយចឹង គេចឹងគេទៅមានកម្លាំងនៅការពារប្រពន្ធកូនវាវៀបរយ ឧទាហរណ៍ថា៥ ទៅ៦នាក់ ឬក៏១០នាក់ដែលចាស់ៗហ្នឹង គាត់នៅទៅ ដល់នៅទៅ ដល់ពេលគាត់លើងដឹកជញ្ជូនមកវិញ អង្គភាពមានមកនៅស្នាក់ ដល់ចឹងទៅវិញមកលេងប្រពន្ធកូនគេ គេនាំគ្នាពូឈើចាំងទុកទៅ អត់ទាន់បានលើកពេលហ្នឹងបានលើក ក៏លើកទៅបើមិនបានលើកតាៗដែលនៅនេះក៏លើកទៅ ជួយគ្នាទៅវិញទៅ មកចឹងទេនែក! អត់មានស៊ីឈ្នួល ជួលព្រាត់ទេ ប៉ុន្តែបានស្អីៗមកឲ្យគ្នាហូបអត់គិតថ្លៃទេ ដាំដំណាំអីបើនរណាពុះឪឡឹកទុំមុនគេទៅបេហយកមកចែកគ្នាស៊ីទៅ ដល់យើងទុំក្រោយបេះមកចែកគ្នាស៊ីទៅ ។ នរណាធ្វើអត់ទាន់អីក៏ស៊ីទាំងអស់គ្នាទៅ ។

បូលីៈ សមោហភាព?

សារិនៈ បាទ! ជួយគ្នាគ្រប់ ។

បូលីៈ យើងមានចែកជាភូមិជាឃុំទេ ពេលហ្នឹង?

សារិនៈ អត់ទេ! ជាអង្គភាពទេពេលហ្នឹង ។

បូលីៈ ទៅតាមអង្គភាពទេ?

សារិនៈ អង្គភាព ប៉ុនថាមានវរសេនាធំនេះនៅចឹងទៅ វរសេនាធំនេះនៅម្តុំៗ ប៉ុន្តែជាប់គ្នាចឹងទៅ ។

បូលីៈ មិនឃ្លាតគ្នាឆ្ងាយប៉ុន្មានទេ?

សារិនៈ បាទ! ដល់ពេលនេះគេថាកងពល៤១៧ ដាក់ ៤១៧ ប៉ុនវរសេនាធំ នៅម្តុំៗ អត់ច្របល់គ្នាទេ ស្រួលកម្លាំងគេនៅហ្នឹង គេគ្រប់គ្រងកម្លាំងខាងក្រោយដូចគ្នា ។ បាទ! ចឹងណាស់ ហើយមានគណៈកម្មាធិការគេដឹកនាំ គ្រោងក្រោយចឹងទៅ គ្រប់អង្គភាពទាំងអស់ជាសមាជិក គណៈកម្មាធិការហ្នឹង មកគ្រប់គ្រងកម្លាំង ចឹងទេ ។

បូលីៈ ធំបំផុតដែលនៅពីលើគេពីណាគេអឹ មួយគ្រប់គ្រង១០០១ទាំងមូល?

សារិនៈ តាខៀវ!

បូលីៈ តាខៀវហ៎?

សារិនៈ តាខៀវ! ១០០១ គឺតាខៀវ ។

បូលីៈ ពីណាទៀតដែលស្ថិតនៅក្រោមតាខៀវ?

សារិនៈ អត់មានទេ! មានតែពួកមុខសញ្ញាកងពលដែលដឹកនាំមើលទៅអាពួកមុខសញ្ញាកងពល តែដឹកនាំមើលទៅអត់ងាយទេ ។ ចាំមើលទៅមានតែគាត់មួយទេ ឈរចាំដោះសាយបញ្ហា ។

បូលីៈ ផ្ទះគាត់មានតែនៅហ្នឹងដែរ?

សារិនៈ ប៉ុន្តែនៅជិតជាប់នៅមុំ៣ គេហៅថាថ្មដា មុំ៣ហ្នឹង ។

បូលីៈ ផ្លូវមុំថ្មដានេះ?

សារិនៈ បាទ! នៅកន្លែងមុំ៣ហ្នឹង ដីហ្នឹងគឺគាត់ចូលគឺតិចហ្នឹង ។ ឯយើងនៅមុខ ចូលមកតិចហ្នឹង!

បូលីៈ ដីខ្មែរ?

សារិនៈ បាទ! ហ្នឹងហើយ ប៉ុនដែលនៅលើភ្នំ ប៉ុន្តែដីខ្មែរជ្រៅណា ។

បូលីៈ គាត់នៅពើយ គាត់នៅចុងពើយចឹងតែម្តង?

សារិនៈ បាទ! មានអីទៀតអូនអើយចង់និយាយឥលូវខ្ញុំសូមនិយាយឲ្យចប់ស្អីរឿងហ្នឹងចុះណា ។ អគុណហើយមួយទៀតសូមជំរាបថាប្រវត្តិដែលជូរចត់ដែលខ្ញុំដោះស្រាយដោយអំពើល្អដែលខ្ញុំកន្លងមកជួបឧបសគ្គជិតងាប់ហើយរស់ឡើងវិញ ។ ឧបសគ្គឆ្លងកាត់មកចឹងមក ដូចខ្ញុំជាជនពិការមិនសមរម្យទេ ប៉ុន្តែដល់ចឹងខ្ញុំខមប្រយុទ្ធរហូតដល់ខ្ញុំបានឡើងភ្នំ ។ ឡើងភ្នំគឺថា អើនិយាយដូចថាដូចមករស់នៅលើទ្រព្យសម្បត្តិស្រាប់ចឹង ។ បើថាអង្ករអីសុទ្ធតែមហា ដែលគេបើកឲ្យមីចង់យកហូបក៏គ្មាននណាគេ ព្រោះឃើញមីធុញ ហូបត្រីខ ទឹកដោះគោ ស្ករសរ ស្ពៃខោអាវសំលៀកបំពាក់ ប៉ុន្តែមកដល់ក្រោយបានក្លាយខ្លួនជាគណៈកម្មាធិការគ្រប់គ្រងកម្លាំង ។

បូលីៈ ខាងក្រោយ?

សារិនៈ ខាងក្រោយ ជាមួយកែពក ។ គាត់នៅឯសមរភូមិ ឯខ្ញុំជាគណៈកម្មធិកាទទួលខុសត្រូវកម្លាំងអង្គភាព ខ្ញុំជាសមាជិកគណៈកម្មាធិការដឹកនាំកម្លាំងរហូតទៅដល់ព្រឹត្តិការណ៍ថ្ងៃខ្ញុំភ្លេចថ្ងៃហើយហើយនៅ៨៥ហ្នឹងនែ៎ក បានយួនចាប់ប្រពន្ធប៉ុនខ្ញុំភ្លេចថ្ងៃវាយហ្នឹង ទៅ៨៥ហ្នឹងនែ៎ បានយួនចាប់ប្រពន្ធខ្ញុំបែកបាកចឹងទៅ ដល់ហើយខ្ញុំទម្រាំតែគេចខ្លួនបាន គេចនៅក្នុងសមរភូមិ១អាទិត្យជាប់ក្នុងយួនណែ៎ បានគេចចេញផុត លួចទៅចេញជាន់អារណ្តៅនោះទៀត អាកន្លែងអូរទឹកខៀវនោះ មានរងាវពេញហ្នឹង ប៉ុនសុទ្ធតែយួន ។ គេចឆ្លងមកផ្លូវហ្នឹងបានទឹកហ្នឹងទេ ប៉ុនព្រៃឫស្សីបាក់ចឹងទៅនោះ ដល់ឆ្លងទៅលូនចូលព្រៃឫស្សី លូនទៅបាន២០០ម៉ែត្រសម្ងំដេកនៅហ្នឹងទៅ ។ គ្នាបួននាក់ ដល់យប់បានស្រវ៉ាចេញឡើងប្រាំង ។ មើលភូមិសាស្រ្តហើយទៅ បបួលគ្នាបេះដាំបាយពេលជិតភ្លឺដែលទៅជាប់នៅហ្នឹងបានបាយកក បែកគ្នាហូបម្តុំៗ ស៊ីជាមួយអំបិលនោះទៅ ក៏ផឹកទឹកផឹកអីហើយ ឡើងៗទៅគាត់ទៅជួបញ៉ាចទៀត វាបាញ់បីគ្រាប់ ។ ប៉ុនបាញ់

វាដូចជាថាឃើញស្រមោលចិន បាញ់បីគ្រាប់ហើយស្រែកយូយៗ បាញ់ដូនៗក៏ខ្ញុំគេចផុត ប្រុចទៅបាត់ៗ បាត់អាចូលឈើធំៗ បាត់ទៅ វាអត់តាមអីចេះតែកាត់ទៅធ្លាក់ទៅដល់ថៃៗ

បូលី៖ ដល់ពេលបាញ់អ៊ី?

សារិន៖ ចេះតែទៅៗ ៗ ហើយលែងសម្រាកកើតហើយអាហ្នឹង ទៅដល់កន្លែងប្រទល់ប្រទាញគ្នា ហើយបើយើងទៅអីផុត តែបើមិនផុតនៅក្នុងកណ្តាប់ដៃ ដែលចេះៗតែទៅផុតទៅបានជួបហ្នឹងកម្លាំងនេះទៅដឹងចឹងបានតាខៀវនោះឲ្យគេមកជួបខ្ញុំណា គេរាយការណ៍ថាខ្ញុំដល់ហើយ តែគាត់អត់មកជួបទេៗ គាត់នាំខ្ញុំចូលទៅអគ្គភាពវិញទៅ ក៏បានទៅនៅជងទង់ដឹកទាំងឡានទៅ ទៅដាក់នៅឯជងទង់នៅនេះវិញពីនោះមកណាៗ ពីមុំ៣ ក្រោយមុំ៣ អាព្រំសាខងស្អីនោះចេញមកធ្លាក់ដល់ភូមិអី ទុកជិត១ថ្ងៃបានដល់ៗ

បូលី៖ មកដល់ខាង១០០៣?

សារិន៖ បាទ! ១០០៣ ជាប់ជាមួយតាម៉ុកវិញៗ

បូលី៖ ឆ្នាំប៉ុន្មានអ៊ុំមកដល់១០០៣?

សារិន៖ ឆ្នាំ៨៥តែម្តង!

បូលី៖ មកប៉ុន្មាននាក់ពេលដឹកមក?

សារិន៖ យី! មនុស្សរាប់ហើយ រាប់ហើយទ្រង់ជាប់បើសិននិយាយថាបើគិតជានិយាយទៅ ប្រហែលខ្ទង់ជា៣០០០ ទៅ៤០០០គ្រួសារហើយកម្លាំងមួយគ្រួសារមានមួយ មានអាខ្លះ នៅលើវចឹងទៅ ប៉ុន្តែយើងគិតមើលមានកូនមានចៅអាខ្លះពីរ អាខ្លះបី អាខ្លះមួយ ហើយគិតទៅៗ

បូលី៖ បានន័យថាមក១០០១ហ្នឹង មកទាំងអស់?

សារិន៖ មកទាំងអស់! គ្រប់មកទាំងអស់តែម្តងហ្នឹង ដឹកមកទាំងអស់មកហ្នឹងៗ

បូលី៖ តាខៀវគាត់អស់ឥទ្ធិពលហើយពេលមក?

សារិន៖ អត់ទេ! គាត់នៅតែគ្រប់គ្រង! ប៉ុន្តែគ្រាន់តែ១០០៣ វាចូលដី១០០៣មែនតែកម្លាំងតាខៀវនៅតែគ្រប់គ្រង អ្នក១០០៣ គេគ្រប់គ្រងកម្លាំងគេចឹងណាៗ

បូលី៖ តាខៀវ គាត់មកនេះដែរ?

សារិន៖ ចា៎ស! មកដែរគាត់ទៅនៅឯកន្លែងអីនេះនោះ កន្លែងហ៊ុំពង្វ័ សង្កីសី ខាន់ស្លាក់នោះណា កន្លែងការងារគាត់នៅក្នុងទឹកដីថៃៗ

បូលី៖ មកខាង១០០៣នោះ ប្រជាជនដែលមករាប់ពាន់គ្រួសារហ្នឹងមកនៅលើក្នុងទឹកដីថៃនោះៗ

សារិន៖ មក! ខាង១០០២ ដែលប្រជាជនរាប់ពាន់គ្រួសារនោះ រស់នៅក្នុងដីខ្មែរនោះ ឬនៅក្នុងដីថៃទេ?

បូលី៖  គេហៅអីអ៊ុំ ម្តុំហ្នឹង?

សារិន៖ គេហៅដងទង់ កន្លែងហ្នឹង ។

បូលី៖  ទល់មុខជាមួយហ្នឹងជាំស្រសាំយើងហ្នឹង?

សារិន៖ ហ្នឹងហើយ! ជាមួយជាមួយនេះ នេះដង ហើយនឹងជាំស្រសាំនេះ ហើយក្បាលទន្សោងនេះណា ទល់មុខគ្នាហ្នឹង ។

បូលី៖  ជំរុំអីគេ?

សារិន៖ ជំរុំហ្នឹង គេហៅជំរុំដងទង់!

បូលី៖  ដងទង់?

សារិន៖ បាទ!

បូលី៖  ភាសាថៃ?

សារិន៖ អត់ទេ! ខ្មែរយើងអ្នកដាក់ ថៃអត់ដាក់ទេ ខ្មែរយើងដាក់ ឯម្តុំដងទង់ហ្នឹងដោយសារអី ដោយសារថៃគេធ្វើនៅកន្លែងហ្នឹង គេមានពួកអាមេព្រៃគេធ្វើកន្ទេះកេះ វាដាក់ទង់ជាតិវា វាធ្វើចឹងទៅធ្វើដងទង់ខ្ពស់ចឹងទៅណា៎ ដល់ចឹងយើងដាក់ម្តុំដងទង់ខ្លួនយើង ។

បូលី៖  ឥលូវដល់បច្ចុប្បន្ន នៅម្តុំដងទង់?

សារិន៖ ហ្នឹង! មកឥលូវគេនៅតែហៅដងទង់! ដល់ចេញពីអាហ្នឹងទៅបានទៅនៅអូរត្រាវទៀត ។

បូលី៖  អូត្រាវហ្នឹងនៅ ពីដងទង់ដែរ មួយណានៅក្បែរដីខ្មែរជាង?

សារិន៖ អត់ទេ! នៅចម្ងាយគ្នា ។ ចម្ងាយពីដីថៃទៅព្រំដែន ចម្ងាយគ្នា ប៉ុន្តែទៅអូរត្រាវវាចង់ជាប់ហ្នឹង ១០០៣ គេហៅថាក្រោយជាប់នៅក្បាលទន្សោងហ្នឹង ។

បូលី៖  អូរត្រាវហ្នឹង ជាប់ហ្នឹងក្បាលទន្សោង?

សារិន៖ អត់ទេ! គេហៅថាអូរត្រាវ ។ ជំរុំអូរត្រាវ ម្តុំអូរត្រាវហ្នឹងមានពីរ មួយជំរុំខ្មែរក្រហម ប៉ុនមួយទៀតនេះ ទម្រង់កាកបាទអន្តរជាតិគេបង្កើតម្តុំអូរត្រាវហ្នឹងហើយដើម្បីជួយ ហើយគេជួយរំលែកអ្នកងាយរងគ្រោះលំបាកអី រត់ចូលជំរុំទៅគេចិញ្ចឹមនោះណា រឿងនេះទេ! ចឹងពួកខ្ញុំនៅជាប់អន្តភាពទេរៀបចំទៅ ប៉ុន្តែដីប្រហែលជាខ្ទង់១គីឡូ ២គីឡូវា២ជំរុំ ។

បូលី៖  ចឹងពីដងទង់ទៅ អូរត្រាវ ដី១គីឡូទេចឹង?

សារិន៖ អត់ទេ! ពីដងទង់ទៅអូរត្រាវហ្នឹង៥គីឡូ ហើយឆ្លងភ្នំពីរ ។

បូលី៖  ៥គីឡូដី?

សារិន៖ បាទ! កាត់ភ្នំពីរបានដល់ ។

បូលី៖  ចុះស្ទឹងចាន់ ជប់មួស្អីគេវិញអីអាហ្នឹង?

សារិនៈ ស៊ីងចាន់?

បូលីៈ ជរ៉ុស៊ីងចាន់ ជរ៉ុដប់មួ អ៊ីដែលព្ទុះទេ ពីរហ្នឹង?

សារិនៈ អត់ទេ! ជរ៉ុស៊ីងចាន់ និងជប់មួនេះ មុំនេះ ខ្ញុំអត់ដែលជាន់ចូលទេ! បើចូលបានដឹង ស៊ីងចាន់ នៅណាអីណា ចំណុចណាអាហ្នឹងចឹងណា! ប៉ុនបើជប់មួ គឺនៅ១០០៣ហើយបាទ។

បូលីៈ របស់ពីណាគេគ្រប់គ្រង?

សារិនៈ តាម៉ុក?

បូលីៈ តាម៉ុកដែរ?

សារិនៈ បាទ! ជប់មួ។

បូលីៈ ចម្ងាយពីដីខ្មែរទៅប៉ុន្មានគីឡូអ៊ី?

សារិនៈ ខ្ញុំអត់ដឹង! ព្រោះខ្ញុំមិនដែលចូលទេស៊ីងចាន់នោះ។

បូលីៈ ចុះអូរគ្រាវនោះ?

សារិនៈ បើអូរគ្រាវប្រហែលខ្ទង់៦គីឡូ ៧គីឡូទេ។

បូលីៈ ពីដីខ្មែរទៅ?

សារិនៈ ពីព្រំដែនខ្មែរទៅ ដល់កន្លែងមុំណា តែប៉ុណ្ណឹងទេ។

បូលីៈ មិនឆ្ងាយប៉ុន្មានដែរ?

សារិនៈ មិនឆ្ងាយប៉ុន្មានទេ! ពួកនេះរស់មិនដែលនៅឆ្ងាយទេ។ ឆ្ងាយយ៉ាងម៉េច? តែឆ្ងាយពីសមរភូមិ អត់ងាយក្ដាប់ ដល់ចឹងចេញចូលគឺលឿន។ ហើយមួយទៀត មកសមរភូមិគឺលឿន ចឹងណា ហើយរស់នៅឆ្ងាយអត់ នៅទឹកដីគេ គេធ្វើបាប។ ធម្មតាគេឲ្យមែន ប៉ុន្តែការចេញចូលលំបាក ណាស់ចឹងណា ប៉ុន្តែយើងគ្រប់គ្រងក៏ល្មមដែរ តែគេប្រគល់ឲ្យគ្រប់គ្រងអាថៃចូល ក៏ពិបាក ដែរ។

បូលីៈ ថៃមានដែរធ្វើបាបខ្មែរយើងទេ?

សារិនៈ មកដូនកាល វាមានមក ប៉ុនមានអ្នកខ្លះខូចទិលមែន ប៉ុនពួកទ័ពទៅ រិបហែងដាក់ វាយហើម មុខហើមមាត់ដូចតែគ្នាហ្នឹង ហើយដល់ហើយឆប៉ោះគេហ្នឹង ហៅពួកប្រចាំការនៅជាមួយការងារ ទំនាក់ទំនងហ្នឹងរាយការណ៍ប្រាប់គេ គេមកយក មានតែគេទាត់ ហើយធាក់ថែមទៀត។

បូលីៈ ហើយយើងមានរកស៊ីជាមួយថៃទេអី?

សារិនៈ ការរកស៊ី ខ្ញុំពិនិត្យទៅពួកខ្មែរក្រហមនេះ មិនសូវទេ អត់ទេ ព្រោះអីគេអស់បើកខោអាវមួយ ឆ្នាំ។ បើកមួយឆ្នាំ គឺបើកថាទាំងស្រី ទាំងប្រុស ហើយអន្ទរហូបមិនឲ្យខ្វះ មានតែសល់ ហើយមានតែសល់លក់ លក់ឲ្យថៃ។ ហើយទៅរកស៊ីទៅធ្វើខ្ញុំថៃ គ្មានទេ អត់ធ្វើសោះ គេគិត

តែរឿងនេះទេ ឯពរឿងរកពាណិជ្ជកម្មនេះនោះមានតែពួកខូចនោះទេ គេរកស៊ីៗ ហើយដល់គេបានគេទាក់រកចិនណា តែឲ្យដឹងអន្តភាពខ្ញុំអត់ អត់សោះ ការរកស៊ីហ្នឹងគឺគ្មានទេ ហើយមួយ ទៀតមានថាលក់ឲ្យថៃ មានខ្លួនឯងរកអីបានលក់ទៅ តែរកស៊ីជាមួយថៃតែម្តងចេញចូលថៃគឺ អត់ៗ អត់ទេ! មានតែថៃគេមកទិញដល់គ្រប់ផ្ទះយើង អាហ្នឹងមានៗ

បូលី: អ៊ីចឹងអូរត្រាវបែកចេញជាពីរមួយខាងខ្មែរក្រហមគ្រប់ គ្រងមួយខាងអង្គការសហប្រជាជាតិគ្រប់គ្រង UN ។

សារិនៈ បាទ! អាហ្នឹង ។

បូលី: ភាគច្រើនខ្មែរយើងទៅរស់នៅខាងណាដែរ?

សារិនៈ ពួកជំរុំអង្គការសហប្រជាជាតិដែលថា ការជួយសង្គ្រោះជំរុំ ដែលជួយហ្នឹងគឺថាគ្មានខុសពីកម្លាំងអតីតខ្មែរក្រហមទេ ទៅនៅហ្នឹងនោះ រាប់ពាន់គ្រួសារចឹងទៅវាជួបការលំបាក ហើយវាធុញទ្រាន់នឹងការលំបាកអាណា ខ្លះក៏ចាស់ចឹងទៅនឹងហើយ ។ ហើយដល់ចឹងកាលលំបាកអានេះក៏ចឹងចូលទៅនៅ ហើយមួយទៀតចឹងទៅមានមុខរបប មួយអង្ករហើយបើកទៅ ហើយមួយ ហើយមុខរបបរកស៊ីអីក្នុងហ្នឹងវាបើក ដល់ចឹងគ្នាឆ្លៀតឱកាសទៅហ្នឹងទៅរកលុយ រកកាក់ទៅនេះចឹងទៅទេ ។

បូលី: ក្នុងជំរុំហ្នឹងមានបើកលក់?

សារិនៈ បាទ! មានទីផ្សារថៃបើក មួយសប្តាហ៍មានប៉ុន្មានថ្ងៃ លក់ដូរទិញរបស់ យកមកលក់ឲ្យគ្នាឯងណាចឹងទេ ។

បូលី: ដែលតាម៉ុកគ្រប់គ្រង?

សារិនៈ អត់ទេ! អាជំរុំកាកបាទក្រហមនោះ ។

បូលី: បាទ! អាខាងនោះមានគេលក់ដូរ?

សារិនៈ បាទ!

បូលី: របស់តាម៉ុក អត់ទេ?

សារិនៈ អត់ទេ! ហើយបើយើងនេះ យើងទៅបន្ទំ អាខ្លះទៅចឹងទៅ ទៅបន្ទំទៅទិញពួកជំរុំនិរតី យកមកកន្លែងអន្តភាពយើងលក់ដូរឲ្យគ្នាយើងទៅ វាមានលុយដូចគ្នា ចឹងនែក?

បូលី: បាទ!

សារិនៈ ចឹងទេ ប៉ុន្តែវាថោក ចឹងទៅ! ធ្វើម៉េចឲ្យបានគ្រប់គ្នាចាយ ឬមួយបន្តិចបន្តួចស៊ីចឹងទៅក៏វាថោកដែលណា ប៉ុន្តែចំណេញក៏តិច ប៉ុន្តែពួកជំរុំទេ គេមិនដឹងទេ ព្រោះគេថាមេជំរុំហើយវាក្លាយទៅជាអ្នកនេះ គ្រប់តែគ្នា ។

បូលី៖   អ្នកណាមេដឹកនាំរបស់អូរគ្រាវ?

សារិន៖ កាលហ្នឹង តា នៅ អាចារ្យនៅ នៅអន្លង់វែង។

បូលី៖   អាចារ្យនៅ នៅក្អួយតាម៉ុកនេះ?

សារិន៖ មិនមែនទេ! អាហ្នឹង នួននៅ ប៉ុន្តែនេះអាចារ្យ នៅ។ អាចារ្យនៅ មួយទៀតអាចារ្យតែម្តង គ្រប់គ្រង។

បូលី៖   នៅឯណាអាចារ្យនៅ ហ្នឹង?

សារិន៖ នៅអន្លង់វែងហ្នឹង   គ្រាន់តែខ្ញុំអត់ហាន លូកដៃលូកជើងទៅ។

បូលី៖   ខ្ញុំឃើញផ្ទះរបស់គាត់ដូចជាមិនមែនជាអ្នកមានអីទេ មើលទៅ? ដូចជាអ្នកសាមញ្ញ?

សារិន៖ សាមញ្ញ ប៉ុនលុយសម្បើមណាស់។

បូលី៖   ខ្ញុំចូលផ្ទះដំបូងៗ ដូចឃើញមួយគ្រែៗដែរ មិនបានប៉ុនផ្ទះអឹងផងមើលទៅ។ ផ្ទះអាចារ្យនៅ នៅអន្លង់វែង?

សារិន៖ ផ្ទះ អាចារ្យនៅ នៅអន្លងវែង ប៉ុន្តែល្បិចច្រើនណាស់ យើងពិបាកពិចារណា ប៉ុន្តែការពិត ប្រភពលុយ កាលនៅកាន់ល្មមៗ ក្នុងមួយសប្តាហ៍ៗ គាត់អត់ចេញមុខទេ គ្រប់មុខអង្គភាពទាំងអស់ ដែលចូលទៅមានកម្លាំងប្រហែលដូចថាសង្កាត់ទៅ។ មួយបើកចិនឲ្យគាត់ប៉ុន្មាន? បើចិនគាត់អត់និយាយ កម្លាំងដែលត្រូវបញ្ចូលចិន គាត់អត់ស៊ីញ៉េ បើមិនចិនពួកនោះបន្លំស៊ីអីចិនពួកនោះឲ្យគាត់៣០ភាគរយ ស៊ី៧០ភាគរយ គេធ្វើហើយ ហើយគាត់យកបន្តិចទៅបើក ម្តងអង្ករអីនៅត្រឹមសម្ភារផ្ទះ ប៉ុន្តែយប់ឡើងចេញអស់ហើយ។

បូលី៖   ឃ្លាំងសម្ភារទាំងអស់នៅឯណាអ៊ំ ឃ្លាំងផ្គត់ផ្គង់?

សារិន៖ ឃ្លាំងរបស់ថាខ្មែរក្រហមវា ឃ្លាំងផ្គត់ផ្គង់នៅកន្លែង តា ខៀវនោះ ប៉ុនថាពេលដឹក មកដល់ថ្ងៃបាន វាដឹកយកមកកន្លែងដឹកនាំហ្នឹងទាំងឡានៗ អង្គភាពទៅណាអង្គភាពទៅទទួលចែកគ្រប់ចំនួនចិនហើយគេទទួលហើយបានហៅកម្លាំងអង្គភាព វាចែកហើយហៅកម្លាំងខ្លួនចូលទៅចិនណា។

បូលី៖   អាហ្នឹងគេចែកទៅតាមអង្គភាពសិន បានមេអ៊ំយកទៅចែកបន្តទៀត?

សារិន៖ ចែកទៅតាមកម្លាំង ហើយចែកតាមបញ្ជី សៀវភៅ ដូចគ្នាៗ។ អត់មានប្រលេមប្រឡំគ្នាសល់ ដឹងតែសល់តែម្តង ខ្វះដឹងតែខ្វះហើយ។ អ្នកខ្វះហ្នឹងខ្វះហើយ គេមិនចង់យកផង ព្រោះស៊ីវាសល់ តែរឿងអីផ្សេងៗខ្ញុំមិនដឹងទេប្រវត្តិ ទើបមកដល់ចុងក្រោយនេះ ការដឹកនាំនៅតាមសមរភូមិជាមួយគាត់នៅឆ្នាំ៩០ដែលចរចារដោះស្រាយ ដល់ចិនទៅនៅជាមួយកូនគាត់២រូប ដល់៩៣ដើម្បីទៅបោះឆ្នោត បានចុះវិលត្រលប់ពីលើនោះមកក្រោមនេះ បានកើតស្រុកពីរ ស្រុកអន្លង់វែងមួយ ស្រុកត្រពាំងប្រាសាទនេះឯងដោយឡែក។ គ្រប់គ្រងខ្ញុំនៅ

ស្រុកត្រពាំង ខ្ញុំធ្វើនៅត្រពាំងប្រាសាទនៅចុងក្រោយបង្អស់ដែលដឹកនាំ ហើយមួយទៀតដែលកម្លាំងសមាហរណកម្មនៅតាមហ្នឹងគឺសមាហរណកម្មនៅអន្លង់វែង ជាមួយរដ្ឋាភិបាល ។ កម្លាំងនៅត្រពាំងប្រាសាទកងទ័ពនេះ មានចលនាមួយ គឺអ្នករត់ទៅសមាហរកម្មទៅចេះទៅ ទៅហើយកម្លាំងទ័ពទៅមួយផ្នែកទៀត ។ ទៅមួយផ្នែកប្រពន្ធកូននៅនេះ វាត្រូវការដឹកជញ្ជូនទប់ទល់សមាហរណកម្ម ហើយបានកើតព្រឹត្តិការណ៍គេហ្នឹងសមាហរណកម្ម មួយផ្នែកទាំងស្រុង ខ្ញុំដឹកនាំទាំងស្រុងមកជាប់ជាមួយរដ្ឋាភិបាល ។

បូលី៖ ពេលដែលចុះពីលើភ្នំមកលចុះឆ្នាំ ប៉ុន្មាន?

សារិន៖ ឆ្នាំ៩០ ។

បូលី៖ ចុះមក ចុះតាមណា?

សារិន៖ ចុះជាំស្រង៉ាំអន្លង់វែង អាផ្លូវឡើងទៅនៅហ្នឹង តាមហ្នឹង កាលនោះផ្លូវស៊ីង កាយធ្វើ ។

បូលី៖ កាលនោះនរណាគេអ្នកធ្វើ?

សារិន៖ តាម៉ុក! កាយភ្នំធ្វើផ្លូវចុះមក ក្រោយពីធ្វើផ្លូវ ប៉ុនកាលជំនាន់ហ្នឹងភ្លៀង ឡានចុះមកសុទ្ធតែចេះ សុទ្ធតែតូចៗឡានចិនណា អត់ពូទេ គ្រីកៗមក អត់ធានាតែម្តង ឡើងហើយចុះ ។

បូលី៖ វាចោទ?

សារិន៖ វាចោទ! លិចក្បាលឡានក្នុងទឹកចឹង ឡើងឈុល! ហើយខ្ញុំកំណើតអាកូនអារៀននេះ ឆ្នាំទី៤ អានេះ ឆ្នាំទី៤នៅភ្នំពេញកើតនៅស្រុកហ្នឹង ។ ចុះមកបានប៉ុន្មានថ្ងៃ ដល់ចឹងទាស់ម្តាយអត់ទឹកដោះ ហើយគាត់ភ័យគាត់ហៅឡើងទៅមន្ទីរ ។ កម្លាំងគេចុះដល់ហើយគាត់កូនខ្ចី ដល់ចឹងថៅកុងឡានគាត់ហ្នឹង គាត់ភ័យ ។ កូនហ្នឹងរស់ហ្នឹងទឹកដោះគោទេ មានទឹកដោះគោដូចសម័យឥឡូវណា មានតែទឹកដោះគោធម្មតាមនុស្សធំដឹកហ្នឹងណាចេះតែឆុងលាយចាមួយបបរ ចេះទៅឡដឹក ទាល់ធធេសធោស គ្នារហូតៗ សុខភាពអត់មាំមួនដូចគេទេ ប៉ុន្តែវារៀន ផលូវហ្នឹង ឆ្នាំទី៤ នៅភ្នំពេញរៀនខាង គិចណូ ។ បាទ! ខាងវិស្វករណាស់ ។

ថនៈ សាលាតិចណូ៎ រៀននៅសាលា ន័រតុន ។

បូលី៖ ផ្លូវនឹងមានតាំងពីយូរមកហើយ ឬក៏ទើបតែធ្វើហ្នឹងទេ? ផ្លូវហ្នឹងមានដានទេ ច្រកជាំស្រង៉ាំ?

សារិន៖ ផ្លូវហ្នឹងអត់ទេ! ការសិក្សាគឺ ពុំមានទេកាលហ្នឹង ផ្លូវគឺផ្លូវដឹកជញ្ជូនខ្មែរក្រហមចេញចូលឆ្លងទៅទេ ហើយផ្លូវសំខាន់ដែលផ្លូវរដ្ឋាភិបាល និងផ្លូវយួននេះ ចុះបន្ទាយនៅជាំស្រង៉ាំ គឺបន្ទាយយួននៅហ្នឹងនៅឡើយ ។

បូលី៖ ភ្នំអំបាញ់មិញហ្នឹង?

សារិនៈ ភ្នំ! នៅព្រំដែនលើហ្នឹងណា ។

បូលីៈ យួន? នៅខាងជើងភ្នំហ៎?

សារិនៈ អត់ទេ! នោលើតែម្តង ដល់ចឹងទៅយើងវាយ ដល់តែបានទៅយើងចុះតាមសិក្សាលើ ផ្លូវវាតាមដាន ផ្លូវយួន ផ្លូវទាហានរដ្ឋាភិបាលឡើងទៅតាមនៅលើនោះ ដើរទៅហ្នឹង ដើរសិក្សាឃើញទៅ សម្រេចចិត្តធ្វើផ្លូវហ្នឹង មៃខូ តម្រៀបគ្នាចឹង បែកកងគ្នាកាយទៅថ្មៗ វាយដាប់ឡើងទៅៗ កាយទម្លាក់ធ្វើបានដីកនេះជាផ្ទាល់ ហើយ ធ្វើឲ្យកាយ មករហូតទៅ ។ ដល់ថៃគេមកពីងថៃមកជួយនេះ អាមៃខូ គេមក អាទំពាថ្មហ្នឹងមក បានអាខែនោះគ្រួកៗគេមក គ្រួកៗបែកទៅណា មកទៀត ហើយ បានមានអាចាក់រុក ថ្មចឹងហើយឆ្កិះ ចាក់រុកឆ្កិះបែក មកទាំងផ្ទាំងៗណាស់ក៏មាន ។ ហើយដាក់អាកាយតម្រឹម មើលឃើញដានក្រចកនោះ អាមៃខូ ថ្មនោះទល់មកឥលូវ គាត់ធ្វើសព្វថ្ងៃហ្នឹង ។ ដល់ពីសម័យសមាហរណកម្មជារដ្ឋាភិបាល ពួកនេះក៏បានចូលមកស្រុកត្រពាំងប្រាសាទនេះ មុនអន្លង់វែង ។ អន្លង់វែង កាលសម័យសមាហរណកម្មមិនរត់ ទៅអន្លង់វែងមួយសារ ប៉ុន្តែក្រោយពួកខ្ញុំទេ ។

បូលីៈ ពេលដែលអីចុះមកភ្លាម អីចុះមកនៅឯណា?

សារិនៈ ខ្ញុំចុះមករត់ទៅ ទៅនៅឯទំនប់ដាច់ ដល់ទំនប់ដាច់បានកម្លាំងទ័ពវាយ គេឡើងដល់លើវិញ ពួកអន្លង់វែង វាយចូលដល់ជំរុំ ចូលមកថៃណា ។ ហើយពួកខ្ញុំឡើងទៅភ្នំ វាយភ្នំបានទៅលើងតាមនោះមកអូរស្មាយវិញ ដល់កន្លែងចាស់ ។ ដល់អូរស្មាយហ្នឹងមកធ្វើអន្ទរ កម្លាំងអីមូលគ្នាអស់បានចេញមកជួបនៅឯនេះ ដែលទិសដៅសមាហរណកម្មនេះមកជួបជុំគ្នា នៅទីនេះហើយ ដែលទៅហើយមកជុំគ្នាពិភាក្សាប្រមូលកម្លាំងរៀបចំនៅមូលហើយ សំណើរទៅរដ្ឋាភិបាល ដើម្បីរៀបចមរចនាសម្ព័ន្ធបង្កើតស្រុកត្រពាំងប្រាសាទ ។ នេះដោយពីអតីតខ្មែរក្រហមមក វាមានស្រុកហ្នឹង ប៉ុន្តែឃុំគឺដូចអគ្គភាពមួយៗទេ កងពលមួយៗជាសមាជិក ដែលនៅក្រោយនោះជាឃុំនៅក្នុងស្រុកចឹងទៅណា បានកើតជាស្រុកនេះ ហើយខ្ញុំហ្នឹងក៏គេឲ្យប៉ុន្តែខ្សែរយៈ ថាទាបាញ់មកជួប ប៉ុនគាត់សួរ ដល់សួរខ្ញុំលាក់ "ទេ តាមខ្ញុំដឹង អភិបាលស្រុកហ្នឹងពីមុន តួស្រុកក៏សមាហរណកម្មនោះ នៅព្រះវិហារហ្នឹងនោះ" ឆ្លើយដាក់ តា សយ ទេ ។ ប៉ុនតាមពិត ខ្ញុំទេអ្នកនិយាយជាមួយគាត់ ខ្ញុំអត់ទុកចិត្តដែរ មិនដឹងជាយ៉ាងម៉េចៗ ដល់ចឹងបានបានគេរៀបរយៗ ដល់ក្រោយមកបានគេពិភាក្សារៀបរចនាសម្ព័នរៀបរយហ្នឹង ហើយទៅខ្ញុំទៅធ្វើជាមន្ត្រីសាលាស្រុកហ្នឹង គឺខ្ញុំខាងផ្នែកការិយាល័យរដ្ឋបាល ។

បូលីៈ ចៅហ្វាយស្រុកមុនគេបងស្អស់?

សារិនៈ ពីមុនកាន់នៅខ្មែរក្រហម គឺខ្ញុំចៅហ្វាយស្រុក ប៉ុនដល់ចូលរដ្ឋាភិបាល ខ្ញុំឈប់ធ្វើ ។

បូលី៖ នរណាគេ?

សារិន៖ កាលហ្នឹង ជុំ ជាតិ។ ដល់អញ្ចឹងទៅខ្ញុំចេះតែនៅធ្វើការទៅ គេប្រើត្រលប់ត្រលិន ថាឯងនោះកាត់ត្រកកាត់ត្រាំង ចេះតែធ្វើទៅៗទាល់តែបានរលូនល្អទៅមហាផ្ទៃ អភិបាលខេត្តអីស្គាល់ខ្ញុំមុនគេអារឿង ខ្ញុំចេះតែទៅ ហើយទៅជួប មិនដឹងជាជួបនរណា ជួបរកតែអភិបាលខេត្តហ្នឹង តា ម៉ៅ គឹង កាលហ្នឹង។ ទៅជួបហ្នឹង ថាធ្វើអីៗហ្នឹងជាមួយគាត់ហ្នឹង ថាមកវិញហ្នឹងជិះម៉ូតូជូន៧ម៉ឺន, ៧ម៉ឺនទៅ ៧ម៉ឺនមក។ កាត់ត្រកកាត់ត្រាំងតែឯងមក បើនរណាក្បត់ វាយផាប់។

បូលី៖ ផ្លូវពិបាកកាលនោះ?

សារិន៖ ៤ ទៅ៥ដងទម្រាំមកដល់ខេត្ត វេទនាណាស់។ ហើយបើទៅតាមសៀមរាប ទៅដេកក្រឡាញ់ ចេញពីក្រឡាញ់ទៅផ្លូវនោះ ផ្លូវទៅចុងកាល់ ស្រីស្នំ សម្រោង របើកប៉ុនៗនេះ របើរបាញអស់ អត់មានដីទេ។ រឃូងរឃាំងមិនដឹងជាស្អីទេ ហើយចុះកន្លែងខ្លះចុះវាងកាត់ស្រែ កាត់ស្រូវ ទឹកជម្រៅៗនេះ ជីកថ្ម ប៉ុណ្ណឹង។ វេទនាណាស់ ប៉ុនខ្ញុំចេះតែទៅ។

បូលី៖ ខាងត្រពាំងប្រាសាទយើង ខាងកងពលណាខ្លះមកឈរជើង បេលដែលចុះពី៩០មក?

សារិន៖ កងពល?

បូលី៖ បាទ!

សារិន៖ ចុះពី៩០ មាន៤១៦, មាន៨០១,៨០២ណា, ៩២០អត់ទេ! នៅជាប់អន្លង់វែងទេ។ មើលកងច្រើនដូចស្អី ៧ចុង? កងពលស្អី ដូចកងពល តាហឿន ហើយកន្លែងបងរឿននោះ បង០៥ កន្លែងអ្នកដឹកនាំ បងរឿននៅកន្លែងហ្នឹងជាប់ត្រពាំងប្រាសាទដែរ។

បូលី៖ មូលដ្ឋានធំ គឺនៅផ្ទះតារឿន?

សារិន៖ ហ្នឹងហើយផ្ទះតារឿនហ្នឹង។

បូលី៖ ហ្នឹងគាត់មេធំនៅ?

សារិន៖ នៅគ្រប់គ្រងខាងនេះ អញ្ចឹងណា!

បូលី៖ ខាងត្រពាំងប្រាសាទ?

សារិន៖ គាត់មេបញ្ជាការខាង៨០១ចាស់ ហើយកើត៨០២ក៏គាត់ គាត់ជាអ្នកដឹកនាំរួមពីមុនក្ដាប់អង្គភាពហ្នឹង មេកើតនោះចេញអីហ្នឹង។

បូលី៖ ពូសួរថា ខាងត្រពាំងប្រាសាទ និង ខាងអន្លង់វែង អត់សូវត្រូវគ្នាទេ?

សារិន៖ ទេ! ត្រូវមិនត្រូវខ្ញុំមិនដឹងទេ! ជិនាន់មុនទេ។

បូលី៖ បាទ! មិនមែនជំនាន់ឥលូវទេ។

សារិនៈ បើជំនាន់មុនគឺត្រូវ ប៉ុន្តែជំនាន់ក្រោយដែរបែកបាក់ជិតសមាហរណកម្មគឺមុនទេ ដែលមួយអន្លង់វែងហ្នឹង ជាមួយតាម៉ុកណា ដល់អញ្ចឹង អត់ត្រូវត្រពាំងប្រាសាទទេ ព្រោះគេ គេថាចូលចេះអូនទៅដែលតា តែតាមពិត មុននៅជាប់ជាមួយហ្នឹងរដ្ឋាភិបាលបច្ចុប្បន្នជាពិសេសជាមួយសម្តេច ហ៊ុន សែន ហ្នឹង ។

បូលីៈ ចារកិច្ចរបស់ ហ៊ុន សែន ។

សារិនៈ មុនបើពីចារកិច្ច ០០៩គេនោះណា ហើយជួបគឺនៅឯថៃនោះ អាពេលមកធ្វើនោះដើម្បីវាយបំបាក់គ្នាឲ្យនេះទៅ តែបើមិនធ្វើឲ្យបែកបាក់កម្លាំងនេះដុំគ្នា រដ្ឋាភិបាលពិបាកហ្នឹងធ្វើណាស់ចឹងណា៎ ហើយដល់ចឹងធ្វើអញ្ចឹង ប៉ះតន្តិចគ្នា ដល់ចុងបញ្ចប់គេឹងដែលមិនត្រូវ គឺមូលហេតុចាប់បង០៥,០៦ សែងទៅសម្លាប់ធ្ងន់ណាស់ ។

បូលីៈ ឃឹម ផុន ហ្នឹង អ្នកចាប់?

សារិនៈ ហ្នឹងហើយ ឃឹម ផុន អ្នកសម្លាប់ ។

បូលីៈ ឃើញក្នុងវីដេអូ មានតាប៉ុល ពត គេចាប់ដាក់ទោស ។ ហើយនៅពីក្រោយតា ប៉ុល ពតមានបីនាក់ មានតា ០៥ មួយ តា០៦មួយ ហើយម្នាក់ទៀតពីណាគេម្នាក់ទៀត ជាប់ឈ្មោះដែណា?

សារិនៈ តា សែន! ឈ្មោះ សែន ។

បូលីៈ នរណាគេឈ្មោះ សែនហ្នឹង?

សារិនៈ តា សែននេះ នៅនេះអង្គភាពចេញពីបង០៥ដូចគ្នា ។

បូលីៈ តា សែនគាត់ជាអ៊ីទៅ ជាអនុ?

សារិនៈ អត់ទេ! កងពល ។

បូលីៈ កងពលអីគេអឺ?

សារិនៈ កងពល! ប៉ុន្តែគាត់កងពលផ្នែកទៅខាងលិចវិញហ្នឹង គាត់ទៅដឹងនាំចាប់ពីអាផ្លូវអូរស្មាច់មកចេះចាប់ដៃជាមួយអន្លង់វែងខាង សហការជាមួយអន្លង់វែងណា៎ តាសែនហ្នឹង កាត់មុខសញ្ញាទីនោះគេឲ្យបូកហ្នឹង ។ ចុះអាម្តុំភូមិបុស្សនោះ ភូមិអី ស្រាប់តែកន្លែងមូលដ្ឋាន តា សែន ហើយនេះគាត់ នេះទៅធ្វើការទៅដល់ហ្នឹង គាត់ដាក់កម្លាំងទ័ពអីនៅហ្នឹងចេញចូលហើយទៅវាយធ្វើសកម្មភាពនៅផ្លូវសម្រោង ខ្ទះធ្លាក់ទៅដល់ចុងកាល់នោះ ។ នេះសកម្មភាពបូក! ប៉ុន្តែគ្រាន់តែថា ខ្ញុំគ្រាន់តែដឹងថាទិសទេ សកម្មភាពគេ ខ្ញុំមិនសួរ ឥលូវពួកខ្ញុំនៅមូលដ្ឋានចេះ គ្រប់គ្រងតែប្រពន្ធគេនៅក្រោយហ្នឹង ហើយដល់ចេះទៅបានមករៀបចំនេះ ខ្ញុំដំណើរទិស ខ្ញុំបានឡើង

អភិបាលវេនវិញ ខ្ញុំកំសត់ ចង់និយាយថាគេប្រកាសអភិបាលវេនវិប ប្រកាសចូលនិវត្តន៍មកជាមួយគ្នាតែម្តង ។

បូលី: គ្រាន់តែប្រកាសភ្លាមចូលនិវត្តន៍ភ្លាម?

សារិនៈ វាធ្វើប្រកាសស្ទើរទៅហ្នឹងនេះអស់ហើយ ប៉ុនដល់ហើយប្រកាសចូលនិវត្តន៍អស់សុពលភាពខ្លួនឯងហ្នឹងហើយ លេងប្រកាសអភិបាលមកដែរ ប្រកាសអភិបាលនិងប្រកាសចូលនិវត្តន៍ជាមួយគ្នា ។

បូលី: ប្រកាសអភិបាលឲ្យយើងធ្វើអី?

សារិនៈ អើអញ្ចឹងបានថា ខ្ញុំដូចអភ័ព្វយ៉ាងម៉េច ដល់អញ្ចឹងខ្ញុំថាអត់អីទេ ប្រកាសក៏ប្រកាសទៅចូលមកសង្គមកិច្ចទៅ ។ បានបីខែ បានគេទម្លាក់ចូលកុងសី បានគេប្រកាសបើកប្រាក់រំព្ញកគេនោះ ។ បាននោះបានចូលទៅបើកប្រាក់រំព្ញក ចូលនិវត្តន៍អញ្ចឹងណា ។ ខ្ញុំក៏លើកដៃបញ្ចូនទៅឈប់ហើយឈប់ធ្វើអីទៀត ហើយខ្ញុំធ្វើក្រុមប្រឹក្សាស្រុកនេះ ។ ខ្ញុំអត់ដឹងខ្លួនទាល់តែសោះ ដល់ថ្ងៃគេប្រកាស ថាចឹងដឹង គេប្រាប់ទៅ គេប្រកាសប្រគល់កម្លាំងយើងហៅត្រូវការរៀបរយអញ្ចឹងឯងហើយ ឲ្យខ្ញុំធ្វើប្រធានក្រុមប្រឹក្សា ហើយសម្រេចពីក្រុម ។ បើនិយាយពីរឿងផ្ទៃក្នុងគេសម្រេច ខ្ញុំឈប់ហើយ មួយទៀតខ្ញុំចាស់ហើយខ្ញុំពិការ ដូចនេះហើយខ្ញុំអត់ចង់ធ្វើអីទៀតទេ ។ ប៉ុន្តែគេថា អត់ទេ ខ្ញុំត្រូវតែធ្វើព្រោះខ្ញុំមាន សមត្ថភាពក្នុងការធ្វើណា ដល់ពួកខ្ញុំឆ្លងកម្មវិធីច្រើន កម្មវិធីសាលា កម្មវិធី Unicief ក៏ខ្ញុំធ្វើ ដូចនេះខ្ញុំប្រលូកទៅហ្នឹង ខ្ញុំយល់សម្របសម្រួលប្រជាជន ទាំងអស់ក្នុងមូលដ្ឋាន អភិវឌ្ឍន៍ បានស្តារប្រជាជនឲ្យមានការរីកចម្រើនទាំងសុខភាព ទាំង សេដ្ឋកិច្ច ទាំងការ សិក្សាសាលារៀនអី បង្កើតតាំងពីអក្ខរកម្មរហូតដល់សាលាមេតយ្យ បាទ! យើងបង្កើតយើងធ្វើ ដល់ចឹងទៅខ្ញុំឈប់មិនឈប់គេថាអត់ឲ្យមានឥទ្ធិពលជាមួយនឹងប្រជា ពល រដ្ឋ ដល់ចឹងថាខ្ញុំក៏ ថាឲ្យធ្វើក៏ធ្វើទៅមកដល់បច្ចុប្បន្ននេះជាប្រធានក្រុមប្រឹក្សា ប្រធានក្រុម ប្រឹក្សាដឹកនាំធ្វើទៅតាមច្បាប់ដឹកនាំរបស់ក្រុមប្រឹក្សាប៉ុន្តែខ្ញុំមិនធ្វើអីឲ្យ ខុសពី អភិបាលកិច្ច ល្អបានទេ គឺធ្វើដើម្បីបញ្ញត្តិ ។ បើថានិតិបញ្ញត្តិនិតិប្រត្តិបត្តិហ្នឹង ខ្ញុំថាសេចក្តីអនុម័តហ្នឹង គឺ បញ្ញត្តិសម្រេចឲ្យអភិបាលតាមដាន ។ ខ្លួនឯងខំអនិវត្តន៍ក្នុងក្រុមប្រឹក្សាខ្ញុំឲ្យបានល្អ ដើម្បី កែទម្រង់ ក្នុងការដឹកនាំឲ្យបានល្អ ឲ្យប្រជាជនមានការគាំទ្រ បើមិនគាំទ្រទេ ដាច់ខ្យល់ទៀត ងាប់ពេលអស់អាណត្តិគឺ វាអស់ខ្យល់ដូចគ្នានេះរឿងនេះដែលខ្ញុំត្រូវការធ្វើ ហើយមួយទៀត មិនយកផលប្រយោជន៍ពិក៏បាន ប៉ុន្តែកិត្តិយសផ្ទាល់ខ្លួន តែយើងងាប់រាប់រយឆ្នាំនៅ គេនិយាយដែរ អាក្រក់ក៏នៅតែគេនិយាយ បើល្អក៏នៅតែគេនិយាយ ដូចនេះខំសាងអំពើល្អទៅ ដើម្បីងាប់ទៅគេនិយាយថាល្អដែរ តែប៉ុណ្ណឹងទេ

ខ្ញុំខំបម្រើជាតិបម្រើប្រជាជននៃ បម្រើ សង្គមដើម្បីអភិវឌ្ឍន៍ ប្រវត្តិសង្គម គឺមានការរីកចម្រើនតាំងពីផ្លូវអត់មាន រហូតដល់ឥលូវ ផ្លូវខ្វាត់ខ្វែងអស់ហើយសាលារៀន អត់មានសាលារៀន! ឥលូវហ្នឹងវាកើតមានគ្រប់ ឆ្លើយតបសឹងថាគ្រប់ភូមិណារៀនបានដូចការសិក្សារបស់សិស្ស គឺបានរហូតដល់មណ្ឌលសុខភាព តាំងពីអត់ដល់មានសុខភាពមានប្អូននៅក្នុង ដើម្បីឆ្លើយតបប្រជាពលរដ្ឋ ហើយសេដ្ឋកិច្ចតាំងពី ស៊ីបាយដែលមុនដំបូងគេជំនួយអង្ករ នៃជំនួយអង្ករឲ្យរហូតដល់ឥលូវហ្នឹងប្រជាជនថ្នាក់សៀម អស់លក់ចេញទៅវិញ ផ្ទុះតាំងពី ប្រក់តង់រស់នៅកន្ទេបកន្ទុប ឥលូវមកក្លាយជារស់នៅសមរម្យ និងប្រជាពលរដ្ឋនេះដែលពេលរស់នៅក្នុងសង្គមយូរហើយបានល្អហើយសេដ្ឋកិច្ច ឥលូវហ្នឹងសឹង ថាបំបាត់មធ្យោបាយចាស់ គេថាគោពពែក្របីអីចឹង ការប្រើប្រាស់ឧបករណ៍កសិកម្មឥលូវ ក្លាយទៅជាបាត់ពួកហ្នឹងអស់ទៅ ហើយគោយន្តត្រាក់ទ័រទៅវិញអស់ ។ នេះវាឈានមកដល់ដំណាក់កាលហើយលែងដើរ ហើយអាកូនទៅរៀនក៏ឈប់ដែរ បើម៉ូតូបានវាសប្បាយចិត្តទៅរៀន វាខុសពីមុន ។ ឥលូវហ្នឹងជាក់ស្តែងជីវភាពជីវិតខ្ញុំជាជនពិការ ហើយចិញ្ចឹមកូន៦នាក់ ប៉ុន្តែមុខរបរខ្ញុំគឺ បម្រើជាតិអត់រកស៊ីអីខុសពីនេះទេ ហើយជួយកូនដោយការស្មោះត្រង់ចឹង ហើយខ្ញុំគ្រប់គ្រាន់ក្នុងការហូបលុយកាក់ឧបត្ថម្ភឲ្យកូនវាមានការខ្វះខាតមែនប៉ុន្តែខ្វះខាតក្នុង ការអត់ជំពាក់គេ មួយជីវិតខ្ញុំដល់ដំណាក់កាលនេះហើយ ភាពអ៊ីដែលត្រឹមត្រូវពិតប្រាកដ គឺខ្ញុំចូលតស៊ូមកដល់បច្ចុប្បន្ន ខ្ញុំធ្វើភាពត្រឹមត្រូវរបស់ខ្ញុំរហូត តែឲ្យទៅក្នុងសង្គមណាក៏ដោយ ពាក្យថាយើងចូលបម្រើដើម្បីជាតិនិងប្រជាជន បំម្រើអីក៏ដោយ ។ គឺថាប្អូនស្វែងរកនេះ ហើយបើប្អូនចង់ដឹងអីសួរបញ្ជាក់ក្នុងដំណាក់កាលនោះ ខ្ញុំដឹងខ្ញុំនិយាយប្រាបប់ចឹងទៅណា តែមួយដំណាក់កាលមួយជីវិតខ្ញុំពេលនេះគឺខ្ញុំធ្វើបានប៉ុណ្ណឹង ហើយរស់ក្នុងសព្វថ្ងៃនេះ ខ្ញុំអត់ បោលទេពីមហាជន ប្រជាជនគាំទ្រគឺថាអត់មានខបសគ្គខ្ញុំធ្វើអីក៏ប៉ះពាល់គេទេ គឺប្រជាជន ទៅ ភូមិណា ដូចភូមិណាតែប៉ុណ្ណឹងទេ ។ ទី២គឺ ប្រវត្តិអតីតគឺជាខ្មែរក្រហមដែលអូនឯងស្វែងរក ការពិតពីធាតុខ្មែរក្រហម ។ ប៉ុនចំពោះបុគ្គល ហើយមួយទៀត ខ្ញុំសូមស្រាយថាក្នុងធាតុដឹកនាំ ទាំងអស់ ។ ខ្ញុំមើលថាសកម្មភាពខាងលើនេះចុះ ប៉ុន្តែអ្នកដែលស្គាល់ដឹកនាំ ខ្ញុំថាខ្មែរក្រហម មានចំណុចល្អ និងអាហ្នឹង ។ បើនិយាយពីរឿងបញ្ហាស្នេហាជាតិ ជំនាន់ហ្នឹងគេថាស្នេហាវណ្ណៈ ដល់ចូលបក្ស បានគេថាស្នេហាវណ្ណៈ គេការពារវណ្ណៈគេណាស់ វណ្ណៈដ៏ទៃចាត់ទុកជាសត្រូវ ទាំងអស់ ទាំងមូល ឯទី២ពាក្យថាស្មោះត្រង់ គឺស្មោះត្រង់តែម្តងពួកនេះ គ្មានអីនៅ ក្បែរហើយការពារអី គឺការពារហ្នឹងបានត្រឹមត្រូវ ។ ហើយទី២ពាក្យថាជាតិ ដូចពាក្យស្លោកថា ជំនាន់ហ្នឹង អ្នកដឹកនាំបានថាអត់មានឲ្យបាត់មួយចំអាមទីនេះទឹកដីកម្ពុជា មានលើដែនទីហ្នឹង គឺមិនឲ្យបាត់មួយចំអាមបានទេ

អ្នកណាឈ្នានពាន គឺអត់បានតែម្តង ត្រូវតែប្រឆាំង ត្រូវតែវាយហ្នឹង ខ្ញុំឃើញ ស្រលាញ់ហ្នឹង ហើយមួយទៀតដែលភាពត្រឹមត្រូវដែលល្អ គឺបញ្ហាទិសដៅ នៃការកសាង គឺខ្ញុំដឹងក្តាប់បានថានេះរបើសិនជាបើមួយឆ្នាំផុត ខ្ញុំថាសភាពការណ៍កម្ពុជា មិនមានការប្រែប្រួលខ្មែរក្រហមខ្ញុំក្តាប់បានទិស គឺឆ្នាំ៨០នេះ គឺឆ្នាំ៨០ ។ ៧៩,៨០ហ្នឹងគឺ យុទ្ធសាស្រ្ត ត្រូវអនុវត្តន៍ផែនការណ៍ថ្មីគឺ ទូទាំងប្រទេស ត្រូវការណ៍ប្រើគ្រឿងចក្រ៨០ ភាគរយ ។ ទាំងគមនាគមន៍ទាំងប្រឡាយប្រពន្ធ័កសិកម្មក គឺ៨០ភាគរយទាំងអស់ ២០ភាគរយ គឺមនុស្សអនុស្សអ្នកបញ្ហានេះប្រើកម្លាំងមនុស្សតែ២០ភាគរយទេ ។

បូលីៈ ចេញពីណា៨០ភាគរយហ្នឹង?

សារិនៈ ចេញពីគ្រឿងចក្រ ចង់យកភោកផល ។

បូលីៈ នរណាគេជាអ្នកដាក់ទិសហ្នឹង?

សារិនៈ ចុះអ្នកដឹកនាំគឺ ប៉ុល ពតហ្នឹង ។ និយាយនេះមិនមែនផែនការគណៈដឹកនាំមជ្ឈិមហ្នឹងគេពិភាក្សា ហើយដំណាក់ពីនោះ ពីរំដោះមកដល់បច្ចុប្បន្ន បានយើងឃើញថា ប្រព័ន្ធប្រលាយអីហ្នឹង ធ្វើហ្នឹងនៅកម្លាំងមនុស្សជំនាន់ប្រព័ន្ធប្រលាយជាគម្រោងទុក ក៏ជាបួង់ ប៉ុន្តែដល់គ្រឿងចក្រ បានគេកែលម្អធ្វើឲ្យល្អទូទៅដោយសំអាងអី សំអាងលើ សេដ្ឋកិច្ច គេឈរលើសេដ្ឋកិច្ចឯង អត់ចាយលុយវាមាន ប៉ុនវាមានសេដ្ឋកិច្ចដោះដូរសេដ្ឋកិច្ច ។ កាលហ្នឹងខ្ញុំដឹងណាកាលហ្នឹង ខ្ញុំទៅរៀនឆ្លងពុ្ងឯកសារគេណាស់ តែប៉ុណ្ណឹងទេ ។

បូលីៈ បើយើងមានសេដ្ឋកិច្ចម៉េចក៏មនុស្សស្លាប់ដោយដាច់ពោះច្រើនសម័យនោះ?

សារិនៈ ប្អូនឯងត្រូវដឹង! មានពីរជាគោល បើចឹងចុងបញ្ចប់ យ៉ាងម៉េចបានជាបូកគ្នាវាយលុក ដល់ចូលមួយទៀតមិន៣ ។ ១,២,៣ ណា៎! វាយតែមួយទេ អូនឯងឆ្ងល់ទេកន្លែងហ្នឹង? ឧទាហរណ៍ នៅក្នុង៣នាក់ហ្នឹង ប៉ុនខាងនេះស្អី ខាងនេះស្អីៗ ប៉ុន្តែនៅជាមួយគ្នាចឹងណា៎ ។ ពិបាកណាស់តាំងពីជំនាន់ហ្នឹង មានសេ-អ៊ី-អា និងកា-សេ-បេ ។ ឃើញទេហើយដល់ពួកមួយសារហ្នឹងទៀត ត្រូវជាមានចលានតស៊ូបូកមានបីហើយទាល់ហ្នឹងមុំ អាមេរិក លន់ នល់ ក៏ដើម្បីលេបកម្ពុជានេះ ដល់ចាញ់កម្ពុជា តើអាមេរិចឈឺចាប់ប៉ុណ្ណា ដែលចាយទន់យន្តហោះ B-៥២ ។ ២០០ថ្ងៃ ២០០យប់ ស្មើរហ្នឹងប្រជាជន៧លាននាក់ ទម្លាក់គ្រប់ ដើម្បីកម្ទេចដើម្បីគ្រប់គ្រងកម្ពុជា ប៉ុន្តែធ្វើត្រឹម ហើយចុះយុទ្ធសាស្រ្តផ្នែកខាងកើត វាថាតណ្ហូចិននេះវាគ្រប់គ្រងតណ្ហូចិន គេពុំមែនគ្រប់គ្រងតែមួយប្រទេសទេ ។ ហើយចុះយើងដឹកនាំថាឯករាជអត់ចូលជាមួយនរណាបក្សកម្មុយនីសដែរ ប៉ុនមិនរណបអ្នកណា តែគេឲ្យរស់ នេះពិចារណាមិនខុសពីបច្ចុប្បន្ន បើមិនខំរៀបចំ គេថាអាស៊ានហ្នឹង បើរៀបចំសមាគមន៍អាស៊ានទេ កូនអ៊ុក

នៅអាស៊ានទាំងប៉ុន្មានធ្លាក់មកដូចជារឿងថៃ បើសិនជាយើងមិនរាវែកទៀត ថៃនៅតែធ្វើ ព្រោះគេសេនាដៃស្តាំ អ្នកណាមានអំណាច ធ្វើតាមចិត្តគេចឹងណា មើលខ្ញុំធ្វើចឹង អានេះប្អូនត្រូវយល់ចឹង ដូចជាអូនឯងស្វែងរកការពិតដើម្បីបំភ្លឺឲ្យប្រជាជន ប៉ុន្តែការពិតខ្មែរក្រហមថាសម្លាប់ជាតិដោយខ្លួនឯងហ្នឹង គឺថា២លាននាក់ជាង ៗ ការពិតវាមិនដល់ប៉ុណ្ណឹងទេ បើគិតពី៧០មក អាយន្តហោះអាមេរិចសម្លាប់ ហើយចុះសម្លាប់គ្នានៅក្នុងសមរភូមិទ័ពក្នុងទ័ព គិតបើសមរភូមិកងទ័ពខាងខ្មែរក្រហម កងទ័ពខាងរំដោះតើស្លាប់ប៉ុន្មាន របួសប៉ុន្មាន ហើយចុះកងទ័ពលន់ នល់ នោះងាប់ប៉ុន្មានបើចុះដើរអត់មានស្អីសោះ ហើយគេហ្នឹង គេបាញ់ យើងងាប់១០នោះអន់បំផុតក៏ងាប់៣០ដែរ ព្រោះពីដើមមានស្ពាយដី ស្ពាយអាវមកណា មានតែគ្រាប់កាំភ្លើង គិតណាចុះយន្តហោះទម្លាក់អាបេ-៥២ហ្នឹង មួយភូមិៗ ប៉ើងជារណ្តៅអណ្តូង មើលអាខ្លះនៅជាប្រវត្តិសាស្ត្រមកឥលូវមិនទាន់លុបផងណាស់ ព្រៃលើប៉ើងនៅសមរភូមិតាកែវនៅប៉ើងគល់ឡើងលើនោះ គេហៅព្រៃលើនែក សមរភូមិ ៗ ខ្ញុំឃើញបើអញ្ចឹងហេតុផលបញ្ហាក់នេះសូមប្អូនចេះតែថាទស្សនៈខ្ញុំទេ ខ្ញុំថាបើជាការពិតស្លាប់សម្លាប់គឺនៅការគ្រប់គ្រង គឺថាការបញ្ចូលគុកហើយសម្លាប់ហើយណា ៗ ពួកខ្ញុំនេះមិនដឹងទេ ពួកសមរភូមិ ពួកខ្ញុំជាកងទ័ពនៅមុខណា ប៉ុន្តែបញ្ចូលរឿងការសម្លាប់នេះ ភាគច្រើនគ្រាន់តែយល់និយមន័យគេនិយាយថាពួកសត្រូវគេមិនទុកទេណា៎ ពួកកម្មុយនីសអត់បានដើម្បីឈ្នះយុទ្ធសាស្ត្រគេអត់ទុកទេ ពួក១៧មេសា ដែលក្រោយពីរំដោះមកនៅប្រឡូកប្រឡល់ក្នុងមូលដ្ឋានតាមផ្នែកៗណា ហ្នឹងដោយសារប្រជាជនច្រើនតែធ្វើចឹងណា ដល់ធ្វើចឹងពួកខ្ញុំច្រើនតែនៅមុខកងទ័ពម៉េចទៅ ហើយប៉ុនដល់ពេលវាចោទប្រកាន់អាអ្នកល្អថាត្រឹមត្រូវក៏ងាប់ដែរហ្នឹងរឿងហ្នឹង រឿងនេះទៅវិញទៀត ៗ មួយជាប់កា-សេ-បេ ហើយអាមួយចោទ កា-សេ-បេថាពួកអានេះសេ-អ៊ី-អា ដល់ចឹងអ្នកខាងលើអត់បានតាមដានល្អិតល្អិនទាន់ ដល់ចឹងទៅ ខ្លះអន់ឆ្លង ដល់លើផង អាអ្នកខំទៅពួកនេះប៉ះដៃយក ប៉ះជើងយកជើងអាហ្នឹងដែលជាចំណុចអាក្រក់ តែបើចំណុចល្អ មាត់ទៅព្រះវិហារ បើជិនទាន់ខ្មែរក្រហមវិញណាធ្វើអន់បំផុតគឺចូល ៗ អន់បំផុតគឺ៥០គីឡូ ខ្មែរក្រហមចូលទៅវិញ ហានសាកមើល! ធ្វើចឹងដើម្បីយុទ្ធសាស្ត្ររបស់ខ្មែរក្រហមវិញ មានពីណាហានធ្វើអញ្ចឹង ហានតែប៉ះរបស់យើងវាយបាក់គីដេញ ចេះតែទៅហើយ ៗ ប៉ុនដល់ចរចារនិយាយថាសូមឲ្យគោរពណាដែនទី ណាដែនដីប្រទេសមួយៗឲ្យច្បាស់លាស់នេះ ដែនទីដែលមានហើយសូមគោរព កុំរំលោភបំពានបើរំលោភបំពាន ខ្ញុំបំពានវិញហើយ អត់ទៅទេ រួចដាក់មើលជាប់ស្ទេញឥលូវហើយ មិនបាប់ទៅចរចារឯណាទេ ៗ

បូលី: នៅព្រះវិហារលោកតូ?

សារិនៈ បាទ! រឿងព្រះវិហារ ។

បូលីៈ ចូលព្រះវិហារ ។

សារិនៈ រឿងនេះបើទស្សនៈអ្នកដឹកនាំកាលហ្នឹងជំនាន់ខ្មែរក្រហម ហើយយួនក៏ចឹង វាយគ្នាតាមព្រំដែន ដោយសារអី គឺដោយសារការពារចឹងនេះ ។

ថនៈ ចុះអីកាលជំនាន់អី ឈរមួយជួរ១០០១នេះអីមានដែលទៅដល់ប្រាសាទព្រះវិហារទេអី?

សារិនៈ ទេ! យើងទៅគ្រប់គ្រងនៅកម្ចាំងនៅក្រោយ អត់ទេ គេមានតែកម្លាំងទ័ពទេណា ទ័ពហ្នឹងគឺមានខាងនេះគឺ១០០១ឈរ ដល់ក្រោយមក១០០៣ វាដូរផ្លាស់១០០១ចុះមកចឹងណា ហើយកន្លែងហ្នឹង គឺខ្ញុំនិយាយត្រង់កាលហ្នឹងជំនាន់ខ្មែរក្រហមនៅទឹកដីគេមែន ប៉ុន្តែជាមួយថៃ ក៏មានការប៉ះដែរ ហើយខ្មែរក្រហមថា អត់ទេ ទឹកដីខ្មែរកមចូលណា តែចូលគ្រោះថ្នាក់ទទួលខុសត្រូវទេ ប្រាប់បីដងនៅតែចូលគឺត្រូវហើយ ព្រោះទឹកដីគេនិយាយតែទឹកដីឯខ្ញុំនៅទឹកដី អ្នកឯងគឺរដ្ឋាភិបាលអ្នកឯង ឲ្យតែមេខ្ញុំឈ្លានពានទៅ ប៉ុន្តែនោះមានអ្នកគួសត្រូវប្រចាំ គាទៅមានគ្រោះថ្នាក់ ហើយកុំថាទឹកដីឯងនៅអត់បាន គេនិយាយចឹង ។

ថនៈ ចុះម្ខាងព្រះវិហារហ្នឹង ពីណាគេអ្នកគ្រប់គ្រងនៅព្រំដែន?

សារិនៈ ព្រំដែន! ពីមុនគេហៅ១០០១ ហើយ ១០០២ ។ ១០០២ ហ្នឹងគឺនៅព្រះវិហារ ដល់ក្រោយមក១០០២ក៏ឈប់មានទៅ ដកទៅចូល១០០៣ទាំងអស់ ។ ១០០៣នៅតែគ្រប់គ្រងមានផ្ទះតាម៉ុកសាងសង់ អាផ្ទះក្រហមនៅហ្នឹងនេះ ហៅថាផ្ទះតាម៉ុកឃ្លាំងសម្ភារបើកកម្លាំងទ័ពនៅហ្នឹង ។

បូលីៈ ផ្ទះក្រហមហ្នឹង ផ្ទះតាម៉ុកហ្នឹង?

សារិនៈ បាទ! ផ្ទះតាម៉ុកធ្វើ ។

បូលីៈ ដីខ្មែរយើងចឹង?

សារិនៈ បាទ! ដីខ្មែរ ធ្វើអត់ដែលធ្វើលើគេទេ គានោះធ្វើលើព្រំប្រទល់ ។

បូលីៈ តែឥលូវថៃដាក់អត់ជាតិបាត់ហើយ?

សារិនៈ ហ៊ឹម! អត់ទេ! ឥលូវអត់គេនិយាយបកស្រាយសាលក្រម គឺត្រូវតែដកវិញទាំងអស់ ។ នរណាលើកនៅណាក៏ដោយ គឺត្រូវតែដក ត្រូវគោរព ។

បូលីៈ ព្រោះនៅក្នុងសាលក្រមដែលតុលាការដាក់មកហ្នឹងវាអត់គ្រប់ដណ្តប់ផ្ទះក្រហមហ្នឹងទេ គ្រប់ដណ្តប់តែផ្លូវឡើង វត្តកែវសិក្ខាគិរីស្វរ ហើយនឹងវាលឥន្រ្ទី ផ្ទះក្រហមវានៅឆ្ងាយពីហ្នឹងទៀត ។

សារិនៈ អត់ទេ! គេអត់មាននិយាយ គេថានៅជុំវិញប្រាសាទព្រះវិហារ និងតំបន់ជុំវិញ តែប៉ុណ្ណឹងទេ តែប្រវត្តិសាស្ត្រតាម៉ុក គាត់អត់ដែលធ្វើនៅលើដីគេទេ ។ គាត់ធ្វើអ្វីជាព្រំជាគោលសំខាន់នៅចំណុចព្រំដែនហ្នឹងដែលចាប់ពីក្បាលទន្សោង មកផ្លូវចាស់ហ្នឹង គាត់ធ្វើ តាមខ្សែព្រំប្រទល់ព្រំដែនទាំងអស់ គាត់អត់ធ្វើចូលដីគេទេ ។

បូលីៈ ចឹងបានន័យថា ផ្ទះក្រហមដែលថៃដាក់ទង់ជាតិនោះជាដីខ្មែរ ជំនាន់ខ្មែរក្រហម?

សារិនៈ ជំនាន់ខ្មែរក្រហមតាម៉ុកអ្នកធ្វើ ហើយធ្វើហ្នឹងគឺសម្រាប់អី គាត់ទៅចាត់ចែងគឺផ្ទះហ្នឹង សម្រាប់ដឹកសម្ភារផ្សេងៗ ផ្តល់ឲ្យគាត់ ។ ការពិតចឹងតែម្តង ហើយគាត់អត់ដែលធ្វើខុសទេ គ្រាន់តែមើលច្រកឈូករុន ថៃមិនហានមក ប៉ុនកម្លាំងមកម្លោះហើយធ្វើព្រំដែន ។ ទឹកដី១ម៉ែត្រ ១ទឹកប៉ុនគេសោះកុំចូក ធ្វើសម្រាប់ព្រំប្រទល់សីមាយើងទឹកដីយើង កុំឲ្យគេកិលបានតែប៉ុណ្ណោះទេ ។ តានោះគាត់មាន គំនិតចឹងប៉ុន្តែគាត់និយាយចឹងតែម្តង ប៉ុន្តែសកម្មភាពគាត់ គាត់ធ្វើជាក់ស្តែងមែនប៉ុន្តែរឿងការចាត់ចែងអីណាយ៉ាងខ្ញុំមិនដឹងទេព្រោះអ្នកដឹកនាំខាងលើចឹងណា ។

ថនៈ ពីដំបូងផ្ទះហ្នឹងសាងសង់ពីអីវិញ? ផ្ទះតាម៉ុក ថាផ្ទះក្រហមនោះសាងសង់ពីអីវិញ ឈើ ឬក៏ថ្ម?

សារិនៈ ការពិតទៅពីថ្ម ហើយចាក់ស៊ីម៉ង់ ស៊ីអីទៅហ្នឹងណា លាបទៅធ្វើប្រក់ស៊ីប្រូស៊ីម៉ង់ក្រហមនោះគេហៅផ្ទះក្រហមទៅ ។ ខ្ញុំអត់មានបានទៅទេ ព្រោះថ្មពួនដឹកមកដុត មកនេះបណ្តោយ ។ ហើយសមរភូមិចែកគ្នាដាច់ តែបើមុំពខ្ញុំដឹង ។

ថនៈ អឹមអត់ដែលបានទៅប្រាសាទទេ?

សារិនៈ អត់ទេ!

ថនៈ រឿងប្រាសាទ អត់ដែរតែម្តង?

សារិនៈ បាទ! រឿងប្រាសាទ ខ្ញុំអត់បានទៅដល់ទេ ព្រោះខ្ញុំអ្នកពិការ ដូចនេះគេអត់ឲ្យចូលទេ ហើយមួយទៀតមានតែអ្នកប្រយុទ្ធ បើអ្នកប្រយុទ្ធបានអ្នកទៅ ហើយទៅហ្នឹងក្នុងនាមគេជាអ្នកការពារប្រាសាទហ្នឹងផង ហើយចុះសកម្មភាពធ្វើការមកតំបន់រដ្ឋាភិបាលផង ។

ថនៈ អឹចុះកាលហ្នឹង ខាង១០០២ អ្នកឈរជើងនៅហ្នឹង? ហើយជំរុំ១០០២ នៅឯណាដែលទៅហើយនរណាគ្រប់គ្រង?

សារិនៈ ១០០២ កាលហ្នឹង! តារិន! តារិន កូនប្រសារ តាម៉ុកហ្នឹងហើយ កើតមុនគេហៅ១០០២ គឺនៅហ្នឹងដែរ ។ ហ្នឹង តាំងពី១០០១កើត ១០០២ក៏កើត ១០០៣ក៏កើតណាស់ ។

បូលីៈ បន្ទាប់ៗគ្នា!

សារិនៈ ហ្នឹងហើយ! បណ្តេញគ្នាទៅលិចទៅរហូត ទៅដល់កោះកុង ។

ថន: ចឹងទ័ពគាត់ឈរជើងនៅអំពុំ ជួរប្រាសាទព្រះវិហារ?

សារិន: ទ័ពនរណាគេ?

ថន: ទ័ព១០០២ តាវិនហ្នឹង?

សារិន: បាទ! តាវិន កូនប្រសារតាម៉ុក គឺគាត់ជាប់កម្លាំងគាត់នៅហ្នឹងឯង។

បូលី: កងពលលេខប៉ុន្មានអ៊ំ?

សារិន: ខ្ញុំអត់ដឹងទេ! គាត់បែកពីខ្ញុំតាំងពីរំដោះហើយមក គាត់ចេញមក មកនៅកងពលប៉ុន្មាននេះ ប៉ុន្តែខ្ញុំមិនដឹងថាតាវិន កាលហ្នឹងនៅនោះគឺតាខៀវ ១០០១នោះមានជាប់បងប្អូនបង០៥, កែពក សុទ្ធតែកងទ័ព កងពលណា! តាមផ្នែកៗចឹងណា ប៉ុនតាខៀវគាត់គ្រប់គ្រងនៅ១០០១ នៅមុំពាណា តែតាវិននេះគឺនៅចំណុះ១០០៣ ប៉ុន្តែគាត់ចូលប្រកសមរភូមិ១០០២ហ្នឹងនែក ជំនួសតាម៉ុក កូនប្រសារនោះ ហើយតាម៉ុកនោះមកនៅ ១០០៣នេះចឹងណា ដឹងច្បាស់ចឹងទេ ប៉ុន្តែរឿងរចនាសម្ព័ន្ធប្រព័ន្ធដឹកនាំ ខ្ញុំអត់បានប្រលូកចូលទេ ខ្ញុំដឹងតែនៅតែ១០០១ចឹងណា។ តែខ្ញុំដឹងថាអារឿងកងទ័ពដែលនៅហ្នឹងមានតាវិនហើយ តាវិនក៏គាត់ជាកងពលមួយមានកម្លាំង សមរភូមិមួយមានកម្លាំង គាត់ឈរនៅហ្នឹងហើយ គេដាក់ឲ្យទិសការពារប្រាសាទហ្នឹងហើយនែ។

ថន: ចុះខាងថៃ ជំនាន់នោះខាងថៃអីមិនឈរជើងនិយាយថាដូចសព្វថ្ងៃខ្មែរក្រហមទេ?

សារិន: អត់ទេ! សម័យខ្មែរក្រហមនរណាហាន ការពិតទៅថៃអ៊ំខ្ញុំយល់កាលហ្នឹងវិភាគខ្លួនឯងទេ។ ថៃវាក៏បន្ទរដៃ ដោយទី១ការពារប្រទេសខ្លួនឯងផង ហើយមើលទៅពិបាកទប់កើតណាស់ មានយកសហការណ៍ជាមួយខ្មែរក្រហម ទប់ស្កាត់ព្រំដែនហ្នឹង ព្រោះយួនកាលហ្នឹង ឡើងដល់ព្រំដែនទាំងអស់នៅលើភ្នំ នៅលើកំពូលភ្នំសុទ្ធតែយួន ដល់ចឹង គឺថាថៃគ្នាពិបាកណាស់កាលហ្នឹងនោះ ខ្ញុំមិនវាយថៃទេ ចឹងបានន័យថាបានខ្មែរក្រហមទេជួយទប់នោះកាលនោះ។

ថន: អឹ! ម្សិលមិញ អ៊ំ ថុង នោះគាត់ថា កាលគាត់ទៅ៩៩ឃើញថៃធ្វើផ្លូវពីផ្ទះក្រហមនោះមក ព្រោះផ្លូវនោះនៅមិនទាន់ធ្វើទេ នឹងគាត់ទៅ៩៩ហើយ។

សារិន: នរណាគេថុង?

ថន: បាទ អ៊ំថុង! ក្រោយសមាហរណកម្មហើយ ថៃទើបតែធ្វើផ្លូវថ្មីៗហើយ ពីផ្ទះក្រហម មក ជើងប្រាសាទ?

សារិន: ខ្ញុំអត់ដឹង! បើអត់ដឹងខ្ញុំនិយាយទៅថាអំដឹង បើដឹងនិយាយតាមដឹង បើអត់ដឹង មិនដឹងជាធ្វើម៉េច ប៉ុន្តែផ្លូវមានផ្លូវជណ្តើរចុះទៅថៃទៅមានប៉ុន្តែ មានផ្លូវគេធ្វើ ធ្វើមិនដឹងទេណា អាហ្នឹងនិយាយចុះក្នុងន័យថា បើមានជណ្តើរចុះ ព្រោះអីត្រូវមានផ្លូវ ប៉ុនមិនដឹងថាមានអ្នកណាប្រើ

ដូចនេះយើងធ្វើត្រឹមតែទឹកដីយើងហ្នឹង ព្រោះការពិតអ៊ីដែលយើងនិយាយសុទ្ធតែការពិត កុំឲ្យនិយាយចេះតែនិយាយ ហើយដល់ចឹងទៅការសួរការឆ្លើយយើងអត់ដឹង ដល់ចឹងចេះតែដឹងៗចេះតែថាពិបាកដែរ ។ បើចឹងរកការពិតមិនឃើញទេ អាពាក្យបន្ទំនោះ ។ នេះខ្ញុំនិយាយ ជាការពិតណាស់ ប៉ុន្តែនៅក្នុងប្រវត្តិសាស្រ្តចប់ត្រឹមហ្នឹងហើយ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំជូនប្អូន ប៉ុនហ្នឹងហើយប្អូនខ្ញុំ. ចង់វិភាគពិចារណាតែបើអ៊ីដែល ដូចថាឆ្ងល់នៅចំណុចអីទៀត ថ្ងៃក្រោយទំនេរមកសួរបានៗ ខ្ញុំបើកចំហ ឲ្យក្មួយ ឲ្យជាតិស្គាល់ថា បើបុគ្គលគេខ្ញុំមិនដឹងទេ បើបុគ្គលខ្ញុំដើម្បីឲ្យជាតិយល់ពីខ្ញុំនេះ តើខ្ញុំនេះធ្វើអីខ្លះសម្រាប់ជាតិ ជាការពិតគឺអញ្ចឹងទេ ប៉ុនប្រយុទ្ធដើម្បីខ្លួនកើតមកពីពោះម្តាយនៅសិក្សារៀនសូត្រ មិនដែលនៅរហូតដល់ខ្លួនឯងសព្វសាច់ហើយពិការទៀត មូលហេតុដើម្បីជាតិហ្នឹងតែមួយមុខ មិនមែនដើម្បីបុគ្គលណាមួយទេ ។ ដល់ពេលចុងបញ្ចប់ ខ្ញុំឆ្លើយបម្រើជាតិ ខ្ញុំធ្វើកម្រិតណាៗ ហើយមួយទៀតខ្ញុំអត់ដែលធ្វើឲ្យយុទ្ធជនហ្នឹងអន្តរាយ ឬប្រជាជនមូលដ្ឋានដែលរស់នៅបុគ្គលណាម្នាក់ទៀតក៏អត់ទេ ខ្ញុំតាមតែបម្រើភារកិច្ចមួយអភិវឌ្ឍន៍សេដ្ឋកិច្ច និងការពារ ។ បង់បំផុតនៅសម័យ៣ឆ្នាំនោះ៨ខែនោះ គឺការពារហើយសេដ្ឋកិច្ច ។ អត់មានដឹកនាំមូលដ្ឋានទេ សេដ្ឋកិច្ចគឺចូលរួមចំណែកអភិវឌ្ឍន៍ជាមួយប្រជាជនហើយនឹងធ្វើដោយខ្លួនឯងដោះស្រាយគាំទ្រខ្លះ បើបានដាក់ចូលជម្រុកទុកទៅ កាលណាកុន កិនបុកស៊ីទៅមែនទេ តាមព្រំដែន ។

បូលី៖ ដូចជារំខានអ៊ីយូរដែរ អគុណអ៊ីច្រើនដែលបានផ្តល់ពេលបទសម្ភាសន៍វែងអន្លាយមែនទែន បានព័ត៌មានច្រើន ។

សារិនៈ បាទ! ខ្ញុំក៏គុណដែលប្អូនណាស់ ដើម្បីអូនឯងស្វែងរកការពិតដើម្បីជាតិ និងប្រជាជនជាពិសេស យុវជន យុវនារីជំនាន់ក្រោយដែលកើតអត់ទាន់សម័យនោះ នេះសូមស្រាយបំភ្លឺថាអ៊ីទាំង អស់ដែលយើងចង់បានវាមានការពិតចឹង ប៉ុន្តែនៅក្នុងករណីដែលមូលហេតុដូចប្អូនបញ្ជាក់មិញថាយ៉ាងម៉េចបានជាទៅជាសម្លាប់មនុស្ស ។ ចឹងខ្ញុំសូមបញ្ជាក់បន្ថែមថាមានយុទ្ធសាស្រ្តពីរដែល បុកគ្នាធ្វើឲ្យយើងអ្នកកណ្តាលពិបាកណាស់ ។ ២ជាយុទ្ធសាស្រ្តទាំងពីរ ។ ទី១គឺខាងលិច ទី២ គឺខាងកើត ពាក្យមួយមាត់នៅក្នុងកិច្ចព្រមព្រៀងដោះស្រាយចរចារឈប់វាយគ្នា គេជារៀមច្បង ខ្ញុំព្ទចឹង ព្ទថាគេរៀមច្បង ឲ្យឈប់ម៉ោងណា ម៉ោងហ្នឹងប៉ុនដល់អ្នកដឹកនាំកម្ពុជាក្រោយ អត់ឈប់វាយតែរហូត ត្រង់នេះហើយដែលចាត់ទុកអត់ស្តាប់ អត់គោរពគ្នា ។ នៅខាងលិច សេនាប្រមុខ លន់ នល់ ជាកូនអ៊ុកនៅក្នុង (ស្តាប់ពុំបាន) ទៅគេចំណាយធនធានពេលហ្នឹង យ៉ាងម៉េចខ្លះមក ធ្វើថាគេចាញ់ គេសុខចិត្តទេ! គេចាញ់ គេនៅតែឈឺចាប់ណាស់ នេះដល់ចឹងទាំងពីរបុកគ្នា បុកទៅមិនរួច បូកគ្នាលែងមួយ អានេះខ្ញុំយល់ទេណា

ខ្ញុំវិភាគទេប៉ុនដល់ពេលឥលូវបានយើង ដឹងថាដំណើរគេទៅចឹង ប៉ុន្តែឥលូវកម្ពុជាយើងបានចឹងមកហើយ ប្រជាធិបតេយ្យដឹកនាំសេរីពហុបក្ស ដល់ប្រជាធិបតិយ្យសេរីពហុបក្សខាងណាក៏ទទួលដែរ ដើម្បីឲ្យទៅប្រទេសយើង អភិវឌ្ឍន៍រីកចំរើននែ៎ៗ បើពីមុនវាកម្មុនីស សេរីមកក៏អត់រហូតៗ កម្មុយនីសធ្វើមិត្រូវដឹកនាំ នេះក៏អត់ឲ្យចូលដែរ ពាក្យកម្មុយនីសៗ លទ្ធិមួយមែនប៉ុន្តែដល់មាគ៌ាបែងខុសគ្នាអត់ឲ្យចូលទេៗ ត្រង់ហ្នឹងហើយដែលជាតិខ្មែរយើង មានភាពរលំរលាយ រលាយសម្លាប់គ្នាគឺមានអញ្ចឹង ហើយខ្ញុំសួរថា បងខ្ញុំយល់ថាគេដឹកនាំ ដែលដឹកនាំសត្វដឹកនាំគេទេ គេថាដឹកនាំជាតិៗនោះ គឺមនុស្សអ្នកដឹកនាំហើយៗ តែបើសម្លាប់មនុស្សពាក្យថាដឹកនាំគឺអត់ទៅរួចទេ ប៉ុន្តែក្នុងករណី ធ្វើដល់តែចឹងហើយ ហើយអូនយកទៅពិចារណា ទៅនែ៎តែប៉ុណ្ណឹងទេ ប៉ុន្តែខាងណាៗមិនដឹងទេ ខាងកើតចង់រីកទៅលិច ខាងលិចចង់រីកទៅកើតយូរៗទៅជាមហាអំណាចគ្រប់គ្រងទាំងមូល ទាំងពីរនេះធ្វើឲ្យសាលកលោកទៅអស់មិនបានសុខនែ៎ៗ ហើយខ្ញុំក្តាប់បានឆ្លងហើយខ្ញុំចាប់ចាំ ទៀត ឯកសារដែលរៀបចុងក្រោយបន្ទស់បណ្តាំ បណ្តាំគាត់ណា អ្នកប៉ុល ពតហ្នឹងតែម្តងៗ គាត់មានពាក្យបណ្តាំថាត្រូវចាំជានិច្ចសង្រ្គាមនយោបាយទៅពុំរួចគឺសង្រ្គាមយោធា សង្រ្គាមយោធាចប់ រលីងហើយមានសង្រ្គាមអីទៀត សង្រ្គាមសេដ្ឋកិច្ចៗ ឥលូវនេះសង្រ្គាមសេដ្ឋចូលហើយ បច្ចុប្បន្នមិនសង្រ្គាមសេដ្ឋកិច្ចៗ សង្រ្គាមសេដ្ឋកិច្ចចប់ គឺសង្រ្គាមសាសនាៗ គាត់ផ្តាំថា ឲ្យចូលទៅ និងប្រលូកសង្គមប្រជាធិបតេយ្យសេរីដឹកនាំ គាត់ផ្តាំថាកុំទៅធ្វើអ្នកធំអស់បើគ្មាន តួនាទី គេឲ្យធ្វើត្រឹមភូមិឃុំបានហើយ ចប់នៅហ្នឹងប្រជាជនដឹងសុខទុកប្រជាជនណែ៎ក គាត់ផ្តាំ គាត់និយាយអីខ្ញុំកត់ទុកឯកសារហ្នឹងទៅមុខបាត់កាលសមាហរណកម្ម ឯកសារហ្នឹងគាត់សៀវភៅណា៎ សៀវភៅកម្រាស់នេះ បាត់ឯកសារនេះ ខ្ញុំស្តាយមែនទែន ហើយគាត់ផ្តាំថាចាំមើលការបុណ្យៗៗ អ្នកឯងរកលុយបាន ប៉ុន្តែការបុណ្យ ហើយក្នុងរបបហ្នឹង គេបង្កប់ គាត់និយាយដាក់ពាក្យគេបង្កប់ថាឲ្យ៥ម៉ឺនមក ប្តូក៏១០ម៉ឺនទៅណាមេណានេះៗ គាត់ដាក់ឲ្យហើយស្រេចៗ

បូលីៈ ដល់មកឃើញចឹងមែន?

សារិនៈ ឃើញក្បែត់! ដល់ចឹងសង្គមចាយលុយ គឺចឹង! បានចេញមកថា អភិបាលកិច្ចល្អៗ អភិបាលកិច្ចល្អ តាមខ្ញុំសិក្សារៀនសូត្រខ្ញុំចាំ ប្អូនឯងចាំទេ! ប្អូនឯងអ្នកទទួលការពិត អភិបាលកិច្ចល្អសូមបកស្រាយ មើលខ្ញុំមានប៉ុន្មានៗ អភិបាលកិច្ចល្អហ្នឹងហើយ បានគេប្រជាធិបតេយ្យៗ គេអភិវឌ្ឍន៍ អភិបាលកិច្ចល្អ ទី១គឺចូលរួមជាកូន ទី២គឺនិតិរដ្ឋ គឺរដ្ឋធម្មនុញ្ញហ្នឹងឯង ទី៣គឺតម្លាភាព ទីព្រមព្រៀងឯកភាពនេះ ដឹកនាំគឺព្រមព្រៀងឯកភាពគ្នា ទី៥សមធម៌មួយមាត់គឺអត់រើសអើងទេៗ អ្នកណាក៏ដោយ គឺត្រូវតែជួយដោះស្រាយឲ្យអស់លទ្ធភាពៗ ពាក្យថា

សមធម៌គឺអត់ប្រកាន់ទេ ដល់ហើយបានយកចេញទៅពាក្យថាសមធម៌ ព្រមព្រៀងទៅគឺថា បានមានអនុវត្តន៍ឲ្យមានប្រសិទ្ធភាព យកគម្រោងសេចក្ដីសម្រេច ឬមួយផែនការទៅអនុវត្តឲ្យមានប្រសិទ្ធភាព។ ក្រោយមកបានទៅគណនីយភាព គឺភាពស្មោះត្រង់ អ្វីទាំងអស់ត្រូវមានការទូរទាត់លត់សោយ ឆ្លើយតបគ្នាទៅវិញ ទៅមកឲ្យដឹង ចាយធ្វើចេះៗនេះអស់ចិត្តណាស់ហើយ បានឆ្លើយតប។ អាទី៨ គឺឆ្លើយតប! ឆ្លើយតបយ៉ាងម៉េច គឺធ្វើអ្វីមួយឲ្យប្រជាជនទទួលផលប្រយោជន៍។

បូលីៈ អ៊ឹមាននៅសល់រូបថតអីចាស់ៗពីដើម?

សារិនៈ រូបថតខ្ញុំ?

បូលីៈ បាទ! បី៨០,៩០ អីមក។ ខ្ញុំចង់សុំមើលពីស្ថានភាពភូមិសាស្ត្រ ទិដ្ឋភាព សភាពពេលនោះយ៉ាងម៉េចចាស់ៗ។

សារិនៈ រូបថត មានតែរូបថតប្រពន្ធកូន ហើយរូបខ្ញុំដូចអត់មាន!

បូលីៈ ខ្ញុំបានទៅឱ្យ រូបថតអ្នកខាងអន្លង់វែង បានមួយចំនួន ដូចរូបចេះៗអី ខ្ញុំឱ្យគេមក។

«ចប់»